ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២

## ឆ្នាំ២០២៣



# មាតិកា

* * *

**អារម្ភកថា**........................................................................................................i

**អក្សរកាត់**........................................................................................................ v

**ខ្លឹមសារសង្ខេប**........................................................................................................ viii

**ផ្នែកទី១ - របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២៣**

I- **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច** ........................................................................................................ ១

១- ស្ថានភាពសេដ្ឋកិច្ចពិភពលោក........................................................................................................ ១

២- កំណើនសេដ្ឋកិច្ចក្នុងស្រុក ........................................................................................................ ៣

៣- ស្ថានភាពអតិផរណា ........................................................................................................ ៧

៤- អត្រាប្តូរប្រាក់........................................................................................................ ៩

៥- ស្ថានភាពជញ្ជីងទូទាត់........................................................................................................ ១១

៦- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ........................................................................................................ ១៤

II- **ការគ្រប់គ្រងរូបិយវត្ថុ**........................................................................................................ ១៥

១- ស្ថានភាពរូបិយវត្ថុ ........................................................................................................ ១៥

២- ការអនុវត្តនយោបាយរូបិយវត្ថុ........................................................................................................ ១៦

III- **ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា**........................................................................................................ ២២

១- ស្ថានភាពទូទៅ ........................................................................................................ ២២

២- វិស័យធនាគារ........................................................................................................ ២៥

៣- វិស័យមីក្រូហិរញ្ញវត្ថុ........................................................................................................ ២៧

៤- វិស័យភតិសន្យាហិរញ្ញវត្ថុ........................................................................................................ ២៨

៥- គ្រឹះស្ថានឥណទានជនបទ ........................................................................................................ ២៩

៦- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន ........................................................................................................ ២៩

៧- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........................................................................................................ ៣០

IV- **ការងារបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន** ........................................................................................................ ៣២

១- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា........................................................................................................ ៣២

២- ការអប់រំផ្នែកហិរញ្ញវត្ថុ........................................................................................................ ៣៣

៣- កិច្ចការពារអតិថិជន និងយន្តការគ្រប់គ្រងការដោះស្រាយបណ្តឹង ........................................................................................................ ៣៤

V- **ការផ្គត់ផ្គង់សេវាធនាគារកណ្តាល** ........................................................................................................ ៣៦

១- ប្រព័ន្ធទូទាត់សងប្រាក់........................................................................................................ ៣៦

២- សេវាគ្រប់គ្រងគណនី ........................................................................................................ ៤១

៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ..... ៤១
**VI- ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** ..... ៤៣
១- ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ..... ៤៣
២- ការងារវិភាគ និងបញ្ជូនរបាយការណ៍ ..... ៤៤
៣- កិច្ចសហប្រតិបត្តិការ ..... ៤៤
៤- ការបណ្តុះបណ្តាល ..... ៤៥
**VII- កិច្ចសហប្រតិបត្តិការអន្តរជាតិ** ..... ៤៦
១- កិច្ចសហប្រតិបត្តិការពហុភាគី ..... ៤៦
២- កិច្ចសហប្រតិបត្តិការទ្វេភាគី ..... ៥០
**VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា** ..... ៥២
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល ..... ៥២
២- ការអភិវឌ្ឍធនធានមនុស្ស ..... ៥២
៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ..... ៥៥
៤- សាខាធនាគារជាតិនៃកម្ពុជា ..... ៥៥
**សន្និដ្ឋាន** ..... ៥៦
**ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆ្នាំ២០២៣**
១- ការអនុវត្តនយោបាយរូបិយវត្ថុ ..... ៥៩
២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ..... ៥៩
៣- ប្រព័ន្ធទូទាត់សងប្រាក់ ..... ៥៩
៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ..... ៥៩
៥- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ..... ៦០
៦- ការងារប្រតិបត្តិការ ..... ៦១
៧- ការងារបោះផ្សាយនិងឃ្លាំងបេឡា ..... ៦១
៨- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ..... ៦១
៩- ការគ្រប់គ្រងសាខា ..... ៦១
១០- គណនេយ្យ ..... ៦២
១១- ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស ..... ៦២
១២- កិច្ចសហប្រតិបត្តិការអន្តរជាតិ ..... ៦២
១៣- ការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច ..... ៦៣
១៤ -ការងារស្ថិតិ ..... ៦៣

**ផ្នែកទី៣ - ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១ តារាង ១ -ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ........................ ៦៤
ឧបសម្ព័ន្ធ ២ តារាង ២ -ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ)....... ៦៥
ឧបសម្ព័ន្ធ ៣ តារាង ៣ -ស្ថិតិស្ថានភាពធនាគារកណ្តាល ............................................ ៦៦
ឧបសម្ព័ន្ធ ៤ តារាង ៤ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត .................. ៦៧
ឧបសម្ព័ន្ធ ៥ តារាង ៥ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើ ................................... ៦៨
ឧបសម្ព័ន្ធ ៦ តារាង ៦ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ................................ ៦៩
ឧបសម្ព័ន្ធ ៧ តារាង ៧ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុ........................................... ៧០
ឧបសម្ព័ន្ធ ៨ តារាង ៨ -ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច ......................... ៧១
ឧបសម្ព័ន្ធ ៩ តារាង ៩ -សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ..................... ៧២
ឧបសម្ព័ន្ធ ១០ តារាង ១០ -ជញ្ជីងទូទាត់ប្រទេសកម្ពុជា .................................................. ៧៣
ឧបសម្ព័ន្ធ ១១ តារាង ១១ -បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពីឆ្នាំ២០១៨ - មីនា ២០២៣ ............................................................................................ ៧៤
ឧបសម្ព័ន្ធ ១២ បញ្ជីលេខទូរសព្ទទំនាក់ទំនងអំពីចម្ងល់និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ................................................................................................ ៧៦

## អារម្ភកថា

នៅឆមាសទី១នេះ សេដ្ឋកិច្ចពិភពលោក បានបន្តងើបឡើងពីវិបត្តិកូវីដ-១៩ ប៉ុន្តែក្នុងសន្ទុះយឺត ដោយសារផលប៉ះពាល់ពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន អត្រាអតិផរណាខ្ពស់ និងការអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត ជាពិសេសនៅសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប។ នៅប្រទេសចិន ក្រោយបញ្ចប់វិធានការគ្មានកូវីដ សេដ្ឋកិច្ចចិនបានងើបឡើង ប៉ុន្តែក្នុងល្បឿនយឺត ជាមួយការធ្លាក់ចុះនៃចំណាយប្រើប្រាស់ សមត្ថភាពប្រើប្រាស់ក្នុងផលិតកម្មមានកម្រិតទាប និងបញ្ហាក្នុងវិស័យអចលនទ្រព្យ។ នៅតំបន់អាស៊ាន សេដ្ឋកិច្ចរក្សាបានកំណើនល្អ ដោយសារកំណើនតម្រូវការក្នុងស្រុក និងការងើបឡើងលឿននៃវិស័យទេសចរណ៍ ដែលបានផាត់ទាត់នូវការថមថយល្បឿននៃការនាំចេញ។

ក្នុងបរិការណ៍នៃការថមថយល្បឿនកំណើនសេដ្ឋកិច្ចពិភពលោក ការនាំចេញរបស់កម្ពុជាក៏បានថមថយផងដែរ ជាពិសេស ផលិតផលកាត់ដេរ ស្បែកជើង និងផលិតផលធ្វើដំណើរ ខណៈដែលការនាំចេញក្រៅពីផលិតផលកាត់ដេរ ដូចជា គ្រឿងអេឡិចត្រូនិក កៅស៊ូ និងអង្ករបន្តកើនឡើងខ្ពស់។ ចំពោះវិស័យទេសចរណ៍ ជោគជ័យនៃការរៀបចំព្រឹត្តិការណ៍ធំៗ ដូចជា កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ដែលបានលើកមុខមាត់កម្ពុជាលើឆាកអន្តរជាតិ បានទាក់ទាញទេសចរបរទេស ដែលការណ៍នេះបានចូលរួមលើកស្ទួយសកម្មភាពទិញ-លក់ទំនិញនិងសេវាក្នុងស្រុកផងដែរ ជាមួយនឹងទេសចរក្នុងស្រុកមានកំណើនល្អប្រសើរ។ ទន្ទឹមនេះ វិស័យកសិកម្មបន្តរក្សាបានកំណើនទាប ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនដំណាំស្រូវ កៅស៊ូ និងអនុវិស័យជលផល ស្របពេលដែលវិស័យសំណង់និងអចលនទ្រព្យកើនឡើងក្នុងល្បឿនយឺត ដែលគាំទ្រដោយកំណើនលំហូរទុនវិនិយោគបរទេស និងគម្រោងសំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

ដើម្បីគាំទ្រការងើបឡើងនៃសេដ្ឋកិច្ចជាតិ ធនាគារជាតិនៃកម្ពុជាបានបន្តរក្សាស្ថិរភាពថ្លៃ អភិវឌ្ឍប្រព័ន្ធធនាគារ និងប្រព័ន្ធទូទាត់ ដែលបានជួយជំរុញដល់ការអភិវឌ្ឍវិស័យនានាឱ្យប្រព្រឹត្តទៅដោយពិលាស។ ក្នុងការរួមចំណែករក្សាស្ថិរភាពថ្លៃនិងជំរុញកំណើនសេដ្ឋកិច្ចជាតិ នយោបាយរូបិយវត្ថុត្រូវបានអនុវត្តប្រកបដោយភាពបត់បែននិងប្រុងប្រយ័ត្នខ្ពស់។ សន្ទនីយភាពត្រូវបានបញ្ចេញទៅក្នុងទីផ្សារនិងស្រូបយកមកវិញ ទៅតាមការប្រែប្រួលនៃតម្រូវការជាក់ស្តែង ក្នុងគោលដៅធានាឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសន្ទនីយភាពគ្រប់គ្រាន់ សម្រាប់ផ្តល់ឥណទានក្នុងអត្រាការប្រាក់មួយសមរម្យ និងបញ្ចៀសសម្ពាធទៅលើអត្រាប្តូរប្រាក់ ក្នុងស្ថានភាពដែលអត្រាការប្រាក់និងតម្លៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារអន្តរជាតិបាននិងកំពុងមាននិន្នាការកើនឡើង។ ទន្ទឹមនេះ ស្ថិរភាពអត្រាប្តូរប្រាក់ បានរួមចំណែកធ្វើឱ្យអតិផរណានៅក្នុងឆមាសទី១ ថយចុះមកកម្រិតទាបប្រមាណ ១,២% ប៉ុណ្ណោះ។ ការទប់ស្កាត់ការកើនឡើងខ្លាំងនៃអត្រាការប្រាក់ទាំងប្រាក់រៀលនិងដុល្លារអាមេរិកនៅលើទីផ្សារ ការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់និងស្ថិរភាពថ្លៃ និងការគរពូនទុនបម្រុងអន្តរជាតិឱ្យស្ថិតក្នុងកម្រិតមួយសមស្រប បានពង្រឹងជំនឿទុកចិត្តវិនិយោគិននិងសាធារណជនមកលើស្ថិរភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិឱ្យកាន់តែរឹងមាំថែមទៀត។

គួររំលេចថា ភាពប្រសើរឡើងនៃសេដ្ឋកិច្ច គួបផ្សំនឹងប្រសិទ្ធភាពនៃឧបករណ៍នយោបាយរូបិយវត្ថុ និងវិធានការគាំទ្រការប្រើប្រាស់ប្រាក់រៀល បាននាំឱ្យតម្រូវការប្រាក់រៀលកើនឡើង ដូច្នេះ

ធនាគារជាតិនៃកម្ពុជាពុំបានធ្វើអន្តរាគមន៍ទិញ-លក់ប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារ ជាមួយគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់នោះទេ នៅក្នុងឆមាសទី១នេះ។ ប្រសិនបើប្រាក់រៀលត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយ ការអនុវត្តនយោបាយរូបិយវត្ថុនឹងអាចប្រព្រឹត្តទៅដោយប្រសិទ្ធភាពខ្ពស់ក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ចឱ្យកាន់តែរីកលូតលាស់ឡើងថែមទៀត។ ជាមួយភាពប្រសើរជាងមុននៃសកម្មភាពសេដ្ឋកិច្ច អត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រូវបានចាប់ផ្តើមដំឡើងវិញពី ៧% ដល់ ៩% ហើយអត្រានេះនឹងឡើងដល់ ១២,៥% ចាប់ពីឆ្នាំ២០២៤។ ប៉ុន្តែអត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលត្រូវបានរក្សាក្នុងកម្រិត ៧% ដដែល ដើម្បីលើកទឹកចិត្តដល់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែច្រើន។ ទោះយ៉ាងណា ការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធទាំងស្ថាប័នសាធារណៈ ឯកជន និងប្រជាជនទូទៅ នៅតែជាគន្លឹះនៃភាពជោគជ័យ ក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយនៅគ្រប់វិស័យទាំងអស់។

ក្រៅពីការរក្សាបានស្ថិរភាពថ្លៃ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញបទប្បញ្ញត្តិម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្នយ៉ាងយកចិត្តទុកដាក់ សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុនិងគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ ទន្ទឹមនេះ ការត្រួតពិនិត្យប្រព័ន្ធធនាគារផ្អែកលើហានិភ័យនិងទស្សនៈអនាគត និងការធ្វើស្ត្រេសតេស្តលើភាពរឹងមាំនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នឹងត្រូវបន្តធ្វើជាប្រចាំដើម្បីធានាពីភាពរឹងមាំនៃប្រព័ន្ធធនាគារទល់នឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ។ សេវាហិរញ្ញវត្ថុត្រូវបានពង្រីកវិសាលភាពនៅគ្រប់ទីកន្លែងទូទាំងប្រទេស ដែលបានលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ខណៈដែលនិរន្តរភាពនៃការបែងចែកឥណទានទៅកាន់វិស័យនានាបានបន្តគាំទ្រដល់ការវិនិយោគនិងការប្រើប្រាស់។ យ៉ាងណាមិញ កំណើននៃការទទួលបានសេវាហិរញ្ញវត្ថុក៏ភ្ជាប់ជាមួយនូវហានិភ័យផងដែរ ដូចជា បំណុលលើសលប់និងកំណើនឥណទានមិនដំណើរការ ប្រសិនបើការយល់ដឹងពីសេវាហិរញ្ញវត្ថុរបស់ប្រជាជននៅមានកម្រិត។ អាស្រ័យហេតុនេះ ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ និងកិច្ចការពារអតិថិជនត្រូវបាននិងបន្តពង្រឹងជាលំដាប់។

ប្រព័ន្ធទូទាត់កម្ពុជាត្រូវបានបន្តធ្វើទំនើបកម្មផ្អែកលើបច្ចេកវិទ្យាថ្មីៗ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់ ដើម្បីសម្រួលដល់ការដោះដូរទំនិញនិងសេវានៅក្នុងសេដ្ឋកិច្ចឱ្យកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងធ្វើទំនើបកម្មនិងសមាហរណកម្មប្រព័ន្ធទូទាត់ចូលទៅក្នុងតំបន់។ ការទូទាត់ឆ្លងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាមានភាពងាយស្រួល ដែលបានឆ្លើយតបនឹងកំណើនតម្រូវការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ក្នុងយុគសម័យបច្ចេកវិទ្យានិងស្របតាមគន្លងប្រក្រតីថ្មី។ ការតភ្ជាប់ប្រព័ន្ធទូទាត់កម្ពុជាជាមួយប្រទេសផ្សេងទៀតនៅក្នុងតំបន់ក៏ត្រូវបានពង្រឹង និងពង្រីកជាបន្តបន្ទាប់ ដែលបានចូលរួមលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងការបង្វែរប្រាក់ ជាពិសេសពីពលករដែលកំពុងបម្រើការនៅក្រៅប្រទេស។ ក្នុងចំណោមប្រព័ន្ធទូទាត់ទាំងអស់ ប្រព័ន្ធទូទាត់បាគងនិងខេអេចឃ្យូអរ (KHQR) បានបន្តលើកមុខមាត់ប្រព័ន្ធទូទាត់កម្ពុជានៅលើឆាកអន្តរជាតិ ដោយមានធនាគារកណ្តាលមួយចំនួន បានស្នើសុំរៀនសូត្រពីបទពិសោធន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការបង្កើតនិងអភិវឌ្ឍប្រព័ន្ធទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងកាត់បន្ថយចំណាយប្រើប្រាស់។ ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) ដែលជាសមិទ្ធផលថ្មី មួយទៀតសម្រាប់កម្ពុជាត្រូវបាន

អភិវឌ្ឍ ដើម្បីធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយប្រសិទ្ធភាពនិងមានភាពប្រទាក់ក្រឡា ព្រមទាំងជួយសម្រួលដល់ប្រតិបត្តិការទូទាត់សងប្រាក់ និងប្រតិបត្តិការផ្សេងៗជាច្រើនទៀត តាមរយៈប័ណ្ណឥណពន្ធ CSS លើម៉ាស៊ីន ATM ។ ទោះយ៉ាងណា ហានិភ័យក៏អាចកើតមាន ទន្ទឹមនឹងការវិវត្តលឿននៃបច្ចេកវិទ្យា ដូចជាឧក្រិដ្ឋកម្មសាយប័រនិងភាពរអាក់រអួលជាយថាហេតុនៃដំណើរការប្រព័ន្ធទូទាត់ឌីជីថល ដែលអាចប៉ះពាល់ដល់ជំនឿទុកចិត្តមកលើប្រព័ន្ធទូទាត់និងប្រព័ន្ធធនាគារទាំងមូល។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើនការតាមដាននិងការត្រួតពិនិត្យពីដំណើរការប្រព័ន្ធទូទាត់ជាប្រចាំ ដើម្បីធានាស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ និងកាត់បន្ថយហានិភ័យដែលអាចកើតមាន។

ក្រៅពីនេះ ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចពិភពលោកកំពុងប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ធនាគារជាតិនៃកម្ពុជាបានចូលរួមយ៉ាងសកម្ម ក្នុងការគាំទ្រដល់ការពង្រឹងសំណាញ់សុវត្ថិភាព និងសហប្រតិបត្តិការហិរញ្ញវត្ថុតំបន់ ទាំងក្នុងក្របខ័ណ្ឌអាស៊ាននិងអាស៊ាន+៣ ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងស្ថិរភាពហិរញ្ញវត្ថុតំបន់។ ជាមួយគ្នានេះ ក្នុងនាមជាប្រធានប្តូរវេនឆ្នាំ២០២៣ នៃក្រុមប្រឹក្សាភិបាលនៃទេសាភិបាលស៊ាសិន (BOG) ធនាគារជាតិនៃកម្ពុជា បាននិងកំពុងរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពជំនាញ និងការស្រាវជ្រាវរបស់មន្ត្រីធនាគារកណ្តាលដែលជាសមាជិក និងការធានានិរន្តរភាពស្ថាប័នរបស់មជ្ឈមណ្ឌលស៊ាសិន។

ដោយឡែក ការពង្រឹងកាតព្វកិច្ចអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានរួមចំណែកមិនអាចខ្វះបានក្នុងការធានានូវតម្លាភាពនិងចីរភាពនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា។ នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការងារសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិនិងអន្តរជាតិ និងការអនុវត្តផែនការសកម្មភាព ដែលបាននាំទៅដល់ការដកកម្ពុជាចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។

ចំពោះទស្សនវិស័យសម្រាប់ឆ្នាំ២០២៣នេះ សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងបន្តកើនឡើងក្នុងរង្វង់ ៥,៥% ហើយអត្រាអតិផរណាត្រូវបានព្យាករថានឹងថយចុះមកក្នុងរង្វង់ ២% វិញ ដោយសារថ្លៃប្រេងឥន្ធនៈត្រូវបានព្យាករថានឹងថមថយក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកមានកំណើនយឺតជាងឆ្នាំមុន និងភាពប្រសើរឡើងនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល។ យ៉ាងណាមិញ សេដ្ឋកិច្ចតំបន់និងពិភពលោកនៅបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ដូច្នេះ សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យចម្បងៗមួយចំនួន រួមមាន៖ i/-ការកើនឡើងនៃភាពតានតឹងភូមិសាស្ត្រនយោបាយ ទន្ទឹមនឹងការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលអាចទាញកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាឱ្យថយចុះ និងប៉ះពាល់ដល់ការនាំចេញ លំហូរវិនិយោគមកកម្ពុជា និងវិស័យទេសចរណ៍ ii/-ការថយចុះអត្រាអតិផរណានៅប្រទេសអភិវឌ្ឍន៍យឺតជាងការរំពឹងទុកអាចនាំទៅដល់ការបន្តដំឡើងអត្រាការប្រាក់គោល ដែលបង្កជាសម្ពាធមកលើអត្រាការប្រាក់នៅកម្ពុជា ជាពិសេសក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ iii/-ការឡើងថ្លៃប្រាក់ដុល្លារអាមេរិកអាចបណ្តាលឱ្យមានឥទ្ធិពលមកលើស្ថិរភាពអត្រាប្តូរប្រាក់រៀល ព្រមទាំងប៉ះពាល់ដល់ភាពប្រកួតប្រជែងលើការនាំចេញនិងការចំណាយរបស់ទេសចរអន្តរជាតិ iv/-ការអូសបន្លាយនៃ

ការឆ្លងជំងឺកូវីដ-១៩ នៅលើពិភពលោក អាចនាំឱ្យកើតមានវីរុសកូវីដបំប្លែងខ្លួនថ្មី ដែលមានលក្ខណៈឆ្លងរាលដាលខ្លាំងឡើងវិញ v/-ការប្រែប្រួលអាកាសធាតុអាចនាំឱ្យប៉ះពាល់ដល់ផលិតកម្មកសិកម្ម និងបង្កជាសម្ពាធទៅលើថ្លៃក្រុមម្ហូបអាហារ vi/-ការកើនឡើងនៃឧក្រិដ្ឋកម្មសាយប័រ ដែលអាចធ្វើឱ្យរអាក់រអួលដល់ដំណើរការប្រព័ន្ធទូទាត់និងសេដ្ឋកិច្ចទាំងមូល និង vii/-ការកើនឡើងសម្ពាធបំណុលក្រុមគ្រួសារនិងក្រុមហ៊ុន-សហគ្រាស ប្រសិនបើសេដ្ឋកិច្ចកើនឡើងយឺតជាងការរំពឹងទុក ដែលអាចនាំទៅដល់ការធ្លាក់ចុះតម្រូវការប្រើប្រាស់ ការវិនិយោគ និងគុណភាពឥណទាន ជាដើម។

ក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តនយោបាយរូបិយវត្ថុ និងវិធានការម៉ាក្រូ និងមីក្រូប្រុងប្រយ័ត្ន ប្រកបដោយស្មារតីបុរេសកម្ម និងបត់បែនទៅតាមការវិវត្តនៃសេដ្ឋកិច្ច ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃនិងស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។ ស្របតាមការងើបឡើងសន្សឹមៗនៃសេដ្ឋកិច្ច យុទ្ធសាស្ត្រចាកចេញពីវិបត្តិនឹងត្រូវបន្តធ្វើឡើងជាលំដាប់ ដើម្បីពង្រឹងឡើងវិញនូវទ្រនាប់គោលនយោបាយ សម្រាប់ឆ្លើយតបការប៉ះទង្គិចដែលអាចកើតមានជាយថាហេតុនាពេលអនាគត។ សេវាហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់នឹងត្រូវបន្តធ្វើទំនើបកម្ម ទន្ទឹមនឹងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងឌីជីថលដល់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំយន្តការគាំទ្រដើម្បីជំរុញដល់ការផ្តល់ហិរញ្ញប្បទានបៃតង និងប្រកបដោយចីរភាព ដោយក្នុងនោះរួមមាន ការបង្កើតផែនទីចង្អុលផ្លូវ និងវត្ថិករសាស្ត្រនៃហិរញ្ញវត្ថុបៃតងសម្រាប់វិស័យធនាគារ ការគ្រប់គ្រងហានិភ័យបរិស្ថាននិងអភិបាលកិច្ច និងការកសាងសមត្ថភាពនៃភាគីពាក់ព័ន្ធ ជាដើម។ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ាន+៣ នឹងត្រូវបន្តពង្រឹងដើម្បីលើកកម្ពស់សហប្រតិបត្តិការ សមាហរណកម្ម និងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ ដែលនឹងរួមចំណែកបង្កើនភាពធន់នៃសេដ្ឋកិច្ចទល់នឹងវិបត្តិ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាដែលតែងតែផ្តល់ការគាំទ្រ ថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាកសាងប្រព័ន្ធធនាគារឱ្យមានការអភិវឌ្ឍជឿនលឿន និងប្រកបដោយចីរភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ និងភាគីពាក់ព័ន្ធនានានឹងបន្តគាំទ្រ និងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងប្រព័ន្ធធនាគារ ដែលនឹងបម្រើជាប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

ទេសាភិបាល

ជា.ចាន់តូ

# អក្សរកាត់

| | | |
|---|---|---|
| គ.ស.ហ. | គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Coordination Committee on Anti-Money-Laundering and Combating the Financing of Terrorism and Financing of Proliferation of Weapons of Mass Destruction |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ហ.ក | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| អ.វ.ហ | អនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Risk Assessment Sub-Committee for Combating Money Laundering and Countering Financing Terrorism and Financing of Proliferation |
| ABC | សមាគមធនាគារនៅកម្ពុជា | The Association of Banks in Cambodia |
| ACCA | សមាគមគណនេយ្យករជំនាញ | Association Of Certified Chartered Accountants |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | The ASEAN+3 Macroeconomic Research Office |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| Bakong LVPS | ប្រព័ន្ធទូទាត់តម្លៃធំបាគង | Bakong Large Value Payment System |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| BOK-KPP | កម្មវិធីស្រាវជ្រាវរួមគ្នាជាមួយធនាគារកណ្តាលកូរ៉េ | Bank of Korea-Knowledge Partnership Program |
| CBS | មណ្ឌលសិក្សាបច្ចេកទេសធនាគារ | Center for Banking Studies |

| | | |
|---|---|---|
| CFA | ជំនាញវិភាគហិរញ្ញវត្ថុ | Chartered Financial Analyst |
| CIA | ជំនាញសវនកម្មផ្ទៃក្នុង | Certified Internal Audit |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា | Cambodia Microfinance Association |
| CMIM | ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |
| CPA | ជំនាញគណនេយ្យករសាធារណៈ | Certified Public Accountant |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វិច | Cambodian Shared Switch |
| EGMONT | ក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ | Egmont Group of Financial Intelligence Units |
| ENEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ | Export-weighted Nominal Effective Exchange Rate |
| EREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ | Export-weighted Real Effective Exchange Rate |
| FAST | ប្រព័ន្ធសេវាទូទាត់រហ័ស | Fast System |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| FCD | អនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណ | Foreign Currency Deposit |
| FICG | ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | Financial Intelligence Consultative Group |
| FPP | កម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ | Financial Programing and Policies |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| Full KYC | អត្តសញ្ញាណពេញលេញ | Full Know Your Customer |
| FUR | របាយការណ៍វឌ្ឍនភាព | Follow-Up Reports |
| IBF | វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ | Institute of Banking and Finance |
| ICRG-JG | ក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ី-ប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ | International Cooperation Review Group- Joint Group |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ | International Finance Corporation |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| INEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល | Import-weighted Nominal Effective Exchange Rate |

| | | |
|---|---|---|
| IREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល | Import-weighted Real Effective Exchange Rate |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន | Japan International Cooperation Agency |
| LCY | រូបិយវត្ថុក្នុងតំបន់ | Local Currency |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |
| MER | របាយការណ៍វាយតម្លៃអញ្ញមញ្ញ | Mutual Evaluation Report |
| MLF | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី | Marginal Lending Facility |
| NBCP | ផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា | National Bank of Cambodia Platform |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| OBS | ប្រព័ន្ធធនាគារអនឡាញ | Online Banking System |
| POS | ម៉ាស៊ីនឆូតកាត | Point of Sale |
| RBS | ត្រួតពិនិត្យផ្អែកលើហានិភ័យ | Risk Based Supervision |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Asset |
| ROE | អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក | Return on Equity |
| RPPI | សន្ទស្សន៍ថ្លៃលំនៅឋាន | Residential Property Price Indices |
| SEACEN | មជ្ឈមណ្ឌលស៊ាសិន | South East Asian Central Banks |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ | United Nations Development Programme |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក | United Nations Economic and Social Commission for Asia and the Pacific |
| UNEP | កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ | United Nations Environment Programme |
| WB | ធនាគារពិភពលោក | World Bank |

# ខ្លឹមសារសង្ខេប

នៅឆមាសទី១ ឆ្នាំ២០២៣នេះ សេដ្ឋកិច្ចពិភពលោកបានបន្តកើនឡើង ទោះបីជាក្នុងល្បឿនយឺត និងប្រឈមនឹងកម្រិតអតិផរណាខ្ពស់។ មូលនិធិរូបិយវត្ថុអន្តរជាតិបានបន្ទាបការព្យាករកំណើនសេដ្ឋកិច្ចពិភពលោកមកត្រឹម ៣% នៅឆ្នាំ២០២៣ ក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ត្រូវបានព្យាករថានឹងកើនឡើង ១,៥% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍មានកំណើន ៤% និងសេដ្ឋកិច្ចប្រទេសអាស៊ាន-៥ កើនឡើង ៤,៦%។ ទន្ទឹមនេះ អតិផរណាពិភពលោកនៅតែមានកម្រិតខ្ពស់ ដោយត្រូវបានព្យាករថាមានកម្រិត ៦,៨% នៅឆ្នាំ២០២៣នេះ (៨,៧% នៅឆ្នាំមុន)។ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ ធនាគារកណ្តាលភាគច្រើនបានបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិតតាមរយៈការដំឡើងអត្រាការប្រាក់គោល ប៉ុន្តែអាចបង្កជាហានិភ័យដល់ស្ថានភាពបំណុល និងលំហាថវិការបស់ប្រទេសកំពុងអភិវឌ្ឍន៍។

សេដ្ឋកិច្ចកម្ពុជាបានបន្តកើនឡើង គាំទ្រជាចម្បងដោយកំណើនខ្ពស់នៃវិស័យទេសចរណ៍ និងវឌ្ឍនភាពល្អនៃវិស័យកសិកម្ម ស្របពេលដែលវិស័យសំណង់បានបង្ហាញពីសញ្ញាងើបឡើងវិញ ខណៈដែលការនាំចេញផលិតផលសំខាន់ៗបានធ្លាក់ចុះ។ វិស័យទេសចរណ៍មានកំណើនខ្ពស់ជាងការរំពឹងទុក ដោយភ្ញៀវអន្តរជាតិបានកើនឡើងដល់ ២,៦ លាននាក់ និងទេសចរក្នុងស្រុកកើនដល់ប្រមាណ ១១ លាននាក់ ដោយសារការរៀបចំព្រឹត្តិការណ៍ធំៗជាច្រើន ដូចជា ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម បានជួយស្រូបទាញកំណើនទេសចរកាន់តែច្រើន។ វិស័យកសិកម្មក៏មានវឌ្ឍនភាពល្អ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនផលស្រូវ កៅស៊ូ និងអនុវិស័យជលផល។ ទន្ទឹមនេះ វិស័យសំណង់និងអចលនទ្រព្យបានងើបឡើង ប៉ុន្តែក្នុងកម្រិតទាប ដែលគាំទ្រដោយកំណើនលំហូរវិនិយោគបរទេស ជាពិសេស គម្រោងសំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។ ចំណែកឯវិស័យកម្មន្តសាលបានទទួលរងផលប៉ះពាល់ ដោយសារការថយចុះនៃតម្រូវការខាងក្រៅ ជាពិសេសនៅតំបន់អឺរ៉ុបនិងសហរដ្ឋអាមេរិក ដោយសារផលប៉ះពាល់ពីការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងឥទ្ធិពលអវិជ្ជមាននៃការដំឡើងអត្រាការប្រាក់គោល ដើម្បីទប់ទល់នឹងកម្រិតអតិផរណាខ្ពស់។ សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ២២៥ លានដុល្លារអាមេរិក ដែលគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ ស្របពេលដែលឱនភាពគណនីចរន្តនិងដើមទុនបានប្តូរទៅជាអតិរេក ព្រមទាំងបានរួមចំណែករក្សាទុនបម្រុងអន្តរជាតិឱ្យស្ថិតក្នុងកម្រិតខ្ពស់គ្រប់គ្រាន់ ដែលអាចធានាការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បានប្រមាណ ៧ខែ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍គួរមាន (៣ខែ)។

អតិផរណាមាននិន្នាការថយចុះមកត្រឹម ១,២% ទាបជាងឆមាសមុន (៤,១%) និងគ្រាដូចគ្នាឆ្នាំមុន (៦,៦%) ដោយសារការធ្លាក់ថ្លៃប្រេងឥន្ធនៈ និងការថមថយថ្លៃក្រុមម្ហូបអាហារ។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាពក្នុងកម្រិតជាមធ្យម ៤.០៩៤ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានថយថ្លៃត្រឹមតែ ០,២% ធៀបនឹងឆ្នាំមុន (៤.០៨៦ រៀល)។ កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុទូទៅ (M2) បន្តនិន្នាការថយល្បឿនមកត្រឹម ៩,២% ដោយសារកំណើនយឺតនៃប្រាក់បញ្ញើជារូបិយប័ណ្ណនិងប្រាក់បញ្ញើជារៀល ខណៈដែលរូបិយវត្ថុក្នុងចរាចរណ៍បានងើបឡើងវិញ។ ក្នុងពេលដែលអត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលត្រូវបានរក្សាត្រឹម ៧% ដដែល អត្រាប្រាក់បម្រុង

កាតព្វកិច្ចជារូបិយប័ណ្ណត្រូវបានដំឡើងពី ៧% ដល់ ៩% ចាប់ពីដើមឆ្នាំ២០២៣មក ដើម្បីពង្រឹងភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) ទាំងជារៀលបានថយចុះ -១៥,២% មកត្រឹម ៥,៩ ទ្រីលានរៀល និងជាដុល្លារអាមេរិកថយចុះ -៧៤,៨% មកត្រឹម ៨,១ ប៊ីលានដុល្លារអាមេរិក ខណៈដែលការបញ្ចេញសន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) បានកើនឡើង ៨៣,៨% ដល់ប្រមាណ ១,៥ ទ្រីលានរៀល ដែលបានបំពេញតម្រូវការប្រាក់រៀលនៅលើទីផ្សារក្នុងអត្រាការប្រាក់សមរម្យ។ ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) ក៏បានផ្តល់សន្ទនីយភាពចំនួន ២០ ប៊ីលានរៀល ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានតម្រូវការប្រាក់រៀលរយៈពេលខ្លីផងដែរ។ មូលបត្ររដ្ឋត្រូវបានបោះផ្សាយតាមរយៈផ្លេតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) ចំនួន ១១២ ប៊ីលានរៀល នៅលើទីផ្សារដំបូង ដោយមានការចូលរួមជាវពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រព័ន្ធធនាគារបន្តមានភាពរឹងមាំ និងបានរួមចំណែកគាំទ្រការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច។ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានកំណើន ៩,៩% ឥណទានទៅកាន់វិស័យចម្បងៗបានកើនឡើង ១៣,៨% និងប្រាក់បញ្ញើអតិថិជនមានកំណើន ៦,៤%។ ជាមួយគ្នានេះ ស្ថានភាពដើមទុននិងសន្ទនីយភាពរក្សាបានភាពរឹងមាំ ដែលឆ្លុះបញ្ចាំងដោយកម្រិតខ្ពស់នៃអនុបាតសាធនភាព (២៣,៦% សម្រាប់គ្រឹះស្ថានធនាគារ និង ២២,៦% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) និងកម្រិតខ្ពស់នៃអនុបាតគ្របដណ្តប់សន្ទនីយភាព (១៥១,៩% សម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និង ១៨៧,១% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) ស្របពេលដែលអនុបាតឥណទានមិនដំណើរការស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ទោះបីជាបានកើនឡើងបន្តិច (៤% សម្រាប់គ្រឹះស្ថានធនាគារ និង ៣,១% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) ដោយសារការបញ្ចប់វិធានការឥណទានរៀបចំឡើងវិញ និងការថមថយកំណើនឥណទាន។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុជាលំដាប់ ដោយបច្ចុប្បន្ន ចំនួនគណនីប្រាក់បញ្ញើអតិថិជនបានកើនឡើងដល់ ១៦,៥ លានគណនី និងគណនីឥណទានអតិថិជនកើនដល់ ៣,៨ លានគណនី។ ធនាគារជាតិនៃកម្ពុជាបានពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាប្រចាំ តាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ជាមួយនឹងការអនុវត្តយុទ្ធសាស្ត្រចាកចេញពីវិបត្តិជាជំហានៗ ដើម្បីពង្រឹងភាពធន់នៃប្រព័ន្ធធនាគារនិងរក្សាស្ថិរភាពហិរញ្ញវត្ថុ។

នវានុវត្តន៍ប្រព័ន្ធទូទាត់សងប្រាក់បាននិងកំពុងរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយបានលើកកម្ពស់ការទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ។ ប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធសេវាទូទាត់រហ័ស និងប្រព័ន្ធខេមបូឌានស៊ែស្វីច ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងបន្ថែមមុខងារចាំបាច់មួយចំនួន ក្នុងគោល-បំណងសម្រួលដល់គ្រឹះស្ថានជាសមាជិក និងអ្នកប្រើប្រាស់ ក៏ដូចជាឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ប្រព័ន្ធបាគង ដែលជាប្រព័ន្ធទូទាត់កន្លោង មានសមាជិកសរុបចំនួន ៧០ ក្នុងនោះ គ្រឹះស្ថានចំនួន ៤៨ បានដាក់ឱ្យដំណើរការជាផ្លូវការ និងមានអតិថិជនចុះឈ្មោះប្រើប្រាស់តាមរយៈកម្មវិធីបាគងចំនួន ៥៥០ ពាន់គណនី ស្របពេលដែលចំនួនគណនីអ៊ីវ៉ាឡេតបានកើនដល់ ២០,២ លានគណនី។ ប្រតិបត្តិការទូទាត់សងប្រាក់បន្តកើនឡើងជាលំដាប់ដល់ប្រមាណ ៨៩,៧ ប៊ីលានដុល្លារអាមេរិក ស្មើនឹងជាង ៣ដងនៃផ.ស.ស ដែលមានចំនួនប្រតិបត្តិការប្រមាណ ៣០,៣ លានប្រតិបត្តិការ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាមួយប្រទេសក្នុងតំបន់ ដូចជា ប្រទេសថៃ ម៉ាឡេស៊ី ឡាវ និងប្រទេសវៀតណាម ដើម្បីសម្រួលដល់ការទូទាត់ឆ្លងដែនឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងបានពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ជាមួយប្រទេសហ្វីជី សូឡូម៉ូន និងប្រទេសវ៉ាន់ដា ដើម្បីចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងនវានុវត្តន៍ និងការទូទាត់តាមបែបឌីជីថលសម្រាប់សេវាកម្មហិរញ្ញវត្ថុ។

ស្របពេលដែលភាពរីកចម្រើននៃមធ្យោបាយទូទាត់ឌីជីថលកាន់តែសម្បូរបែប ការចរាចរសាច់ប្រាក់ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព ដើម្បីបំពេញតម្រូវការរបស់សាធារណជននៅទូទាំងប្រទេស ជាមួយនឹងការលើកកម្ពស់គុណភាពនិងសោភ័ណភាពក្រដាសប្រាក់រៀល។ យុទ្ធនាការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ក៏ត្រូវបានរៀបចំឡើង ដែលបានបង្កើនចំណេះដឹងរបស់ប្រជាជនអំពីអត្ថប្រយោជន៍នៃរូបិយវត្ថុជាតិ ព្រមទាំងបំផុសស្មារតីយុវជនឱ្យស្រឡាញ់និងប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយ។ ការងារសវនកម្មនិងអធិការកិច្ចត្រូវបានធ្វើឡើងជាប្រចាំ ដោយបានលើកកម្ពស់អភិបាលកិច្ចល្អ គុណភាពសេវាធនាគារកណ្តាល និងការគ្រប់គ្រងហានិភ័យនានា។ លើសពីនេះ ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សត្រូវបានយកចិត្តទុកដាក់អនុវត្ត តាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស និងការសិក្សាតាមប្រព័ន្ធអនឡាញ ដែលបានពង្រឹងគុណវុឌ្ឍិរបស់មន្ត្រីបុគ្គលិក និងប្រសិទ្ធភាពការងារ។

ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានរួមចំណែកដ៏សំខាន់ក្នុងការអនុវត្តផែនការសកម្មភាព និងសហការការងារជាមួយក្រសួង-ស្ថាប័ននានា និងវិស័យឯកជន ដោយទទួលបានជោគជ័យក្នុងការដកកម្ពុជាចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។ ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មត្រូវបានបន្តអនុវត្តយ៉ាងសកម្ម តាមរយៈការត្រួតពិនិត្យនិងតាមដានការអនុវត្តច្បាប់និងបទប្បញ្ញត្តិរបស់បុគ្គលរាយការណ៍ ការវិភាគនិងបញ្ជូនរបាយការណ៍ទៅអាជ្ញាធរអនុវត្តច្បាប់ និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងក្នុងស្រុកនិងអន្តរជាតិ។

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ក្នុងការពង្រឹងនិងពង្រីកចំណងកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថាប័នអន្តរជាតិនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី ដើម្បីចូលរួមជំរុញសមាហរណកម្មទាំងក្នុងតំបន់និងពិភពលោក ពង្រីកចំណេះដឹងនិងបទពិសោធន៍ការងារ និងកសាងសមត្ថភាពមន្ត្រី-បុគ្គលិក ស្របតាមតម្រូវការការងារ និងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ផ្នែកទី១- របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២៣

## I- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

### ១. ស្ថានភាពសេដ្ឋកិច្ចពិភពលោក

ទោះបីជាប្រទេសជាច្រើនបានបើកដំណើរការសេដ្ឋកិច្ចស្ទើរតែទាំងស្រុង ពិភពលោកនៅតែប្រឈមនឹងកំណើនទាបនិងអតិផរណាខ្ពស់ ដែលជាចម្បងបណ្តាលមកពីការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត។ ការថមថយនៃសកម្មភាពសេដ្ឋកិច្ចក៏បានធ្វើឱ្យថ្លៃប្រេងនៅធ្លាក់ចុះដែលជាហេតុធ្វើឱ្យអង្គការ OPEC កាត់បន្ថយការផលិតប្រេង។ ជាមួយគ្នានេះ កម្រិតបំណុលសាធារណៈខ្ពស់[១]នៅតែជាបញ្ហាប្រឈមសម្រាប់បណ្តាប្រទេសនានា។

ការអនុវត្តនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលដើរតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាស្ថិរភាពថ្លៃ និងកាត់បន្ថយហានិភ័យក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ។ ដើម្បីបន្ថយសំពាធអតិផរណា ធនាគារកណ្តាលភាគច្រើននៅតែបន្តដំឡើងអត្រាការប្រាក់គោល ប៉ុន្តែក្នុងល្បឿនយឺតជាងមុន ជាពិសេសបន្ទាប់ពីមានការក្ស័យធននៃធនាគារ Silicon Valley របស់សហរដ្ឋអាមេរិក[២]។ កម្រិតខ្ពស់នៃអតិផរណា និងការកើនឡើងនៃអត្រាការប្រាក់គោលជាកត្តាជំរុញឱ្យថ្លៃដើមឥណទានកើនឡើង ដែលបង្កជាហានិភ័យដល់ស្ថានភាពបំណុល និងប៉ះពាល់ដល់លំហថវិកា (Fiscal space) របស់ប្រទេសកំពុងអភិវឌ្ឍន៍[៣]។

**ក្រាហ្វ ១៖ កំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់**

(គិតជាភាគរយ, ឆ្នាំ២០២១ - ២០២៣ព)




ប្រភព៖ WEO - IMF, ខែកក្កដា ឆ្នាំ២០២៣, *ប=ប៉ាន់ស្មាន, *ព=ព្យាករណ៍

**ក្រាហ្វ ២៖ តម្លៃប្រេងនៅពិភពលោក**

(គិតជាដុល្លារអាមេរិកក្នុង១បារ៉ែល, ខែមករា ឆ្នាំ២០២១ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ Energy Information Administration (EIA) និងគេហទំព័រ fred.stlouisfed.org

**ក្រាហ្វ ៣៖ កម្រិតអតិផរណា**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ គេហទំព័រ Tradingeconomics.com

---

[១] សហរដ្ឋអាមេរិកកំពុងពិនិត្យលើការដំឡើងពិដានបំណុលសាធារណៈ ស្របពេលដែលនាយកដ្ឋានរតនាគារបានលើកឡើងថា សហរដ្ឋអាមេរិកមិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុបាន ដែលការណ៍នេះអាចជះឥទ្ធិពលដល់ទីផ្សារហិរញ្ញវត្ថុសកលផងដែរ។

[២] កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ធនាគារ Silicon Valley (SVB) របស់សហរដ្ឋអាមេរិក បានដួលរលំ ដោយសារការសម្រុកដកប្រាក់បញ្ញើ និងវិបត្តិដើមទុន។

[៣] ប្រភព៖ របាយការណ៍ស្ថានភាពសេដ្ឋកិច្ចពិភពលោកនិងទស្សនវិស័យរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣។

ធនាគារកណ្តាលប្រទេសអភិវឌ្ឍន៍ភាគច្រើន បានបន្តដំឡើងអត្រាការប្រាក់គោល ក្នុងនោះ រួមមាន ធនាគារកណ្តាលអាមេរិក[១] ធនាគារកណ្តាលអង់គ្លេស[២] ធនាគារកណ្តាលកាណាដា[៣] ធនាគារកណ្តាលអូស្ត្រាលី[៤] និងធនាគារកណ្តាលអឺរ៉ុប[៥]។ ដោយឡែក ធនាគារកណ្តាលជប៉ុន[៦]បានសម្រេចរក្សាអត្រាការប្រាក់គោល និងបន្តទិញសញ្ញាប័ណ្ណរយៈពេលវែងរបស់រដ្ឋាភិបាល។

សម្រាប់ប្រទេសកំពុងលូតលាស់និងក្នុងតំបន់ ធនាគារកណ្តាលចិន[៧] និងធនាគារកណ្តាលឥណ្ឌូណេស៊ី[៨] បន្តរក្សាអត្រាការប្រាក់គោល ខណៈដែលធនាគារកណ្តាលនៃប្រទេសផ្សេងទៀតបានដំឡើងអត្រាការប្រាក់គោល[៩] មានដូចជា ធនាគារកណ្តាលឥណ្ឌា ធនាគារកណ្តាលម៉ាឡេស៊ី ធនាគារកណ្តាលថៃ និងធនាគារកណ្តាលហ្វីលីពីន។ ចំណែកឯ ធនាគារកណ្តាលវៀតណាម[១០]បានបន្ថយអត្រាការប្រាក់គោលពីរដង ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បន្ទាប់ពីបានដំឡើងកាលពីខែវិច្ឆិកា ឆ្នាំ២០២២។

**ក្រាហ្វ ៤៖ អត្រាការប្រាក់គោលនៃប្រទេសអភិវឌ្ឍន៍**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២០ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ គេហទំព័រ Tradingeconomics.com

**ក្រាហ្វ ៥៖ អត្រាការប្រាក់គោលនៃប្រទេសកំពុងលូតលាស់ និងក្នុងតំបន់**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២០ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ គេហទំព័រ Tradingeconomics.com

---

[១] ក្នុងឆមាសទី១ ឆ្នាំ២០២៣ ធនាគារកណ្តាលអាមេរិកបានសម្រេចដំឡើងអត្រាការប្រាក់គោលលើកទី១នៅខែកុម្ភៈ ដល់ ៤,៧៥% លើកទី២ នៅខែមីនា ដល់ ៥% និងលើកទី៣នៅខែមិថុនា ដល់ ៥,២៥%។

[២] ធនាគារកណ្តាលអង់គ្លេសបានដំឡើងអត្រាការប្រាក់គោលលើកទី១ នៅខែកុម្ភៈ ដល់ ៤% លើកទី២ នៅខែមីនា ដល់ ៤,២៥% លើកទី៣ នៅខែឧសភា ដល់ ៤,៥% និងលើកទី៤ ខែមិថុនា ដល់ ៥%។

[៣] ធនាគារកណ្តាលកាណាដាបានសម្រេចដំឡើងអត្រាការប្រាក់គោល លើកទី១ នៅខែមករា ដល់ ៥%។

[៤] ធនាគារកណ្តាលអូស្ត្រាលីបានដំឡើងអត្រាការប្រាក់គោល លើកទី១ នៅខែកុម្ភៈ ដល់ ៣,៣៥% លើកទី២ នៅខែមីនា ដល់ ៣,៦% និងលើកទី៣ នៅខែឧសភា ដល់ ៣,៨៥%។

[៥] ធនាគារកណ្តាលអឺរ៉ុបបានដំឡើងអត្រាការប្រាក់គោល លើកទី១ នៅខែកុម្ភៈ ដល់ ៣% លើកទី២ នៅខែមីនា ដល់ ៣,៥% លើកទី៣ នៅខែឧសភា ដល់ ៣,៧៥% និងលើកទី៤ នៅខែមិថុនា ៤%។

[៦] ធនាគារកណ្តាលជប៉ុនបានរក្សាអត្រាការប្រាក់គោលត្រឹម -0,1%។

[៧] ធនាគារកណ្តាលចិនបានកាត់បន្ថយអត្រាការប្រាក់គោលពី ៣,៨% មក ៣,៧% ក្នុងខែមករា ឆ្នាំ២០២២ បន្តកាត់បន្ថយមកនៅ ៣,៦៥ ខែមិថុនា និងបន្តកាត់បន្ថយមក ៣,៥៥% ក្នុងខែមិថុនា ឆ្នាំ២០២២។

[៨] ធនាគារកណ្តាលឥណ្ឌូណេស៊ីបានដំឡើងអត្រាការប្រាក់គោលពី ៥,២៥% ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ ៥,៧៥% ក្នុងខែមករា ឆ្នាំ២០២៣។

[៩] ធនាគារកណ្តាលឥណ្ឌាបានដំឡើងអត្រាការប្រាក់គោលដល់ ៦,៥% ធនាគារកណ្តាលម៉ាឡេស៊ី ៣% ធនាគារកណ្តាលថៃ ២% និងធនាគារកណ្តាលហ្វីលីពីន ៦,២៥%។

[១០] ធនាគារកណ្តាលវៀតណាមបានបន្ថយអត្រាការប្រាក់គោលត្រឹម ៤,៥%។

## ២- កំណើនសេដ្ឋកិច្ចក្នុងស្រុក

ក្នុងឆមាសទី១ ឆ្នាំ២០២៣នេះ សេដ្ឋកិច្ចកម្ពុជាបន្តមានវឌ្ឍនភាពល្អ ដែលគាំទ្រដោយចម្បងដោយកំណើនខ្ពស់នៃវិស័យទេសចរណ៍ និងវឌ្ឍនភាពល្អនៃវិស័យកសិកម្ម ស្របពេលដែលវិស័យសំណង់ហាក់បានបង្ហាញពីសញ្ញាងើបឡើងវិញ ខណៈដែលការនាំចេញក្នុងវិស័យកាត់ដេរ ស្បែកជើងនិងផលិតផលធ្វើដំណើរទៅកាន់ប្រទេសដៃគូសំខាន់ៗបានធ្លាក់ចុះ ដោយសារតែសេដ្ឋកិច្ចប្រទេសទាំងនោះទទួលរងផលប៉ះពាល់ពីការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងឥទ្ធិពលអវិជ្ជមាននៃការដំឡើងអត្រាការប្រាក់គោលដើម្បីទប់ទល់នឹងកំណើនអតិផរណា។

**វិស័យកម្មន្តសាល**[១៤]**៖** វិស័យកម្មន្តសាលបានទទួលរងផលប៉ះពាល់ ដោយសារការថយចុះនៃតម្រូវការខាងក្រៅ ជាពិសេស សហរដ្ឋអាមេរិក និងអឺរ៉ុប។ តម្លៃផលិតផលកម្មន្តសាលសរុប[១៥] ថយចុះ -១៦,១% (ឆ្នាំលើឆ្នាំ) ដែលក្នុងនោះ ផលិតផលកម្មន្តសាលសម្រាប់នាំចេញថយចុះ -១៩,៨%[១៦] ស្របពេលដែលផលិតផលកម្មន្តសាលបម្រើទីផ្សារក្នុងស្រុកថយចុះ -៧,៨%។

**ក្រាហ្វ ៦៖ តម្លៃផលិតផលសរុប**

(ឆមាសទី១ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ទោះយ៉ាងនេះក្តី ចំនួនរោងចក្រសរុប[១៧] បានកើនឡើងបន្តិចដល់ ១.៩៩៥ រោងចក្រ ធៀបនឹង ១.៩៨២ រោងចក្រ នៅចុងឆ្នាំ២០២២ ដែលបានផ្តល់ការងារដល់កម្មករសរុបប្រមាណ ១ លាននាក់។

**ក្រាហ្វ ៧៖ ចំនួនរោងចក្រសរុប**

(ឆមាសទី១ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

---

[១៤] ទិន្នន័យគ្របដណ្តប់សហគ្រាសធុនធំ ក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

[១៥] ទិន្នន័យប៉ាន់ស្មានសម្រាប់ខែមេសា-ខែមិថុនា ឆ្នាំ២០២៣។

[១៦] ផលិតផលកាត់ដេរនិងស្បែកជើង ដែលមានសមាមាត្រស្មើនឹងប្រមាណ ៩៣,៣% នៃកម្មន្តសាលនាំចេញសរុបបានថយចុះប្រមាណ -១៦% ស្របពេលដែលកម្មន្តសាលនាំចេញផ្សេងៗទៀតថយចុះប្រមាណ -២៦%។

[១៧] ទិន្នន័យប៉ាន់ស្មានសម្រាប់ខែឧសភា និងខែមិថុនា ឆ្នាំ២០២៣។

**វិស័យទេសចរណ៍៖** វិស័យទេសចរណ៍មានកំណើនខ្ពស់ជាងការរំពឹងទុក ដោយក្នុងឆមាសទី១ ឆ្នាំ២០២៣នេះ ប្រទេសកម្ពុជាបានរៀបចំព្រឹត្តិការណ៍ធំៗជាច្រើន ដូចជា ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ដែលព្រឹត្តិការណ៍ទាំងនេះបានជួយស្រូបទាញកំណើនទេសចរអន្តរជាតិចូលមកប្រទេសកម្ពុជាកាន់តែច្រើនជាងមុន។ ភ្ញៀវអន្តរជាតិកើនឡើងដល់ប្រមាណ ២,៦ លាននាក់ (កើន ៥,១ ដងឆ្នាំលើឆ្នាំ) ដោយភ្ញៀវថៃបន្តឈរនៅលំដាប់ទី១នៃភ្ញៀវអន្តរជាតិដែលមកកម្សាន្តនៅប្រទេសកម្ពុជា (សមាមាត្រ ៣៤%) បន្ទាប់មកភ្ញៀវវៀតណាម (១៨%) និងចិន (១០%)។

ទន្ទឹមនេះ ទេសចរក្នុងស្រុកបន្តកើនឡើងគួរឱ្យកត់សម្គាល់ ដល់ប្រមាណ ១១ លាននាក់ (កើន ៧៣,២% ឆ្នាំលើឆ្នាំ)។ ការកើនឡើងនេះដោយសារទេសចរក្នុងស្រុកបានធ្វើដំណើរកម្សាន្តទៅរមណីយដ្ឋាននិងកន្លែងកម្សាន្តនានាក្នុងឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ។ តំបន់ឆ្នេរទទួលទេសចរច្រើនជាងគេ ដែលមានសមាមាត្រ ៤៦% (កើន ៨១,១%) នៃទេសចរក្នុងស្រុកសរុប ខណៈខេត្តសៀមរាបឈរនៅលំដាប់ទី២ (សមាមាត្រ ២៥%) រាជធានីភ្នំពេញឈរលំដាប់ទី៣ (១៧%) និងតំបន់អេកូទេសចរណ៍ឈរលំដាប់ទី៤ (៤%)។

**ក្រាហ្វ ៨ ៖ ភ្ញៀវអន្តរជាតិ**

(ឆមាសទី១ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភពៈ ក្រសួងទេសចរណ៍

**ក្រាហ្វ ៩ ៖ ទេសចរក្នុងស្រុក**

(ឆមាសទី១ ឆ្នាំ២០២១ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភពៈ ក្រសួងទេសចរណ៍

**វិស័យកសិកម្ម៖** វិស័យកសិកម្មបន្តមានវឌ្ឍនភាពល្អ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនដំណាំស្រូវនិងកៅស៊ូ និងអនុវិស័យជលផល។ ផលស្រូវរដូវប្រាំងសម្រេចបានកំណើនខ្ពស់ប្រមាណ ១៣% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (០,២% ឆ្នាំមុន) ដល់ប្រមាណ ៣,៣ លានតោន ស្របពេលដែលផ្ទៃដីដាំដុះស្រូវរដូវវស្សាបានកើន ១៨,៧% (ឆ្នាំលើឆ្នាំ) ដោយសារកត្តាអំណោយផលពីអាកាសធាតុ ដែលបានផ្តល់ទឹកគ្រប់គ្រាន់សម្រាប់កសិករបង្កបង្កើនផល[១៨]។

ផលកៅស៊ូមានកំណើនទាប ០,១% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (២,៣%) ខណៈដែលតម្លៃកៅស៊ូជាមធ្យមក្នុងមួយតោនបានបង្ហាញពីនិន្នាការធ្លាក់ចុះចាប់ពីដើមឆ្នាំ២០២១ និងបានធ្លាក់ចុះ -១៥,៨% (គ្រាដូចគ្នាឆ្នាំមុន -៥,៨%) ដោយសារការថយចុះនៃតម្រូវការខាងក្រៅ។

អនុវិស័យជលផលបានបន្តមានកំណើនល្អ ៨,៩% ដោយក្នុងនោះ ផលនេសាទទឹកសាបនិងសមុទ្រ និងផលវារីវប្បកម្ម (ចិញ្ចឹមត្រីនិងបង្គា) បានកើន ៥,១% ៣៩,១% និង ២,៩% រៀងគ្នា ជាចម្បងដោយសារកំណើនតម្រូវការក្នុងស្រុកគួបផ្សំនឹងវិធានការរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់បទល្មើសនេសាទខុសច្បាប់។

**ក្រាហ្វ ១០ ៖ ផលស្រូវ**

(ឆមាសទី១ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**ក្រាហ្វ ១១ ៖ ផលនិងតម្លៃកៅស៊ូ**

(ឆមាសទី១ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ក្រាហ្វ ១២ ៖ សកម្មភាពវារីវប្បកម្ម**

(ឆមាសទី១ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

[១៨] ផលិតកម្មស្រូវរដូវប្រាំងបានចាប់ផ្តើមដាំពីខែវិច្ឆិកាហើយបញ្ចប់ប្រមូលផលនៅខែមេសា ខណៈស្រូវរដូវវស្សាចាប់ផ្តើមពីខែឧសភាហើយបញ្ចប់ នៅខែធ្នូ។

**វិស័យសំណង់ និងអចលនទ្រព្យ៖** វិស័យសំណង់បានងើបឡើងមកវិញ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់ (០,៤%)។ ចំពោះគម្រោងសាងសង់ដែលទទួលបានការអនុម័ត[១៩] តម្លៃនិងផ្ទៃក្រឡាគម្រោងសាងសង់ ត្រូវបានប៉ាន់ស្មានថាមានកំណើន ១,៣ ដង (ឆ្នាំលើឆ្នាំ) ខណៈចំនួនគម្រោងបានថយចុះ -៩%។

នៅក្នុងវិស័យអចលនទ្រព្យ សន្ទស្សន៍ថ្លៃលំនៅឋាន[២០] (RPPI) បានបង្ហាញថា តម្លៃលំនៅឋាននៅកម្ពុជាពុំសូវមានភាពប្រែប្រួលខ្លាំងនោះទេ។ តម្លៃលំនៅឋាននៅរាជធានីភ្នំពេញបានកើនឡើង ៦,៩% (ឆ្នាំលើឆ្នាំ) ស្របពេលដែលតម្លៃលំនៅឋាននៅតាមបណ្ដាខេត្តផ្សេងៗកើនឡើង ៥,៣%។

ចំពោះសកម្មភាពលក់លំនៅឋាន[២១] (ផ្ទះល្វែង វីឡាភ្លោះនិងទោល) ថយចុះប្រមាណ -៦៤,៧% ខណៈការលក់ខុនដូមានកំណើនវិជ្ជមានឡើងវិញក្នុងអត្រា ១២,៩%។

**ក្រាហ្វ ១៣៖ តម្លៃនិងកំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់**

(ឆមាសទី១ ឆ្នាំ២០២១ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៤៖ ចំនួននិងតម្លៃគម្រោងសំណង់**

(ឆមាសទី១ ឆ្នាំ២០២១ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, *ប=ប៉ាន់ស្មាន

**ក្រាហ្វ ១៥៖ សន្ទស្សន៍ថ្លៃលំនៅឋានកម្ពុជា (RPPI)**

(បម្រែបម្រួល គិតជាភាគរយ, ខែមករា ឆ្នាំ២០២១ - ខែឧសភា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១៩] អនុម័តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[២០] ទិន្នន័យត្រឹមខែឧសភា ឆ្នាំ២០២៣

[២១] និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ៣- ស្ថានភាពអតិផរណា

អតិផរណាបន្តនិន្នាការថយចុះនៅ ឆមាស-ទី១នេះ ជាចម្បងបណ្តាលមកពីការថយថ្លៃប្រេង និងការថយល្បឿននៃការឡើងថ្លៃម្ហូបអាហារ ស្របពេលដែលអតិផរណាស្នូលមានកម្រិតទាប។ អតិផរណារួមជាមធ្យមមានកម្រិត ១,២% ទាបជាង ឆមាសទី២ ឆ្នាំ២០២២ (៤,១%) និងឆមាសទី១ ឆ្នាំ២០២២ (៦,៦%)។

ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានថយចុះ -៦,៣% នៅឆមាសនេះ[២២] (៣,៨% នៅឆមាសទី២ ឆ្នាំ២០២២ និង ១៨,៤% នៅឆមាសទី១ ឆ្នាំ២០២២) ស្របតាមនិន្នាការថមថយនៃថ្លៃប្រេងនៅពិភពលោក។ កំណើនថ្លៃក្រុមម្ហូបអាហារបានបន្តថយល្បឿនមក ២,៦% (៤,៣% នៅឆមាសទី២ ឆ្នាំ២០២២ និង ៥,៦% នៅឆមាសទី១ ឆ្នាំ២០២២) ដែលជាចម្បងបណ្តាលមកពីភាពប្រសើរឡើងនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល ដែលនាំឱ្យមានការថមថយថ្លៃដើមផលិត ដូចជា ជីកសិកម្ម ថ្នាំសម្លាប់សត្វល្អិតនិងស្មៅ និងប្រេងឥន្ធនៈ។ អតិផរណាស្នូលបានបន្តនិន្នាការថយល្បឿនមក ១,៥% (៣,៨% នៅឆមាសទី២ ឆ្នាំ២០២២ និង ៥% នៅឆមាសទី១ ឆ្នាំ២០២២) ដែលជាចម្បងបណ្តាលមកពីមូលដ្ឋានខ្ពស់ស្រាប់នៅគ្រាដូចគ្នាឆ្នាំមុន គួបផ្សំនឹងឥទ្ធិពលពីការថមថយថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈ។

**ក្រាហ្វ ១៧៖ អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៨ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៨៖ អតិផរណាក្រុមសំខាន់ៗទាំងបី**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៨ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

[២២] ថ្លៃសាំងកម្ពុជាបានថយចុះមកប្រមាណ ៤.២៣៥រៀល (៤.៩៩៤រៀល ក្នុង១លីត្រ នៅឆមាសទី២ ឆ្នាំ២០២២ និង ៥.០២២រៀល ក្នុង១លីត្រ នៅឆមាសទី១ ឆ្នាំ២០២២)។

### -អតិផរណាព្យាករណ៍

អតិផរណានៅឆមាសទី២ អាចប្រឈមនឹងភាពមិនច្បាស់លាស់ ដោយសារស្ថានភាពសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងស្ថានភាពសេដ្ឋកិច្ចពិភពលោក។ អតិផរណាក្នុងឆមាសទី២ ឆ្នាំ២០២៣ ត្រូវបានព្យាករ[២៣]ថាមានកម្រិតជាមធ្យមប្រមាណ ២,៧% (១,២% នៅឆមាសទី១) ហើយអតិផរណាសម្រាប់ឆ្នាំ២០២៣ អាចមានកម្រិតជាមធ្យមប្រមាណ ២%។ ការព្យាករនេះត្រូវបានធ្វើឡើងក្រោមការសន្មតដូចខាងក្រោម៖

**ក្រាហ្វ ១៩៖ អតិផរណាព្យាករណ៍**

(ឆ្នាំលើឆ្នាំ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី២ ឆ្នាំ២០២៣ព)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ព=ព្យាករណ៍

i/-ការថយថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ -0,៣%[២៤] (-៦,៣% នៅឆមាសទី១) ដោយសារការរំពឹងពីការថមថយកំណើនសេដ្ឋកិច្ចពិភពលោក ដែលធ្វើឱ្យតម្រូវការប្រេងថយចុះ បើទោះជាថ្លៃប្រេងនៅពិភពលោកត្រូវបានព្យាករថានឹងកើនឡើងជាបន្តបន្ទាប់ចាប់ពីខែកក្កដាដល់ខែកញ្ញា មុននឹងថមថយមកវិញចាប់ពីខែតុលា ក្នុងបរិការណ៍ដែល OPEC និងបណ្តាប្រទេសដៃគូ (OPEC+) បានប្រកាសកាត់បន្ថយការផលិតប្រេងនៅចំនួន ១,២ លានបារ៉ែលក្នុងមួយថ្ងៃ នៅដើមខែមេសា រហូតដល់ចុងឆ្នាំ ២០២៣។

ii/-កំណើនថ្លៃម្ហូបអាហារបន្តមានកម្រិតទាប ប៉ុន្តែកើនមកវិញបន្តិច ៣,២% (២,៦% នៅឆមាសទី១) ដោយសារភាពប្រសើរឡើងនៃវិស័យកសិកម្ម គួបផ្សំនឹងមូលដ្ឋានខ្ពស់ស្រាប់កាលពីគ្រាដូចគ្នាឆ្នាំមុន និង

iii/-អតិផរណាស្នូលអាចនឹងកើនឡើងមកវិញបន្តិចផងដែរ ប៉ុន្តែបន្តមានកម្រិតទាប ២,៧% (១,៥% នៅឆមាសទី១) ដោយសារកំណើនតម្រូវការ គួបផ្សំនឹងឥទ្ធិពលនៃការកើនឡើងថ្លៃម្ហូបអាហារ។

---

[២៣] ការព្យាករត្រូវបានធ្វើឡើងដោយប្រើម៉ូឌែល i/-Multiple regression ដែលសិក្សាពីទំនាក់ទំនងរវាងអតិផរណា និងសូចនាករសំខាន់មួយចំនួន រួមមាន អតិផរណានៅឆមាសមុន អតិផរណាដៃគូនាំចូល បម្រែបម្រួលថ្លៃប្រេងឥន្ធនៈពិភពលោក កំណើនឥណទាន និងបម្រែបម្រួលអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ii/-ARIMA(p,d,q) ដែលធ្វើការព្យាករក្រុមទាំង ១២ នៅក្នុងកន្ត្រកទំនិញប្រើប្រាស់ ដោយផ្អែកលើតម្លៃគ្រាមុននិងគម្លងរបស់អថេរទាំងនោះ iii/-VARX ដែលមានអត្រាអតិផរណា កំណើនឥណទាន បម្រែបម្រួលអត្រាប្តូរប្រាក់ អតិផរណាដៃគូនាំចូល និងដាក់ថ្លៃប្រេងជា exogenous variables iv/-ARIMA (៣,១,៣) ដែលប្រើប្រាស់អត្រាអតិផរណាគ្រាមុនៗចំនួន ៣ ឆមាស និង v/-VARX ដែលព្យាករអតិផរណាស្នូល អតិផរណាក្រុមម្ហូបអាហារ និងអតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។

[២៤] ថ្លៃសាំងកម្ពុជាជាមធ្យម អាចថយចុះបន្តិចមកប្រមាណ ៤.១៨០រៀល នៅឆមាសទី២ ឆ្នាំ២០២៣ (៤.២៣៥រៀល ក្នុង១លីត្រ នៅឆមាសទី១ ឆ្នាំ២០២៣)។

## ៤- អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក នៅឆមាសទី១នេះ បន្តមានស្ថិរភាព ប៉ុន្តែមានកម្រិតខ្ពស់បន្តិចធៀបនឹងគ្រាមុនវិបត្តិកូវីដ-១៩ ដោយសារប្រាក់រៀលបន្តរងសម្ពាធពីការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក បន្ទាប់ពីមានការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិកជាបន្តបន្ទាប់ ទោះបីជាតម្រូវការប្រាក់រៀលមានការកើនឡើង នៅពេលសកម្មភាពសេដ្ឋកិច្ចងើបឡើងវិញក៏ដោយ។

**ក្រាហ្វ ១៩៖ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**

(គិតជារៀលក្នុងមួយដុល្លារអាមេរិក, ឆ្នាំ២០១៦ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានកម្រិតជាមធ្យម ៤.០៩៤ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានថយថ្លៃ ០,២% ធៀបនឹងឆ្នាំមុន (៤.០៨៦ រៀល) និង ១,៤% ធៀបនឹងគ្រាមុនវិបត្តិ (២០១៨-២០១៩)។ ទន្ទឹមនេះ សន្ទស្សន៍ប្រាក់ដុល្លារអាមេរិកជាមធ្យមមានកម្រិត ១១៦ ដោយបានកើនឡើង ២,៩% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ហើយរូបិយប័ណ្ណប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាបន្តថយថ្លៃធៀបនឹងដុល្លារអាមេរិក។

**ក្រាហ្វ ២០ ៖ សន្ទស្សន៍ប្រាក់ដុល្លារអាមេរិក**

(មករា ឆ្នាំ២០១៨=១០០, ខែមករា ឆ្នាំ២០២១ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចាប់ពីខែសីហា ឆ្នាំ២០២២ អត្រាប្តូរប្រាក់ផ្លូវការដែលបានចេញដោយធនាគារជាតិនៃកម្ពុជាត្រូវបានគណនាចេញពីអត្រាប្តូរប្រាក់ជាក់ស្តែងដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រើប្រាស់ក្នុងការជួញដូរនៅលើផ្លែតហ្វម NBCP ប្រចាំថ្ងៃ។ ដូច្នេះ អត្រាប្តូរប្រាក់មានកម្រិតស្មើនឹងអត្រាទីផ្សារ ដែលធ្វើឱ្យអត្រាផ្លូវការឆ្លុះបញ្ចាំងពីស្ថានភាពទីផ្សារប្តូរប្រាក់បានកាន់តែប្រសើរនិងមានប្រសិទ្ធភាព។ អត្រាប្តូរប្រាក់ផ្លូវការត្រូវបានផ្សព្វផ្សាយរៀងរាល់ថ្ងៃចុងប្រតិបត្តិការនិងនាពេលព្រឹកនៅថ្ងៃបន្ទាប់។ នៅឆមាសទី១នេះ ប្រតិបត្តិការទិញ-លក់រូបិយប័ណ្ណតាមរយៈផ្លែតហ្វម NBCP មាន ១.០០៨ លានដុល្លារអាមេរិក បានថយ -៥% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ដោយសារការថមថយនៃតម្រូវការ។

**ក្រាហ្វ ២១ ៖ ការទិញ-លក់ប្រាក់ដុល្លារអាមេរិកតាមរយៈ NBCP**
(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២២ ៖ អត្រាប្តូរប្រាក់ប្រសិទ្ធភាព**
(សន្ទស្សន៍ ២០១៥=១០០, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល (IREER) មាននិន្នាការថយចុះ ដែលបានជួយបន្ទាបសម្ពាធអតិផរណាពីការនាំចូល។ IREER បានថយចុះ -៣% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ដោយសារអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល (INEER)[២៥]បានថយចុះ -៥,៤% ខណៈអត្រាអតិផរណារបស់កម្ពុជាមានកម្រិតទាបជាងប្រទេសដៃគូនាំចូល។

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ (EREER) កើនឡើង ១,៦% ដែលបណ្តាលមកពីអត្រាអតិផរណារបស់កម្ពុជាមានកម្រិតទាបជាងប្រទេសដៃគូនាំចេញ បើទោះជាអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ (ENEER)[២៦] បានថយចុះ -១,៩%។ ការកើនឡើងនៃ EREER បង្ហាញពីភាពប្រសើរឡើងនៃឧត្តមភាពប្រកួតប្រជែងលើការនាំចេញ។

---

[២៥] ប្រទេសដៃគូនាំចូលមកកម្ពុជាចម្បងៗរួមមាន៖ ចិន ថៃ វៀតណាម តៃវ៉ាន់ សិង្ហបុរី ជប៉ុន ហុងកុង កូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងសហរដ្ឋអាមេរិក។

[២៦] ប្រទេសគោលដៅនាំចេញរបស់កម្ពុជាជាចម្បងៗរួមមាន៖ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា ចិន ថៃ អេស្ប៉ាញ បែលហ្សិក បារាំង ហូឡង់ វៀតណាម ហុងកុង អ៊ីតាលី។

## ៥- ស្ថានភាពជញ្ជីងទូទាត់

សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ២២៥ លានដុល្លារអាមេរិក ធៀបនឹងអតិរេក ៨០០ លានដុល្លារអាមេរិក គ្រាដូចគ្នាឆ្នាំមុន ដែលគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ ស្របពេលដែលឱនភាពគណនីចរន្តនិងដើមទុនបានប្តូរទៅជាអតិរេក។

**ក្រាហ្វ ២៣ ៖ ជញ្ជីងទូទាត់កម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### -គណនីចរន្ត និងដើមទុន

ស្ថានភាពគណនីចរន្តនិងដើមទុន មានភាពប្រសើរឡើងដោយបានប្តូរពីឱនភាពទៅជាអតិរេកគណនីចរន្តនិងដើមទុន។ គណនីចរន្តនិងដើមទុនមានអតិរេក ១,៣% នៃផ.ស.ស. (១៧១,៥ លានដុល្លារអាមេរិក) ធៀបនឹងឱនភាព ៣០% នៃផ.ស.ស. គ្រាដូចគ្នាឆ្នាំមុន ដែលជាចម្បងដោយសារភាពប្រសើរឡើងនៃឱនភាពពាណិជ្ជកម្មទំនិញ[២៧] និងគណនីចំណូលបឋម[២៨] និងការប្តូរពីឱនភាពទៅជាអតិរេកគណនីសេវា[២៩] ខណៈដែលអតិរេកគណនីចំណូលបន្ទាប់បន្សំ[៣០] និងលំហូរចូលសុទ្ធគណនីដើមទុនបានថយចុះ[៣១]។

**ក្រាហ្វ ២៤៖ គណនីចរន្ត និងគណនីដើមទុន**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[២៧] ឱនភាពពាណិជ្ជកម្មទំនិញបានធ្លាក់ចុះ -៣.៤៨២ លានដុល្លារអាមេរិក (-៧១,២%) ធៀបនឹងឱនភាព ៤.៨៨៩ លានដុល្លារអាមេរិកក្នុងឆមាសទី១ ឆ្នាំ២០២២ ក្នុងនោះការនាំចូលបានថយចុះ -២២,៤% ខណៈការនាំចេញបានថយចុះ -២,១%។

[២៨] ឱនភាពគណនីចំណូលបឋមបានថយចុះ -៧៦ លានដុល្លារអាមេរិក (-៩%) ធៀបនឹងឱនភាព ៨៤៦ លានដុល្លារអាមេរិក។

[២៩] គណនីសេវាសុទ្ធបានប្តូរពីឱនភាព ៤៣១ លានដុល្លារអាមេរិក ទៅជាអតិរេក ៦៧៩ លានដុល្លារអាមេរិក ជាចម្បងដោយសារការកើនឡើងនៃចំណូលពីសេវាធ្វើដំណើរ។

[៣០] អតិរេកគណនីចំណូលបន្ទាប់បន្សំបានថយចុះ -៣៥ លានដុល្លារអាមេរិក (-២,១%) ធៀបនឹងអតិរេក ១.៦៣៤ លានដុល្លារអាមេរិក។

[៣១] គណនីដើមទុនមានលំហូរចូលសុទ្ធ ៧០ លានដុល្លារអាមេរិក បានថយចុះ -៣៣,៣%។




ឱនភាពពាណិជ្ជកម្មទំនិញ បានថយចុះ -៧១,២% (ឆ្នាំមុន -២០,៥%) ដោយសារការនាំចូលថយចុះ -២២,៤% ក្នុងនោះ យានយន្តថយ -២២,៨% វត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់ -១៧,៩% និងប្រេងឥន្ធនៈ -១,៩% ខណៈដែលម្ហូបអាហារនិងភេសជ្ជៈកើន ២,៣% និងសម្ភារនិងបរិក្ខារសំណង់ ០,៥%។ ការនាំចេញបានថយចុះ -២,១% ជាចម្បងដោយសារការថយចុះការនាំចេញទោចក្រយាន (-៣០,៥%) ផលិតផលកាត់ដេរ[៣២] (-១៨,៥%) និងកៅស៊ូ (-៩,៨%) ខណៈដែលមុខទំនិញផ្សេងទៀតបានបន្តកើនឡើងរួមមាន គ្រឿងអេឡិចត្រូនិក (១,៣ដង) និងអង្ករ (១២,៥%)។

គណនីសេវាសុទ្ធបានប្ដូរពីឱនភាព ទៅជាអតិរេក ជាចម្បងដោយសារការកើនឡើងនៃចំណូលពីសេវាធ្វើដំណើរ ២,៥ដង ស្របពេលដែលឱនភាពគណនីចំណូលបឋមបានថយចុះ -៩%

[៣២] ក្នុងនោះការនាំចេញសម្លៀកបំពាក់ថយចុះ -១៩% ស្បែកជើង -១៧,២% សម្ភារសម្រាប់ធ្វើដំណើរ និងផលិតផលវាយនភ័ណ្ឌផ្សេងទៀត -១៧,១%។

ជាចម្បងដោយសារការកើនឡើងការទូទាត់ពីក្រៅប្រទេស ៤៦,២% (ចំណូលពីការប្រាក់កើន ៧,៥%) ស្របពេលដែលការទូទាត់ទៅក្រៅប្រទេសបានថយចុះ -០,៦% (ចំណាយការប្រាក់របស់រាជរដ្ឋាភិបាលកើន ៨,៣% ខណៈការបែងចែកភាគលាភនិងប្រាក់ចំណេញពីការវិនិយោគផ្ទាល់ថយចុះ -៣,៩%)។ ទន្ទឹមនេះ អតិរេកគណនីចំណូលបន្ទាប់បន្សំបានថយចុះ -២,១% ក្នុងនោះប្រាក់បង្វែររបស់ពលករពីក្រៅប្រទេស[៣៣] បានថយចុះ -២,៧% ខណៈជំនួយរបស់រាជរដ្ឋាភិបាលបានកើនឡើង ១,២%។

- **គណនីហិរញ្ញវត្ថុ**

សមតុល្យគណនីហិរញ្ញវត្ថុត្រូវបានប៉ាន់ស្មានថា មានលំហូរចូលសុទ្ធ ៧៨០ លានដុល្លារអាមេរិក ដែលគាំទ្រដោយវិនិយោគផ្ទាល់ ខណៈដែលវិនិយោគផ្សេងទៀតបានប្តូរពីលំហូរចូលសុទ្ធទៅជាលំហូរចេញសុទ្ធ។ លំហូរវិនិយោគផ្ទាល់សុទ្ធបានកើនឡើង ១៣,១% ជាចម្បងដោយសារការវិនិយោគលើវិស័យមិនមែនធនាគារ[៣៤] បានកើនឡើង ២១,២% ខណៈដែលវិស័យធនាគារបានថយចុះ-០,៩%។

ក្រាហ្វ ២៥ ៖ គណនីហិរញ្ញវត្ថុ
(ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

វិនិយោគផ្សេងទៀតមានលំហូរចេញសុទ្ធ ៩៧២ លានដុល្លារអាមេរិក បានប្តូរពីលំហូរចូលសុទ្ធ ៣,៤ ប៊ីលានដុល្លារអាមេរិក ក្នុងឆមាសទី១ ឆ្នាំ២០២២ ដែលបណ្តាលពីការប្តូរពីលំហូរចូលសុទ្ធទៅជាលំហូរចេញសុទ្ធនៃទ្រព្យសកម្មបរទេសសុទ្ធរបស់វិស័យធនាគារ និងវិស័យឯកជនផ្សេងទៀត ខណៈការខ្ចីរបស់រាជរដ្ឋាភិបាលសុទ្ធថយចុះ -៤៦,៩%។

ក្រាហ្វ ២៦ ៖ វិនិយោគផ្ទាល់បរទេស
(ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

[៣៣] ក្នុងនោះ ប្រាក់បង្វែររបស់ពលករពីប្រទេសថៃថយចុះ -៣% និង ម៉ាឡេស៊ី -៦% ខណៈដែលជប៉ុនកើន ៣៨% កូរ៉េ ១៣% ហុងកុង ៦% និងសិង្ហបុរី ៥%។

[៣៤] វិស័យកម្មន្តសាលកើន ៧៤,៣% (ក្នុងនោះ ការវិនិយោគលើវិស័យកាត់ដេរសម្លៀកបំពាក់កើន ២៣,២% ស្បែកជើង ២,៣ដង ផលិតផលធ្វើដំណើរ ១២,៣% ផលិតផ្ទាំងសូឡា ៣,៨ដង និងផ្សេងៗទៀត ៩២,៤%) វិស័យសំណង់ ១,០៥ដង វិស័យថាមពល ៥៥,៤% វិស័យសណ្ឋាគារនិងការកម្សាន្ត ១១,៥% វិស័យអចលនទ្រព្យ ៣២,៩% និងវិស័យអាជីវកម្មរ៉ែ ៥៥,៩% ខណៈដែលវិស័យកសិកម្មបានថយចុះ -២៦,២% និងវិស័យផ្សេងទៀត -១៤,៤%។

## ៦- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

**ក្រាហ្វ ២៧ ៖ ទុនបម្រុងអន្តរជាតិ**

(ឆ្នាំ២០១២ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

នៅឆមាសទី១ ឆ្នាំ២០២៣នេះ ទុនបម្រុងអន្តរជាតិមានចំនួន ១៨,៤ ប៊ីលានដុល្លារអាមេរិក បានកើនឡើងបន្តិចវិញ ប្រមាណ ៣,២% ធៀបនឹងចុងខែធ្នូ ឆ្នាំ២០២២ បើទោះបីជាទទួលរងសម្ពាធពីការដួលរលំធនាគារពាណិជ្ជមួយចំនួននៅសហរដ្ឋអាមេរិក និងការខាតបង់របស់ធនាគារ Credit Suisse ដែលជាធនាគារធំមួយនៅប្រទេសស្វីស និងការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍។ ការកើនឡើងទុនបម្រុងនេះជាលទ្ធផលពីការកើនឡើងចំណូលពីការវិនិយោគក្រៅប្រទេស ថ្លៃមាស និងប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅធនាគារជាតិនៃកម្ពុជា។ កម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិនេះបង្ហាញពីលទ្ធភាពរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ ទំនុកចិត្តលើរូបិយវត្ថុជាតិ មូលដ្ឋានសម្រាប់ការខ្ចីក្រៅប្រទេស ព្រមទាំងផ្តល់ការការពារគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការសន្ទនីយភាពទប់ទល់នឹងវិបត្តិខាងក្រៅ។

ការវិនិយោគទុនបម្រុងអន្តរជាតិត្រូវបានអនុវត្តដោយមានភាពបត់បែន ហើយហានិភ័យនៃការវិនិយោគត្រូវបានគ្រប់គ្រងនិងតាមដានយ៉ាងហ្មត់ចត់ និងគោរពតាមសេចក្តីណែនាំការវិនិយោគរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាបានការគ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយសុវត្ថិភាព សន្ទនីយភាព និងទទួលបានចំណូលសមស្រប។ នៅដើមឆ្នាំ២០២៣ នេះ ធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំការវិនិយោគ ដោយបានកែសម្រួលសមាសភាគនៃចំណែកទុនបម្រុងវិនិយោគ និងរូបិយប័ណ្ណ ដើម្បីឆ្លើយតបនឹងកំណើននៃតម្រូវការសន្ទនីយភាព និងលទ្ធភាពខ្ពស់ក្នុងការចាប់យកឱកាសពីការប្រែប្រួលនៃអត្រាការប្រាក់នៅលើទីផ្សារ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការបង្កើនការវិនិយោគលើសញ្ញាប័ណ្ណបៃតង (Green bonds) និងសញ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលបោះផ្សាយដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ នៅប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន និងនៅតំបន់អឺរ៉ុប។

## II- ការគ្រប់គ្រងរូបិយវត្ថុ

ការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្ន ដោយថ្លឹងថ្លែងពីតម្រូវការសន្ទនីយភាពដើម្បីគាំទ្រការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច និងសម្ពាធលើអតិផរណានិងអត្រាប្តូរប្រាក់។

### ១- ស្ថានភាពរូបិយវត្ថុ

កំណើននៃការផ្គត់ផ្គង់រូបិយវត្ថុទូទៅ (M2) បន្តនិន្នាការថយល្បឿនមកត្រឹម ៩,២% (ឆ្នាំលើឆ្នាំ) បន្ទាប់ពីបានកើនឡើងខ្ពស់ក្នុងអំឡុងវិបត្តិកូវីដ-១៩ ដល់ ១៩,២% ក្នុងឆមាសទី១ ឆ្នាំ២០២១។ ការថយល្បឿនកំណើននេះដោយសារកំណើនយឺតនៃប្រាក់បញ្ញើជារូបិយប័ណ្ណ (៧,៨%) និងប្រាក់បញ្ញើជារៀល (២៦,២%) ខណៈកំណើនរូបិយវត្ថុក្នុងចរាចរណ៍បានកើនមកវិញ (៨%)។ ចំណែកឯដុល្លារូបនីយកម្មបន្តមានកម្រិតខ្ពស់ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ ៨៣% ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុប ៩០,៤% និងឥណទានជារូបិយប័ណ្ណធៀបនឹងឥណទានសរុប ៨៩%។

**ក្រាហ្វ ២៨៖ សមាសធាតុ និងកំណើនរូបិយវត្ថុទូទៅ**

(ឆមាសទី១ ឆ្នាំ២០១៦ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

#### - ទ្រព្យសកម្មក្នុងស្រុកសុទ្ធ

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់គ្រឹះស្ថានហិរញ្ញវត្ថុ[៣៥]បានថមថយកំណើនមកត្រឹម ១២,៨% (ឆ្នាំលើឆ្នាំ) ពី ៤១,៩% នៅគ្រាដូចគ្នាឆ្នាំមុនដែលជាចម្បងបណ្តាលមកពីការថមថយកំណើនឥណទានចំពោះវិស័យឯកជនមកត្រឹម ១០,៨% ធៀបនឹងកំណើន ២៣,៥% ក្នុងឆមាសទី១ឆ្នាំមុន។

**ក្រាហ្វ ២៩៖ ឥណទានចំពោះវិស័យឯកជន ប្រាក់បញ្ញើសរុប និងកំណើនឆ្នាំលើឆ្នាំ**

(ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

#### - ទ្រព្យសកម្មបរទេសសុទ្ធ

ទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានហិរញ្ញវត្ថុ បានកើនឡើងបន្តិច ០,២% ធៀបនឹងការថយចុះ -២៥,៦% នៅគ្រាដូចគ្នាឆ្នាំមុន ដែលបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសសរុបចំនួន ១,៩% ខ្ពស់ជាងកំណើនទ្រព្យអកម្មបរទេសសរុបដែលបានកើនឡើងត្រឹមតែ ២,៥%។ កើនឡើងនៃទ្រព្យសកម្មបរទេសសរុបនេះ គឺបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត (២៧,៩%) និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត (៧,៥%) ខណៈដែល

[៣៥] រួមបញ្ចូលគ្រឹះស្ថានធនាគារ មីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង។

ទ្រព្យសកម្មបរទេសធនាគារជាតិនៃកម្ពុជាថយចុះ -៤,៥%។ ចំណែកឯការកើនឡើងនៃទ្រព្យអកម្មបរទេសសរុប គឺដោយសារកំណើនទ្រព្យអកម្មបរទេសរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត[៣៦] (៧,៣%) គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត[៣៧] (៦,៨%) ខណៈដែលទ្រព្យអកម្មបរទេសរបស់ធនាគារជាតិនៃកម្ពុជាបានថយចុះ(-៦១,៤%)។

**ក្រាហ្វ ៣០ ៖ ទ្រព្យសកម្មបរទេសសុទ្ធនៃគ្រឹះស្ថានទទួលប្រាក់បញ្ញើ**

(គិតជាប៊ីលានរៀល, ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២- ការអនុវត្តនយោបាយរូបិយវត្ថុ

### ក- ប្រតិបត្តិការទិញ-លក់រូបិយប័ណ្ណ

ក្នុងបរិការណ៍នៃការកើនឡើងតម្រូវការប្រាក់រៀល ដោយសារភាពប្រសើរឡើងវិញនៃសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាពុំបានធ្វើអន្តរាគមន៍ទិញ-លក់ប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារជាមួយគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់នោះទេនៅឆមាសទី១ ប៉ុន្តែបានប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុផ្សេងៗដើម្បីឆ្លើយតបនឹងកំណើនតម្រូវការប្រាក់រៀល។ ដោយឡែក ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកពីស្ថាប័នរដ្ឋចំនួន ១៨,៥ លានដុល្លារអាមេរិក និងលក់ ១៣,២ លានដុល្លារអាមេរិក ធៀបនឹងគ្រាដូចគ្នាឆ្នាំមុនមានការទិញ ១៤ លានដុល្លារអាមេរិក និងការលក់ ៥១,៩ លានដុល្លារអាមេរិក។

**ក្រាហ្វ ៣១៖ ការទិញ-លក់ប្រាក់ដុល្លារអាមេរិកជាមួយស្ថាប័នរដ្ឋ**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣)




**ក្រាហ្វ ៣២៖ អន្តរាគមន៍ទិញ-លក់ប្រាក់ដុល្លារអាមេរិក**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៣៦] គ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀតមាន ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

[៣៧] គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត មាន ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងក្រុមហ៊ុនធានារ៉ាប់រង

## ខ- មូលបត្រអាចជួញដូរបាន (NCD)

ចាប់ពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣ NCD ត្រូវបានផ្លាស់ប្តូរយន្តការពីការបោះផ្សាយតាមតម្រូវការរបស់គ្រឹះស្ថាន រៀងរាល់ ១ សប្តាហ៍ម្តង មកជាវិធីសាស្រ្តដេញថ្លៃ តាមទំហំទឹកប្រាក់ និងអត្រាការប្រាក់អតិបរមា ដែលកំណត់ដោយ ធនាគារជាតិនៃកម្ពុជា រៀងរាល់ ២ សប្តាហ៍ម្តង។ ការផ្លាស់ប្តូរយន្តការនេះមានគោលបំណងជំរុញទីផ្សារអន្តរ-ធនាគារឱ្យកាន់តែសកម្ម និងឆ្លុះបញ្ចាំងពីការកំណត់អត្រាការប្រាក់មួយសមរម្យតាមយន្តការទីផ្សារបច្ចុប្បន្ន។ ការចេញផ្សាយ NCD ជាដុល្លារអាមេរិកថយចុះ -៧៩,៨% មកត្រឹម ៩,១ ប៊ីលានដុល្លារអាមេរិក និង NCD ជារៀលថយចុះ -១៥,២% មកត្រឹម ៥,៩ ទ្រីលានរៀល ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។ NCD មិនទាន់ដល់ឥណប្រតិទានជារៀលថយចុះ -១៦% មកត្រឹម ៩៨៩,៦ ប៊ីលានរៀល និងជាដុល្លារអាមេរិកថយចុះ -៦៦,៦% មកត្រឹម ១,១ ប៊ីលានដុល្លារអាមេរិក ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។

អត្រាការប្រាក់ NCD ជាដុល្លារអាមេរិកមាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ ដោយមានអត្រាក្នុងចន្លោះ ១,៩១% ដល់ ១,៩៥% សម្រាប់ឥណប្រតិទានទាំងអស់ (ពី ៧ថ្ងៃ ដល់ ៣៦៤ថ្ងៃ)។ ចំណែកអត្រាការប្រាក់ NCD ជារៀល មានស្ថិរភាពសម្រាប់ឥណប្រតិទានក្រោមនិងស្មើ ៩១ថ្ងៃ ខណៈអត្រាការប្រាក់សម្រាប់ឥណប្រតិទានវែងជាងនេះមានការថយចុះ ដោយមានកម្រិត ០,៦៨% និង ០,៧១% សម្រាប់ឥណប្រតិទាន ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ។

**ក្រាហ្វ ៣៣៖ NCD ជាដុល្លារអាមេរិក**

(គិតជាប៊ីលានដុល្លារអាមេរិក, ឆមាសទី២ ឆ្នាំ២០១៣ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៤៖ NCD ជារៀល**

(គិតជាទ្រីលានរៀល, ឆមាសទី២ ឆ្នាំ២០១៤ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៥៖ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិក**

(គិតជាភាគរយ, អត្រាមធ្យម, ឆមាសទី១ ២០២០ - ឆមាសទី១ ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៦៖ អត្រាការប្រាក់ NCD ជារៀល**

(គិតជាភាគរយ, អត្រាមធ្យម, ឆមាសទី១ ២០២០ - ឆមាសទី១ ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### - មូលបត្ររដ្ឋ

ធនាគារជាតិនៃកម្ពុជាជាភ្នាក់ងារបោះផ្សាយ និងទូទាត់មូលបត្ររដ្ឋ នៅលើទីផ្សារដំបូង (Primary Market) ដែលមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាអ្នកចូលរួមជាវ។ ការដេញថ្លៃមូលបត្ររដ្ឋបានចាប់ផ្ដើមពីខែកញ្ញា ឆ្នាំ២០២២ មកដល់បច្ចុប្បន្នសរុបបាន ១១ដង គិតជាទំហំទឹកប្រាក់សរុប ១៨៤,១ ប៊ីលានរៀល។ នៅក្នុងឆមាសទី១ ឆ្នាំ២០២៣ ការដេញថ្លៃមូលបត្ររដ្ឋនៅលើផ្លែតហ្វម NBCP មាន ៦ដង ដែលសរុបជាប្រាក់រៀល ១១២ ប៊ីលានរៀល។

**ក្រាហ្វ ៣៧៖ មូលបត្ររដ្ឋជាប្រាក់រៀល**

(គិតជាប៊ីលានរៀល, ឆ្នាំ២០២២ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### គ- ប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា (LPCO)

តាមរយៈប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា (LPCO) ធនាគារជាតិនៃកម្ពុជា បានផ្គត់ផ្គង់ប្រាក់រៀលរយៈពេលខ្លីដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងអត្រាការប្រាក់ទាប។ ប្រតិបត្តិការដេញថ្លៃ LPCO ត្រូវបានធ្វើឡើង ១២លើក (២ដងក្នុង១ខែ) ដោយមានទឹកប្រាក់ ១,៥ ទ្រីលានរៀល [៣៨] ដែលកើនឡើង ៨៣,៨% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។ ទំហំទឹកប្រាក់ប្រតិបត្តិការ LPCO ដែលមិនទាន់ដល់ឥណប្រតិទានមាន ១,៥ ទ្រីលានរៀល ដោយបានកើនឡើង ៨១,៩% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។

**ក្រាហ្វ ៣៨៖ ទំហំទឹកប្រាក់ក្នុងប្រតិបត្តិការ LPCO**

(គិតជាប៊ីលានរៀល, ឆមាសទី២ ឆ្នាំ២០១៦ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៣៨] ឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ មាន ៤៩០,៨ ប៊ីលានរៀល ៨២៥ ប៊ីលានរៀល និង ១៥៤,៩ ប៊ីលានរៀល រៀងគ្នា។

អត្រាការប្រាក់ដេញថ្លៃឈ្នះ LPCO មានកម្រិតប្រហាក់ប្រហែលនឹងគ្រាដូចគ្នាឆ្នាំមុន ដោយសារគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានតម្រូវការប្រាក់រៀល ស្របពេលដែលធនាគារជាតិនៃកម្ពុជា បានដំឡើងទំហំទឹកប្រាក់ LPCO ដាក់ឱ្យដេញថ្លៃ សម្រាប់បំពេញតម្រូវការប្រាក់រៀលនៅលើទីផ្សារតាមកត្តារដូវកាល។ អត្រាការប្រាក់ដេញថ្លៃឈ្នះជាមធ្យមមានកម្រិត ៥,៦% (៥,៦% គ្រាដូចគ្នាឆ្នាំមុន) ដោយអត្រាសម្រាប់ឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៤ថ្ងៃ មានកម្រិត ៥,៥% ៦,១% និង ៥,១% រៀងគ្នា ធៀបនឹង ៥,៣% ៥,៧% និង ៥,៨% នៅគ្រាដូចគ្នាឆ្នាំមុន។

**ក្រាហ្វ ៣៩៖ អត្រាការប្រាក់ LPCO**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ឃ- ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF)

**ក្រាហ្វ ៤០៖ ទំហំទឹកប្រាក់មិនទាន់ដល់ឥណប្រតិទាន**

(គិតជាប៊ីលានរៀល, ឆមាសទី២ ឆ្នាំ២០១៦ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) ត្រូវបានដាក់ឱ្យដំណើរការ ដើម្បីបំពេញតម្រូវការសន្ទនីយភាពជាប្រាក់រៀលចាំបាច់សម្រាប់រយៈពេល ១ថ្ងៃ និងអាចបន្តបានរយៈពេល ៥ថ្ងៃ ក្នុងអត្រាការប្រាក់ប្រចាំឆ្នាំ ៩% ដោយមានវត្ថុធានា។ បច្ចុប្បន្ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា សម្រាប់ការប្រើប្រាស់ប្រតិបត្តិការ MLF មាន ៣០ ធនាគារ[៣៩]។ នៅក្នុងឆមាសទី១ ឆ្នាំ២០២៣ នេះ តាមរយៈ MLF សន្ទនីយភាពជាប្រាក់រៀលចំនួន ២០ ប៊ីលានរៀល ត្រូវបានផ្តល់ជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ១ ក្នុងរយៈពេល ១ថ្ងៃ។ គួររំលេចថា ទំហំ MLF មិនត្រូវបានកំណត់ទេ គឺអាស្រ័យលើទំហំនៃវត្ថុធានា ដែលធនាគារជាតិនៃកម្ពុជាទទួលយក។

---

[៣៩] ធនាគារប្រៃសណីយ៍កម្ពុជា ធនាគារដេគ្រាស៍ រ៉ូយ៉ាល់ ធនាគារវឌ្ឍនៈអាស៊ី ធនាគារមេយប៊ែង ធនាគារអេស៊ីលីដា ធនាគារស៊ិនហាន ធនាគាររីង ធនាគារអេសប៊ីអាយលីហ្វរ ធនាគារហ្វីលីព ធនាគារអាយស៊ីប៊ីស៊ី ធនាគារគូកមីន ធនាគារវឌ្ឍនៈ ធនាគារតៃវ៉ាន់ ធនាគារព្រីនស៍ ធនាគារពាណិជ្ជទីមួយ ធនាគារប្រេដប៊ែង ធនាគារស្ថាបនា ធនាគារស៊ីអាយអិមប៊ី ធនាគារពាណិជ្ជកម្មក្រៅប្រទេស ធនាគារកម្ពុជាពាណិជ្ជ ធនាគារមេហ្គា ធនាគារកាណាឌីយ៉ា ធនាគារចិន ធនាគារភ្នំពេញ ពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអិលអូអិលស៊ី ធនាគារអូរិនថល ធនាគារហត្ថា ធនាគារហេងហ៊ី ធនាគារហេង ហ្វឹង និងធនាគារកសិកម្ម និងអភិវឌ្ឍន៍ជនបទ ។

## ខ- អត្រាប្រាក់បម្រុងកាតព្វកិច្ច

អត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រូវបានដំឡើងពី ៧% ដល់ ៩% ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ខណៈដែលអត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលត្រូវបានរក្សាក្នុងកម្រិត ៧% ដដែល។ ការដំឡើងអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបានស្រូបសន្ទនីយភាពជារូបិយប័ណ្ណមួយផ្នែកពីប្រព័ន្ធធនាគារ ប៉ុន្តែនៅផ្តល់សន្ទនីយភាពបន្ថែមប្រមាណ ៧ ទ្រីលានរៀល (១,៧ ប៊ីលានដុល្លារអាមេរិក) បើធៀបនឹងអត្រាមុនវិបត្តិ (១២,៥% សម្រាប់ដុល្លារអាមេរិក និង ៨% សម្រាប់រៀល)។ ការផ្តល់សន្ទនីយភាពដល់ប្រព័ន្ធធនាគារបានបន្តរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តវិធានការរៀបចំឥណទានឡើងវិញ ការបង្កើនសំវិធានធន គាំទ្រកំណើនឥណទាន និងពង្រឹងការការពារហានិភ័យសន្ទនីយភាព។ បច្ចុប្បន្ន ប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិកមាន ១៧,៨ ទ្រីលានរៀល (ប្រមាណ ៤,៣ ប៊ីលានដុល្លារអាមេរិក) និងជារៀល ១,៤ ទ្រីលានរៀល (៣៤០,៤ លានដុល្លារអាមេរិក) ដែលប្រាក់បម្រុងកាតព្វកិច្ចមាននិន្នាការកើនឡើង ៣២% និង ១៩% រៀងគ្នា ធៀបនឹងឆមាសទី១ ឆ្នាំ២០២២ ស្របតាមកំណើនប្រាក់បញ្ញើរបស់អតិថិជន និងការខ្ចីក្រៅប្រទេស។

**ក្រាហ្វ ៤១ ៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**
(ទិន្នន័យចុងគ្រា, ឆ្នាំ១៩៩៦ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤២ ៖ សន្ទនីយភាពលើសជារៀល និងដុល្លារអាមេរិក**
(គិតជាទ្រីលានរៀល, ខែមិថុនា ឆ្នាំ២០១៩ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សន្ទនីយភាពលើសជាដុល្លារអាមេរិកបានថយចុះ-២៤,២% ធៀបនឹងឆមាសទី១ឆ្នាំមុន មកត្រឹម ១៩ ទ្រីលានរៀល (៤,៦ ប៊ីលានដុល្លារអាមេរិក) ខណៈសន្ទនីយភាពលើសជារៀលបានកើនឡើង ៦៣% ដល់ ៥,៧ ទ្រីលានរៀល (១,៤ ប៊ីលានដុល្លារអាមេរិក) ដោយសារការថយចុះនៃប្រាក់បញ្ញើរដ្ឋាភិបាល (-៣៧,៥%)។ អនុបាតសន្ទនីយភាពលើសធៀបនឹងប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិកមានកម្រិត ១០៧% (៤,៣ ប៊ីលានដុល្លារអាមេរិក) និងជារៀល ៤០៦% (៣៥០,៤ លានដុល្លារអាមេរិក) ដែលបង្ហាញពីសន្ទនីយភាពខ្ពស់ក្នុងប្រព័ន្ធធនាគារ។

**ក្រាហ្វ ៤៣ ៖ អនុបាតសន្ទនីយភាពលើសធៀបនឹងប្រាក់បម្រុងកាតព្វកិច្ចជារៀល និងដុល្លារអាមេរិក**
(ខែមិថុនា ឆ្នាំ២០១៩ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ច- ការចាក់បញ្ចូលសន្ទនីយភាពសុទ្ធជារៀល

ការចាក់បញ្ចូលសន្ទនីយភាពសុទ្ធជារៀល[៤០] បានកើនឡើងដល់ ១,១ ទ្រីលានរៀល (កើន ១០៤% ធៀបនឹងឆមាសទី១ ឆ្នាំមុន) ដោយសារការបង្កើនការបញ្ចេញសន្ទនីយភាពតាមរយៈប្រតិបត្តិការ LPCO ជាបន្តបន្ទាប់ចាប់ពីខែមករា ឆ្នាំ២០២៣ ខណៈដែល NCD មិនទាន់ដល់ឥណប្រតិទានថយចុះប្រមាណ -១៦% បើធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ដោយសារការកាត់បន្ថយការស្រូបយកសន្ទនីយភាព តាមរយៈ NCD ជារៀល ចាប់ពីខែមីនាមក។

**ក្រាហ្វ ៤៤ ៖ ការចាក់បញ្ចូលសន្ទនីយភាព**
(គិតជាទ្រីលានរៀល, ខែមិថុនា ឆ្នាំ២០២០ - ខែមិថុនា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៤០] ការចាក់បញ្ចូលសន្ទនីយភាពសុទ្ធជារៀល ជាផលដករវាងប្រតិបត្តិការ LPCO មិនទាន់ដល់ឥណប្រតិទាន និង NCD មិនទាន់ដល់ឥណប្រតិទាន។ នៅពេលដែលផលដកមានសញ្ញាវិជ្ជមាន មានន័យថាជាការចាក់បញ្ចូលសន្ទនីយភាពសុទ្ធជារៀល ដោយឡែក នៅពេលដែលផលដកមានសញ្ញាអវិជ្ជមាន មានន័យថាជាការស្រូបយកសន្ទនីយភាពសុទ្ធជារៀល។

## III- ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា

### ១- ស្ថានភាពទូទៅ

ប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជ ៥៩ ធនាគារឯកទេស ៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨២ គ្រឹះស្ថានឥណទានជនបទ ១១៨ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៧ អ្នកដំណើរការតតិយភាគី ៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៣៥ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៦ និងអាជីវកម្មប្តូរប្រាក់ ២.៨៩០។ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារ[៤១]មានកំណើន ៩,៩% ដល់ ៣៣៣,៤ ទ្រីលានរៀល (៨២,២ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះ វិស័យធនាគារគ្របដណ្តប់ប្រមាណ ៨៥% នៃទ្រព្យសកម្មសរុប ស្របពេលដែលវិស័យមីក្រូហិរញ្ញវត្ថុ និងវិស័យភតិសន្យាហិរញ្ញវត្ថុមានចំណែក ១៤,៤% និង ០,៦% រៀងគ្នា។

**ក្រាហ្វ ៤៥៖ ទ្រព្យសកម្មប្រព័ន្ធធនាគារ**
(ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣ប)




**ក្រាហ្វ ៤៦៖ ចំណែកទ្រព្យសកម្មប្រព័ន្ធធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

ឥណទាន និងប្រាក់បញ្ញើអតិថិជនមានកំណើន ១៣,៨% ដល់ ២៣៧,៥ ទ្រីលានរៀល (៥៨,៦ ប៊ីលានដុល្លារអាមេរិក) និង ៦,៤% ដល់ ១៧៩,៨ ទ្រីលានរៀល (៤៤,៤ ប៊ីលានដុល្លារអាមេរិក) រៀងគ្នា។ ជាមួយគ្នានេះ ដើមទុនក្នុងប្រព័ន្ធធនាគារមានកំណើន ៨,១% ដល់ ៣៥,៤ ទ្រីលានរៀល (៨,៧ ប៊ីលានដុល្លារអាមេរិក)។

**ក្រាហ្វ ៤៧៖ ប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

---

[៤១] រាប់បញ្ចូលធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។

កន្លងមក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានរួមចំណែកជួយសម្រាលបន្ទុករបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងគ្រោះទឹកជំនន់ ដោយបានផ្តល់ការអនុគ្រោះដល់អ្នកខ្ចីប្រាក់តាមរយៈការរៀបចំឥណទានឡើងវិញ។ ឥណទានរៀបចំឡើងវិញបន្តមាននិន្នាការថយចុះ ស្របតាមការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ហើយគិតត្រឹមឆមាសទី១នេះ មានចំនួន ១៤០.៥៣៨ គណនី ស្មើនឹង ១០,៧ ទ្រីលានរៀល (២,៦ ប៊ីលានដុល្លារអាមេរិក)។

**ក្រាហ្វ ៤៨៖ ចំនួនគណនីឥណទានរៀបចំឡើងវិញ**
(ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៣ប)




**ក្រាហ្វ ៤៩៖ សមតុល្យឥណទានរៀបចំឡើងវិញ**
(គិតជាលានដុល្លារអាមេរិក ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**ក្រាហ្វ ៥០៖ ចំនួនគណនីឥណទានរៀបចំឡើងវិញតាមវិស័យ**
(ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៣ប)




**ក្រាហ្វ ៥១៖ សមតុល្យឥណទានរៀបចំឡើងវិញតាមវិស័យ**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

ទោះស្ថិតក្នុងស្ថានភាពនៃការរឹតត្បិតហិរញ្ញវត្ថុខាងក្រៅនិងភាពមិនច្បាស់លាស់ ប្រព័ន្ធធនាគារបន្តមានស្ថិរភាពនិងរក្សាបាននូវភាពធន់ ដែលឆ្លុះបញ្ចាំងតាមរយៈភាពរឹងមាំនៃសូចនាករហិរញ្ញវត្ថុសំខាន់ៗដូចខាងក្រោម៖

i/-ស្ថានភាពដើមទុនបន្តមានភាពគ្រប់គ្រាន់ អនុលោមតាមបទប្បញ្ញត្តិ (១៥%) ដោយអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ មានកម្រិត ២៣,៦% និង ២២,៦% រៀងគ្នា។

ក្រាហ្វ ៥២៖ អនុបាតសាធនភាព

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែមេសា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ii/-សន្ទនីយភាពបន្តមានកម្រិតខ្ពស់ ដោយអនុបាតគ្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានកម្រិត ១៥១,៩% និង ១៨៧,១% រៀងគ្នា ខ្ពស់ជាងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១០០%) ដែលបង្ហាញពីលទ្ធភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបនឹងតម្រូវការឥណទាន និងការដកប្រាក់បញ្ញើរបស់អតិថិជន។

iii/-អនុបាតឥណទានមិនដំណើរការបានកើនឡើងបន្តិច បន្ទាប់ពីការបញ្ចប់វិធានការឥណទានរៀបចំឡើងវិញកាលពីចុងខែមិថុនា ឆ្នាំ២០២២ និងការថមថយកំណើនឥណទាន ប៉ុន្តែអនុបាតនេះបន្តស្ថិតនៅកម្រិតអាចគ្រប់គ្រងបាន ក្នុងនោះគ្រឹះស្ថានធនាគារមានកម្រិត ៤% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានកម្រិត ៣,៣%។

ក្រាហ្វ ៥៣៖ អនុបាតគ្របខ័ណ្ឌសន្ទនីយភាព

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែមេសា ឆ្នាំ២០២៣)




ក្រាហ្វ ៥៤៖ អនុបាតឥណទានមិនដំណើរការ

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែមេសា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

iv/-លទ្ធភាពស្វែងរកប្រាក់ចំណេញបន្តមានចីរភាព ដោយអនុបាតប្រាក់ចំណេញធៀបទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុនិក (ROE) របស់គ្រឹះស្ថានធនាគារមានកម្រិត ១% និង ៥,១% រៀងគ្នា ខណៈគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានកម្រិត ២,៥% និង ១១,៤% រៀងគ្នា។ ការរក្សាបានលទ្ធភាពស្វែងរកប្រាក់ចំណេញបានរួមចំណែកការពារគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពីវិបត្តិ ក៏ដូចជាបង្កើនលទ្ធភាពក្នុងការបម្រើសេវាហិរញ្ញវត្ថុប្រកបដោយភាពសម្បូរបែប និងនវានុវត្តន៍។

**ក្រាហ្វ ៥៥៖ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែមេសា ឆ្នាំ២០២៣)




**ក្រាហ្វ ៥៦៖ អនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុនិក**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែមេសា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥៧៖ អត្រាប្រាក់បម្រុងកាតព្វកិច្ចនិងអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិន**
(គិតជាភាគរយ, ឆ្នាំ២០១៩ - ឆ្នាំ២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ស្របតាមការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជានិងជាផ្នែកមួយនៃការអនុវត្តយុទ្ធសាស្រ្តចាកចេញពីវិបត្តិ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់វិធានការគាំទ្រដែលបានដាក់ចេញក្នុងអំឡុងពេលការរាលដាលជំងឺកូវីដ-១៩ រួមមានការតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុវាយតម្លៃចំណាត់ថ្នាក់ឥណទានរៀបចំឡើងវិញ និងរៀបចំសំវិធានធនសមស្រប ការដំឡើងអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសជាសន្សឹមៗមក ៩% នៅឆ្នាំ២០២៣ និង ១២,៥% នៅឆ្នាំ២០២៤ ព្រមទាំងការអនុវត្តឡើងវិញនៃទ្រនាប់ដើមទុននៅកម្រិត ១,២៥% ត្រឹមចុងខែមិថុនា ឆ្នាំ២០២៣ និងគ្រោងអនុវត្តពេញលេញ ២,៥% នៅចុងឆ្នាំ២០២៣ ដើម្បីពង្រឹងភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការទប់ទល់នឹងវិបត្តិ។

## ២- វិស័យធនាគារ

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារកើនឡើង ៨,៩% ដល់ ២៨៣,៥ ទ្រីលានរៀល (៦៩,៩ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទានអតិថិជនកើនឡើង ១១,៩% ដល់ ១៨៨,៣ ទ្រីលានរៀល (៤៥,៨ ប៊ីលានដុល្លារអាមេរិក) និងមានចំនួន ១,៦ លានគណនី។ ឥណទានត្រូវបានផ្តល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច ដូចជា៖ ការជួញដូររាយ ១៦% (មានកំណើន ១២,៩%) ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១៤,៥% (១៧,៥%) ការជួញដូរអចលនទ្រព្យ ៩,៥% (១៣,៦%) ការជួញដូរដុំ ៩,៣% (១១,៧%) សំណង់ ៩% (៨,៩%)

**ក្រាហ្វ ៥៨៖ ឥណទានគ្រឹះស្ថានធនាគារតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**
(ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៨% (១៣,៥%) ការឱ្យខ្ចីជាបុគ្គល ៨,៣% (០,៩%) កម្មន្តសាល ៥,៣% (២២,២%) សណ្ឋាគារនិងភោជនីយដ្ឋាន ៤,២% (៧,៨%) និងផ្សេងៗ ១៦,៩% (១០,៥%)។ ប្រាក់បញ្ញើបានកើនឡើង ៦,៥% ដល់ ១៥៩,៩ ទ្រីលានរៀល (៣៩,៥ ប៊ីលានដុល្លារអាមេរិក) និងមានចំនួន ១៣,៧ លានគណនី។

**ក្រាហ្វ ៥៩៖ ការរួមចំណែកតាមវិស័យក្នុងកំណើនឥណទានគ្រឹះស្ថានធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣ប)




**ក្រាហ្វ ៦០៖ កំណើនឥណទានគ្រឹះស្ថានធនាគារតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០២១ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=បឋមាន់ស្មាន

អត្រាការប្រាក់បញ្ញើ[៤២]ជារៀលនិងដុល្លារអាមេរិកក្នុងវិស័យធនាគារ មានកម្រិតជាមធ្យម ៧,៧៥% និង ៦,៣២% រៀងគ្នា ខ្ពស់ជាងអត្រាជាមធ្យមក្នុងគ្រាដូចគ្នាឆ្នាំមុន (៦,៤៧% និង ៤,៩២%)។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទាន[៤៣]ជារៀលនិងដុល្លារអាមេរិកជាមធ្យម ក៏បានកើនឡើងផងដែរ ដោយមានអត្រា ១៥,០៣% និង ១១,៦៦% រៀងគ្នា ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ១៣,១០% និង ១១,១៣%។

**ក្រាហ្វ ៦១៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៥ - ខែមេសា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៤២] អត្រាការប្រាក់បញ្ញើ៖ ត្រូវបានគណនាពីការថ្លឹងជាមួយទំហំប្រាក់បញ្ញើថ្មីក្នុងខែ ដែលបានដាក់ក្នុងគណនីបញ្ញើមានកាលកំណត់ ៩-១២ខែ។

[៤៣] អត្រាការប្រាក់ឥណទាន៖ ត្រូវបានគណនាពីការថ្លឹងជាមួយទំហំឥណទានថ្មីក្នុងខែ ដែលបានផ្តល់ទៅកាន់ធុរកិច្ចមានការធានា និងមានឥណប្រតិទានពី១ឆ្នាំ-៥ឆ្នាំ។

## ៣- វិស័យមីក្រូហិរញ្ញវត្ថុ

ទ្រព្យសកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង ១៦,៣% ដល់ ៤៧,៨ ទ្រីលានរៀល (១១,៨ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះ ឥណទានអតិថិជនបានកើនឡើង ១៤,៨% ដល់ ៤០ ទ្រីលានរៀល (៩,៧ ប៊ីលានដុល្លារអាមេរិក) ដោយមាន ២,២ លានគណនី។ ឥណទានទាំងនេះបានផ្តល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច រួមមាន៖ អង្គភាពគ្រួសារ ៣៤% (មានកំណើន ១៨,៤%) ពាណិជ្ជកម្មនិងជំនួញ ២៣,២% (១៥%) កសិកម្ម ១៧,៦% (១៣,២%) សេវាកម្ម ១៣,៤% (៨,៩%) ដឹកជញ្ជូន ៤,២% (០,២%) សំណង់ ៤,៤% (១៤%) កម្មន្តសាល ១,៩% (៣០,៨%) និងផ្សេងៗ ១,៣% (៤២,៤%)។ ទន្ទឹមនេះ វិស័យមីក្រូហិរញ្ញវត្ថុបានទទួលប្រាក់បញ្ញើ ២០ ទ្រីលានរៀល (៤,៩ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ២,៧ លានគណនី។

**ក្រាហ្វ ៦២៖ ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**
(ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=បាន់ស្មាន

**ក្រាហ្វ ៦៣៖ ការរួមចំណែកតាមវិស័យក្នុងកំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣ប)




**ក្រាហ្វ ៦៤៖ កំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០២១ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=បាន់ស្មាន

អត្រាការប្រាក់បញ្ញើជារៀល និងដុល្លារអាមេរិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាមធ្យមមាននិន្នាការកើនឡើងដល់ ៨,១៨% និង ៨,០៨% រៀងគ្នា ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (៧,២៥% និង ៧,២៣%)។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទានជាមធ្យមជារៀល និងដុល្លារអាមេរិក ក៏បានកើនឡើងផងដែរ ដល់ ១៧,៣៥% និង ១៦,០១% រៀងគ្នា ពី ១៦,៦៨% និង ១៤,៩៤% ក្នុងគ្រាដូចគ្នាឆ្នាំមុន។

**ក្រាហ្វ ៦៥៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(គិតជាភាគរយ, ឆ្នាំ២០១៥ - ខែមេសា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- វិស័យភតិសន្យាហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុកើនឡើង ៨,៣% ដល់ ២,១ ទ្រីលានរៀល (៥១៣,៥ លានដុល្លារអាមេរិក)។ ឥណទានភតិសន្យាហិរញ្ញវត្ថុកើនឡើង ១៣,១% ដល់ ១,៨ ទ្រីលានរៀល (៤៥៥,៥ លានដុល្លារអាមេរិក) ដោយមាន ៩៦.៩៦៤ គណនី ហើយត្រូវបានផ្តល់ទៅវិស័យជាច្រើន រួមមាន៖ កសិកម្ម ២៦,៥% អង្គភាពគ្រួសារ ២១,៦% សេវាកម្ម ២០,១% ដឹកជញ្ជូន ៥,៦% សំណង់ ៤,៧% ពាណិជ្ជកម្មនិងជំនួញ ៣,៦% និងវិស័យផ្សេងៗ ១៧,៩%។ ប្រភពទុនចម្បងរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុបានមកពីមូលនិធិភាគទុនិក ដោយកើនឡើង ៦,៩% ដល់ ៦៦០,៤ ប៊ីលានរៀល (១៦២,៩ លានដុល្លារអាមេរិក)។

**ក្រាហ្វ ៦៦៖ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ**
(ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

## ៥- គ្រឹះស្ថានឥណទានជនបទ

គ្រឹះស្ថានឥណទានជនបទបាននិងកំពុងរួមចំណែកផ្តល់សេវាឥណទានខ្នាតតូចនៅតាមតំបន់មូលដ្ឋាន ដើម្បីបំពេញតម្រូវការឥណទានទៅតាមប្រភេទអាជីវកម្មរបស់ប្រជាពលរដ្ឋ។ គ្រឹះស្ថានឥណទានជនបទដែលទទួលបានវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា បានផ្តល់ឥណទានដល់អតិថិជនសរុប ៨៤.២៣៦ គណនី ស្មើនឹង ១៧៧,៤ ប៊ីលានរៀល (៤៣,៧ លានដុល្លារអាមេរិក)។ ទន្ទឹមនេះ ដើម្បីពង្រឹងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ និងភាពរឹងមាំនៃវិស័យឥណទានជនបទ គ្រឹះស្ថានឥណទានជនបទចំនួន ១០៥ ត្រូវបានលុបឈ្មោះចេញពីបញ្ជីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងឆមាសទី១ ឆ្នាំ២០២៣។

**ក្រាហ្វ ៦៧៖ គ្រឹះស្ថានឥណទានជនបទ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

## ៦- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី[44] ដែលជាអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មានគ្រឹះស្ថានជាសមាជិកចំនួន ១៩១ គ្រឹះស្ថាន (កើន ៧ គ្រឹះស្ថាន ធៀបនឹងឆ្នាំ២០២២ ក្នុងនោះ ធនាគារពាណិជ្ជ ៥៩ ធនាគារឯកទេស ៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៨៧ គ្រឹះស្ថានភិតិសន្យា ១៧ និងគ្រឹះស្ថានឥណទានជនបទ ១៧)។ គិតត្រឹមខែមេសា ឆ្នាំ២០២៣ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានចំនួន ៤,២ លានគណនី (ប្រមាណ ២២៩,១ ទ្រីលានរៀល ស្មើនឹង ៥៥,៧ ប៊ីលានដុល្លារអាមេរិក) កើន ៦៧.៦៣៦គណនី ធៀបនឹងចុងឆ្នាំ២០២២រួមមាន៖ i/-ឯកត្តបុគ្គលមានចំនួន ៤,២ លានគណនី ជាមួយអតិថិជនសរុបចំនួន ៤,៩ លាននាក់ ក្នុងនោះស្ត្រីមានចំនួន ២,៦ លាននាក់ (៥២,៨%) និង ii/-ក្រុមហ៊ុនមាន ៥.៥៩៣ គណនី ជាមួយនឹងចំនួនអតិថិជន ១.៦៤៩ ក្រុមហ៊ុន។ ទន្ទឹមនេះ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីសរុបមានចំនួន ៧៥៦ ប្រតិបត្តិការ។

[44] មានទ្រព្យសកម្មសរុបប្រមាណ ៨២,៨ ប៊ីលានរៀល (២០,១ លានដុល្លារអាមេរិក)

**ក្រាហ្វ ៦៨៖ ចំនួនប្រតិបត្តិការប្រើប្រាស់របាយការណ៍ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

(គិតជាប្រតិបត្តិការ, ឆ្នាំ២០១៧ - ខែមេសា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ចុះអនុស្សរណៈយោគយល់ជាមួយក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (សិង្ហបុរី) ភីធីអ៊ី អិលធីឌី លើកិច្ចសហការសេវាចែករំលែករបាយការណ៍ឥណទានទ្វេភាគីរវាងកម្ពុជា និងសិង្ហបុរី។ បច្ចុប្បន្ន ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ក៏កំពុងសិក្សាលើកិច្ចសហការផ្តល់ព័ត៌មានឥណទានឆ្លងប្រទេសជាមួយបណ្តាប្រទេសផ្សេងទៀតផងដែរ។

បន្ថែមលើនេះ ដើម្បីធានានូវតម្លាភាពនិងសង្គតិភាពនៃទិន្នន័យដែលគ្រឹះស្ថានបានផ្តល់ទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ធនាគារជាតិនៃកម្ពុជា បានចេញលិខិតតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិករបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ផ្ទៀងផ្ទាត់ជាប្រចាំខែនូវទិន្នន័យគណនីឥណទានអតិថិជនដែលគ្រឹះស្ថានមិនបានប្រើប្រាស់របាយការណ៍ឥណទាន (Non-enquiry Loan Account) គិតចាប់ពីខែមករា ឆ្នាំ២០២៣ តទៅ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បន្តតាមដាននិងត្រួតពិនិត្យលើវឌ្ឍនភាពនៃការប្រតិបត្តិតាមបទប្បញ្ញត្តិជាធរមានរបស់អ្នកផ្តល់ទិន្នន័យ និងអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន សំដៅធានាគុណភាពទិន្នន័យ និងនិរន្តរភាពនៃដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា។

## ៧- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា បន្តតាមដាន និងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយផ្តោតលើស្ថានភាពហិរញ្ញវត្ថុ ភាពធន់ និងស្ថិរភាពនៃប្រព័ន្ធទាំងមូល ជាពិសេសការអនុវត្តយុទ្ធសាស្ត្រចាកចេញពីវិបត្តិ បន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្ត ខណៈដែលសេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងឥទ្ធិពលនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការរឹតត្បិតនៃស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ ជាដើម។ ការត្រួតពិនិត្យត្រូវបានអនុវត្តតាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ ដើម្បីបង្កើនប្រសិទ្ធភាពត្រួតពិនិត្យបន្ថែមទៀតតាមរយៈលទ្ធភាពកំណត់ជាមុននូវហានិភ័យនានាគួបផ្សំនឹងទស្សនៈអនាគត ដើម្បីអាចចាត់វិធានការត្រួតពិនិត្យនិងកែតម្រូវបានទាន់ពេលវេលា។ ជាមួយគ្នានេះ ធនាគារជាតិ

នៃកម្ពុជា បានប្រើប្រាស់វិធីសាស្ត្រស្រប ដើម្បីធ្វើការវិភាគទាំងផ្នែកបរិមាណនិងគុណភាព ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងការវិនិច្ឆ័យដោយហ្មត់ចត់តាមរយៈវិធីសាស្ត្រស្រប ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវអនុសាសន៍ និងកំណត់ជាក់លាក់អំពីតម្រូវការដើមទុន សន្ទនីយភាព និងការកំណត់មុខសញ្ញាសម្រាប់ការរៀបចំផែនការចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ បន្ថែមពីនេះ ការត្រួតពិនិត្យក៏រួមបញ្ចូលការធ្វើស្ត្រេសតេស្ត និងស្ត្រេសតេស្តត្រលប់លើអនុបាតសាធនភាព អនុបាតក្របខ័ណ្ឌសន្ទនីយភាព និងឥណទានរៀបចំឡើងវិញ ដើម្បីវាយតម្លៃលើស្ថានភាពដើមទុននិងភាពធន់របស់គ្រឹះស្ថាននីមួយៗ។

ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារពាណិជ្ជចំនួន ១០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន ២ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ១ និងគ្រឹះស្ថានឥណទានជនបទចំនួន ៣ ដោយផ្តោតលើអភិបាលកិច្ច គុណភាពទ្រព្យសកម្ម ការគ្រប់គ្រងហានិភ័យឥណទាន ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងឥទ្ធិពលនៃការដំឡើងអត្រាការប្រាក់សកល។ ធនាគារជាតិនៃកម្ពុជា បន្តចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានឥណទានជនបទ ក្នុងគោលបំណង៖ i/-ពង្រឹងការអនុលោមតាមបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា ii/-ធ្វើបច្ចុប្បន្នកម្មស្ថានភាពជាក់ស្តែង ចំពោះគ្រឹះស្ថានឥណទានជនបទដែលកំពុងធ្វើប្រតិបត្តិការ និង iii/-ធានាប្រសិទ្ធភាពនិងភាពរឹងមាំនៃវិស័យឥណទានជនបទ។

ជាលទ្ធផល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា នៅតែរក្សាបាននូវភាពធន់នៃសន្ទនីយភាពនិងដើមទុន មានអភិបាលកិច្ចល្អ ការគ្រប់គ្រងហានិភ័យឥណទានប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិបានល្អប្រសើរ។ ទោះយ៉ាងណា គ្រឹះស្ថានមួយចំនួននៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងអភិបាលកិច្ចគ្រឹះស្ថាន ការត្រួតពិនិត្យផ្ទៃក្នុងនិងការគ្រប់គ្រងហានិភ័យ ការផ្តល់ឥណទានជារូបិយវត្ថុជាតិ និងការមិនអនុវត្តបានពេញលេញតាមអនុសាសន៍ដែលដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ កង្វះខាតទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំ ដោយការតាមដាននិងវាយតម្លៃលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ប្រចាំត្រីមាសនីមួយៗ និងបានចេញលិខិតក្រើនរំឭកនិងពិន័យដល់គ្រឹះស្ថានដែលអនុវត្តមិនស្របតាមបទប្បញ្ញត្តិជាធរមាន ជាដើម។

- **ការងាររៀបចំបទប្បញ្ញត្តិ**

ដើម្បីពង្រឹងភាពធន់និងធានាវឌ្ឍនភាពនៅក្នុងប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាស និងសេចក្តីជូនដំណឹងមួយចំនួន ដើម្បីឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តដូចជា i/-ប្រកាស ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ii/-លិខិតជូនដំណឹងទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ស្តីពី ការអនុវត្តឡើងវិញនូវអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង iii/-លិខិតជូនដំណឹងទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្តីពី ការហាមឃាត់ទទួលយកអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅសម្រាប់ការធានាលើការផ្តល់ឥណទាន។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា កំពុងរៀបចំសេចក្ដីព្រាងប្រកាសមួយចំនួនស្របតាមស្តង់ដារបាសែល ៣ ដែលជាផ្នែកមួយនៃការអនុវត្តផែនការត្រួតពិនិត្យផ្អែកលើហានិភ័យ។ សេចក្ដីព្រាងប្រកាសទាំងនេះរួមមាន៖ i/-ប្រកាស ស្តីពី ក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ii/-ប្រកាស ស្តីពី នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iii/-ប្រកាស ស្តីពី ហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ព្រមទាំងសេចក្ដីណែនាំ ស្តីពី ការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃលើអ៊ីមភែរមិន។

លើសពីនេះ ការរៀបចំយន្តការនៃប្រព័ន្ធការពារប្រាក់បញ្ញើកំពុងត្រូវបានបន្តសិក្សា ដើម្បីការពារអ្នកដាក់ប្រាក់បញ្ញើនិងពង្រឹងជំនឿទុកចិត្តសាធារណជនលើប្រព័ន្ធធនាគារ។

## IV- **ការងារបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន**

### ១- **ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា**

បរិយាបន្នហិរញ្ញវត្ថុ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុផ្លូវការដល់ប្រជាជន និងអាជីវកម្ម ព្រមទាំងបានរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច។ ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមបន្ថែមនូវសកម្មភាពនិងយុទ្ធនាការនានា លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ កិច្ចការពារអតិថិជន ព្រមទាំងបានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នជាតិនិងអន្តរជាតិពាក់ព័ន្ធ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ស្របតាមផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ ២០១៩-២០២៥។ ជាក់ស្តែង ចំនួនគណនីប្រាក់បញ្ញើអតិថិជនមាន ១៦,៥ លានគណនី និងគណនីឥណទានមាន ៣,៨ លានគណនី។ ទីស្នាក់ការកណ្តាល និងសាខារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ២.៧២៤ ទីតាំង និងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៤.៧៥០ ក្នុងនោះ i/-គ្រឹះស្ថានធនាគារមានទីស្នាក់ការកណ្តាលនិងសាខាចំនួន ១.៥៤៨ ទីតាំង និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៤.៣៨៧ ii/-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានទីស្នាក់ការកណ្តាល និងសាខាចំនួន ១.១១១ ទីតាំង និង iii/-ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានទីស្នាក់ការកណ្តាល និងសាខាចំនួន ៦៥ ទីតាំង។

**ក្រាហ្វ ៦៩៖ ចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

(គិតជាគណនី, ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

## ២- ការអប់រំផ្នែកហិរញ្ញវត្ថុ

### - ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបញ្ចប់គម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ដំណាក់កាលទី២។ បន្ទាប់ពីបញ្ចប់ការបង្រៀនសាកល្បង ក្រុមការងាររបស់ស្ថាប័នទាំងពីរបានពិនិត្យឡើងវិញនូវខ្លឹមសារមេរៀន និងបានកែសម្រួលសៀវភៅគ្រូនិងសិស្សសម្រាប់ថ្នាក់ទី៤ និងថ្នាក់ទី៧ ទៅតាមមតិយោបល់កែលម្អដែលទទួលបានពីលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ ទម្រង់និងខ្លឹមសារនៃសៀវភៅទាំងនេះត្រូវបានឯកភាពនិងស្នើសុំក្រសួងអប់រំ យុវជន និងកីឡា ដាក់ឱ្យប្រើប្រាស់ក្នុងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាសម្រាប់ថ្នាក់ទាំង ២ នៅតាមសាលារៀនជាបណ្ដើរៗ មុននឹងសៀវភៅសម្រាប់ថ្នាក់ផ្សេងទៀត ត្រូវបានរៀបចំរួចរាល់។

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូ-ហិរញ្ញវត្ថុកម្ពុជា ក្នុងការរៀបចំឯកសារនិងសារគន្លឹះជាវីដេអូ ឬពាក្យស្លោក ដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការពង្រឹងការអនុវត្តទីផ្សារនិងកិច្ចការពារអតិថិជន។ ការផ្សព្វផ្សាយនេះត្រូវបានអនុវត្តរៀងរាល់ថ្ងៃចន្ទ សប្ដាហ៍ទី១ នៃខែនីមួយៗ។ លើសពីនេះ វគ្គបណ្ដុះបណ្ដាល ស្ដីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ សិទ្ធិ និងកិច្ចការពារអតិថិជន" ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការវាងធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាសម្រាប់ដល់ជនបង្គោលថ្នាក់ឃុំនិងថ្នាក់ភូមិចំនួន ៧០នាក់ មកពីខេត្តចំនួន៤រួមមាន ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង និងខេត្តបាត់ដំបង។ វគ្គបណ្ដុះបណ្ដាលនេះមានគោលបំណងលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ សិទ្ធិ និងកិច្ចការពារអតិថិជន តាមរយៈជនបង្គោល និងផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់ពួកគាត់ សំដៅបង្កើនលទ្ធភាពទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការប្រកបដោយសុវត្ថិភាព។

### - ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី

ការចែករំលែកចំណេះដឹងហិរញ្ញវត្ថុត្រូវបានធ្វើជាប្រចាំតាមរយៈការបន្តកិច្ចសហការជាមួយក្រសួងកិច្ចការនារី ដើម្បីការបណ្ដុះបណ្ដាលគ្រូបង្គោលដែលជាស្ត្រី នៅតាមសាលារៀន និងសហគមន៍នៃមូលដ្ឋានរបស់ខ្លួន លើប្រធានបទ៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រើប្រាស់សេវាហិរញ្ញវត្ថុ សេវាទូទាត់ឌីជីថល និងកិច្ចការពារអតិថិជន។ ការសហការនឹងបន្តពង្រឹងបន្ថែមទៀត ជាពិសេសក្នុងការរៀបចំវេទិកាពិភាក្សា ដើម្បីផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងផ្នែកឌីជីថលហិរញ្ញវត្ថុសម្រាប់បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច និងអភិវឌ្ឍសហគ្រិនភាពដល់ស្ត្រី។

- **យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់"**

យុទ្ធនាការជំណាក់កាលទី២ "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់" ត្រូវបានដាក់ឱ្យដំណើរការកាលពីខែធ្នូ ឆ្នាំ២០២១។ យុទ្ធនាការនេះ មានគោលដៅផ្តោតលើសារសំខាន់នៃការគិតគូរឱ្យបានដិតដល់ ការថ្លឹងថ្លែងអំពីជម្រើសផលិតផលនិងសេវាហិរញ្ញវត្ថុ ការយល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ច និងការចូលរួមធ្វើសេចក្តីសម្រេចរួមគ្នារវាងបុរសនិងស្ត្រីនៅក្នុងគ្រួសារ។ យុទ្ធនាការនេះធ្វើឡើងតាមវិធីសាស្ត្រ ៣ សំខាន់ៗៈ ១/-ការផ្សព្វផ្សាយតាមបណ្តាញសង្គមនូវខ្សែវីដេអូអប់រំខ្លីចំនួន ៤ វគ្គ រួមមាន វគ្គទី១ "ក្តីសុបិនសម្រាប់អនាគត" វគ្គទី២ "និយាយចេញមក" វគ្គទី៣ "អនុស្សាវរីយ៍កាលវ័យកុមារ" និង វគ្គទី៤ "ព្យុះជីវិត" ២/-ការផ្សព្វផ្សាយតាមកម្មវិធីវិទ្យុដោយមានការចូលរួមពីវាគ្មិន ដែលមានបទពិសោធន៍ផ្នែកអប់រំហិរញ្ញវត្ថុនិងការចូលរួមរបស់ប្រិយមិត្តអ្នកស្តាប់ និង ៣/-កម្មវិធីបណ្តុះបណ្តាលផ្ទាល់ជាមួយកម្មការិនីរោងចក្រ និងសហគ្រិនស្ត្រី ជាពិសេសនៅក្នុងរាជធានីភ្នំពេញ។ ការអនុវត្តយុទ្ធនាការនេះរួមបញ្ចូលនូវសកម្មភាពដូចជាៈ ការរៀបចំឯកសារបណ្តុះបណ្តាល ការបង្កើតមាតិកាអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការរៀបចំសិក្ខាសាលា ការបណ្តុះបណ្តាលគ្រូបង្គោល និងការផ្សព្វផ្សាយតាមបណ្តាញសង្គម ជាដើម។ ក្នុងឆមាសទី១ ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា និងអង្គការ Good Return បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលមកពីអង្គការនារីដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ដែលនឹងត្រូវចុះទៅបង្រៀនផ្ទាល់ដល់កម្មការនីរោងចក្រកាត់ដេរ ចាប់ពីត្រីមាសទី១ ដល់ត្រីមាសទី៣ ឆ្នាំ២០២៣។

- **ការចុះផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា"**

ធនាគារជាតិនៃកម្ពុជា បានបន្តកំណត់ផែនការចុះរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" សម្រាប់ឆ្នាំ២០២៣ ចំនួន ៦លើក ដោយក្នុងនោះសិក្ខាសាលាសម្រាប់ថ្នាក់ខេត្តចំនួន ២ លើក និងថ្នាក់ក្រុង/ស្រុកចំនួន ៤ លើក ក្នុងគោលដៅបន្តពង្រឹងចំណេះដឹងពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ និងធានាឱ្យមានការរីកចម្រើនប្រកបដោយប្រសិទ្ធភាព ស្ថិរភាព តម្លាភាព និងការពារអត្ថប្រយោជន៍ជូនប្រជាពលរដ្ឋ ដើម្បីសម្រេចបានគោលដៅរួមក្នុងការបន្តលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជំរុញបរិយាបន្នហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជន។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៣ ក្រុមការងារបានចុះផ្សព្វផ្សាយចំនួន ៣ លើក គឺស្រុកចំការលើ ខេត្តកំពង់ចាម ស្រុកថ្មគោល ខេត្តបាត់ដំបង និងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ និងកំពុងបន្តចុះផ្សព្វផ្សាយសិក្ខាសាលានេះទៅតាមផែនការដែលបានកំណត់ ដើម្បីឱ្យអាជ្ញាធរមូលដ្ឋានយល់ដឹង និងបន្តជួយសហការផ្សព្វផ្សាយពីចំណេះដឹងផ្នែកហិរញ្ញវត្ថុនេះនៅតាមមូលដ្ឋាននីមួយៗឱ្យបានកាន់តែផុលផុសឡើងថែមទៀត។

## ៣- កិច្ចការពារអតិថិជន និងយន្តការគ្រប់គ្រងការដោះស្រាយបណ្តឹង

ក្នុងឆមាសទី១ ឆ្នាំ២០២៣ បណ្តឹងនិងការសាកសួរព័ត៌មាន មានចំនួន ១៨៤ ករណី ដែលក្នុងនោះ ១៧៦ ករណី ដោះស្រាយរួចរាល់ ៤ ករណី កំពុងដោះស្រាយ និង ៤ ករណីស្ថិតក្នុងនីតិវិធីតុលាការ។ បណ្តឹងភាគច្រើនពាក់ព័ន្ធនឹង៖ i/-ការស្នើសុំបង់ផ្តាច់ឥណទានមុនកាលកំណត់ និងដកទ្រព្យធានា ii/-ការស្នើសុំកែប្រែព័ត៌មាន ឬលុបឈ្មោះចេញពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន iii/-ការស្នើសុំការអនុគ្រោះផ្សេងៗ iv/-ការស្នើសុំលើកលែងប្រាក់ពិន័យ v/-ការប្រើប្រាស់កម្ចីក្រៅផ្លូវការ និង vi/-ការសាកសួរព័ត៌មានផ្សេងៗអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ ជាដើម។ ស្របពេលគ្នានេះដែរ ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកហាតឡាញ តាមរយៈការរៀបចំវគ្គចែករំលែកចំណេះដឹង ស្តីពី វឌ្ឍនភាពនៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា និងការរៀបចំបច្ចុប្បន្នភាព "កម្រងឯកសារជំនួយស្មារតីសម្រាប់មន្ត្រីទទួលបន្ទុកហាតឡាញ" ដើម្បីជាមូលដ្ឋានក្នុងការផ្តល់ចម្លើយនិងដំណោះស្រាយដែលត្រឹមត្រូវចំពោះរាល់សំនួរដែលទទួលបានតាមលេខទូរស័ព្ទហាតឡាញ ខណៈដែលយន្តការគ្រប់គ្រងនិងដោះស្រាយបណ្តឹងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានពង្រឹងជាប្រចាំ។ ទន្ទឹមនេះ ដើម្បីលើកកម្ពស់និងពង្រឹងកិច្ចការពារអតិថិជននៅកម្ពុជា ធនាគារជាតិនៃកម្ពុជា ក៏បានចេញសេចក្តីប្រកាសព័ត៌មាននានា រួមមាន៖

- សេចក្តីប្រកាសព័ត៌មាន ស្តីពី ការឆបោកប្រាក់តាមបណ្តាញសង្គម និងប្រព័ន្ធទូរស័ព្ទ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ដើម្បីផ្សព្វផ្សាយជូនសាធារណជនបានជ្រាប និងមានការប្រុងប្រយ័ត្នខ្ពស់អំពីការឆបោកប្រាក់តាមគ្រប់រូបភាព នៅតាមបណ្តាញសង្គម (Telegram, Facebook និង Tiktok ជាដើម) ក៏ដូចជាតាមប្រព័ន្ធទូរស័ព្ទ ខណៈពេលដែលបច្ចេកវិទ្យាឌីជីថលនៅកម្ពុជាកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និង

- សេចក្តីប្រកាសព័ត៌មានរួមរវាងធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ស្តីពី ការអនុវត្តច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ និងប្រកាសស្តីពី ខសន្យាមិនសុចរិត ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់ ទប់ស្កាត់ការបង្កើតទម្រង់ស្តង់ដារនៃកិច្ចសន្យាដែលមិនសុចរិត និងមានលក្ខណៈកេងចំណេញពីអ្នកប្រើប្រាស់។

ក្នុងការចូលរួមទប់ស្កាត់សកម្មភាពប្រតិបត្តិការធនាគារមិនស្របច្បាប់ និង/ឬ មិនមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ធនាគារជាតិនៃកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ បាន និងកំពុង i/-ស្រាវជ្រាវ តាមដាន កំណត់មុខសញ្ញា និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារមិនស្របច្បាប់ ឬមិនមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ii/-រៀបចំផែនការ ឬវិធានការដោះស្រាយទៅលើក្រុមហ៊ុន ឬបុគ្គលដែលធ្វើប្រតិបត្តិការធនាគារដោយគ្មានច្បាប់អនុញ្ញាត និង iii/-ចុះប្រតិបត្តិការដល់ទីកន្លែង ដើម្បីប្រមូលភស្តុតាង និងចាត់វិធានការចំពោះក្រុមហ៊ុន ឬ បុគ្គលល្មើសច្បាប់។ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញសេចក្តីថ្លែងការណ៍រួម ក្រោមបរិបទនៃការបង្ក្រាបសកម្មភាពផ្សព្វផ្សាយ និងផ្តល់ឥណទានដោយខុសច្បាប់ សំដៅចូលរួមទប់ស្កាត់បទល្មើសនានាឱ្យទាន់ពេលវេលា ដែលអាចបង្កជាហានិភ័យចំពោះគ្រឹះស្ថាន អតិថិជន និងប្រព័ន្ធធនាគារទាំងមូល។ ទន្ទឹមនេះ កិច្ចសហការក្នុងការទប់ស្កាត់ចំពោះក្រុមហ៊ុនខុសច្បាប់ ដែលបានផ្សព្វផ្សាយលើគេហទំព័រហ្វេសប៊ុកកំពុងផ្សព្វផ្សាយអំពីការផ្តល់សេវាឥណទាន និងសេវាធនាគារផ្សេងទៀត ដែលមិនមានច្បាប់អនុញ្ញាតត្រឹមត្រូវក៏ត្រូវបានពង្រឹងជាបន្តបន្ទាប់ផងដែរ។

## V- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ១- ប្រព័ន្ធទូទាត់សងប្រាក់

នវានុវត្តន៍នៃប្រព័ន្ធទូទាត់សងប្រាក់បាននិងកំពុងរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធទូទាត់ជាបន្តបន្ទាប់ ដូចជា ប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធសេវាទូទាត់រហ័ស និងប្រព័ន្ធខេមបូឌានស៊ែស្វីច ដោយបានធ្វើបច្ចុប្បន្នកម្ម និងបន្ថែមមុខងារចាំបាច់មួយចំនួន ក្នុងគោលបំណងសម្រួលដល់គ្រឹះស្ថានជាសមាជិក និងអ្នកប្រើប្រាស់ ក៏ដូចជាឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ នៅឆមាសទី១នេះ ប្រព័ន្ធទូទាត់សងប្រាក់មានប្រតិបត្តិការប្រមាណ ៣០,៣ លានប្រតិបត្តិការ កើនឡើង ១,៦ដង និងទំហំប្រាក់ប្រតិបត្តិការមានប្រមាណ ៨៩,៧ ប៊ីលានដុល្លារអាមេរិក កើនឡើង ៣,៦% ស្មើនឹងប្រមាណ ៣ដងនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។

ដើម្បីគាំទ្រដល់គោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមលើកកម្ពស់ការទូទាត់ឌីជីថលជាមួយវិស័យសាធារណៈ តាមរយៈការពង្រីកមុខងារប្រព័ន្ធបាគងសម្រាប់គាំទ្រដល់ការទូទាត់សេវាសាធារណៈជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយបានអភិវឌ្ឍមុខងារសម្រាប់ទូទាត់បង់ពន្ធដារ បើកប្រាក់បៀវត្ស ប្រាក់សោធននិវត្តន៍ ច្រកទូទាត់ក្នុងផ្សារពាណិជ្ជកម្មអេឡិចត្រូនិក និងច្រកសម្រាប់ផ្តល់មូលនិធិគាំទ្រដល់ជនក្រីក្រ កុមារកំព្រា និងទ្រទ្រង់គ្រោះមហន្តរាយផ្សេងៗ ជាដើម។ ទន្ទឹមនេះ មុខងារថ្មីមួយទៀតដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីខែកុម្ភៈ ឆ្នាំ២០២៣ គឺអតិថិជនដែលបានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគងដោយមានអត្តសញ្ញាណពេញលេញ (Full KYC) អាចស្វែងរកព័ត៌មានអំពីការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ខ្លួនបានយ៉ាងងាយស្រួលនៅក្នុងកម្មវិធីទូទាត់បាគង ទោះបីជាពុំបានយកប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ មកតាមខ្លួនក៏ដោយ។

ជាមួយគ្នានេះ ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុក៏បានផ្តល់ឱកាសឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនការប្រកួតប្រជែងដើម្បីទាក់ទាញអតិថិជន ជាពិសេសតាមរយៈការដាក់ឱ្យប្រើប្រាស់សេវា និងឧបករណ៍ទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍។ ក្នុងនោះការទូទាត់តាម KHQR Code ទទួលបានការពេញនិយមគួរឱ្យកត់សម្គាល់ ដោយគិតត្រឹមខែមេសា ឆ្នាំ២០២៣ ចំនួនប្រតិបត្តិការទូទាត់តាម KHQR Code មានការកើនឡើងជាលំដាប់ក្នុងនោះប្រតិបត្តិការជារៀលមានចំនួន ១៦៩.១៩៥ ប្រតិបត្តិការ គិតជាប្រាក់មានចំនួន ៩៧ ប៊ីលានរៀល និងប្រតិបត្តិការជាដុល្លារមានចំនួន ២១៦.០៦៨ ប្រតិបត្តិការ គិតជាប្រាក់មានចំនួន ៣៨ លានដុល្លារអាមេរិក។

ទន្ទឹមនោះ ក្នុងគោលបំណងពង្រឹងកិច្ចសហការលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ឆ្លងដែន ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាមួយប្រទេសមួយចំនួនក្នុងតំបន់ដូចជា ប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសឡាវ និងប្រទេសវៀតណាម ហើយក៏បានពង្រឹងផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ជាមួយប្រទេសហ្វីជី

កោះសូឡូម៉ូន និងប្រទេសវ៉ាន់ដា ដើម្បីចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងនវានុវត្តន៍ និងការទូទាត់តាមបែបឌីជីថលសម្រាប់សេវាកម្មហិរញ្ញវត្ថុរវាងគ្នានិងគ្នាផងដែរ។

នៅក្នុងវិស័យទូទាត់សងប្រាក់ សេវាទូទាត់ឌីជីថលបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការដាក់ចេញនូវផលិតផល និងសេវាថ្មីៗ ដែលផ្តល់ភាពងាយស្រួល និងសុវត្ថិភាពដល់អ្នកប្រើប្រាស់។ ការរីកចម្រើនទាំងនេះអាចសម្រេចទៅបានដោយសារការដាក់ចេញបទប្បញ្ញត្តិដែលមានភាពអំណោយផលដល់ការប្រកួតប្រជែងរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងយន្តការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់របស់ធនាគារជាតិនៃកម្ពុជាកន្លងមក។ លើសពីនេះ ដើម្បីសម្រួលដល់ការអនុលោមតាមគោលនយោបាយប្រព័ន្ធខេមបូឌានស៊ែស្វីច លើការអភិវឌ្ឍប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ប័ណ្ណស្តង់ដារ EMV-Chip ស្តង់ដារ CSS-BIN និងការពង្រឹងសុវត្ថិភាពលើម៉ាស៊ីន ATM/POS ធនាគារជាតិនៃកម្ពុជាបានបន្តពន្យារពេលការអនុលោមតាមគោលនយោបាយសម្រាប់ប្រព័ន្ធ ជូនគ្រឹះស្ថានជាសមាជិក រហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៣ ដូចមានចែងក្នុងសេចក្តីជូនដំណឹងលេខ ធ១៥.០២៣.១២៧.ស.ជ.ណ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣។ នាពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាក៏បានចេញសេចក្តីជូនដំណឹងស្តីពី ការអភិវឌ្ឍបន្ថែមមុខងារ Contactless លើប្រព័ន្ធខេមបូឌានស៊ែស្វីច ក្នុងគោលបំណងធានាប្រសិទ្ធភាពនៃការដាក់ឱ្យដំណើរការមុខងារថ្មីនេះនៅលើទីផ្សារ។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៣ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់សរុបចំនួន ៣៥ ទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ២ ទទួលបានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដែលក្នុងនោះមានអតិថិជនចុះឈ្មោះបង្កើតគណនីអ៊ីវ៉ាឡេតសរុបប្រមាណ ២០,២ លានគណនី។ ជាមួយគ្នានេះ ប្រតិបត្តិការទូទាត់សងប្រាក់បានកើនឡើងប្រមាណ ៥៨% ពី ២១១,១ ទៅ ៣៣៣,៧ លានប្រតិបត្តិការ និងមានទំហំទឹកប្រាក់កើនឡើងប្រមាណ ៩៨,៣% ពី ២៩,៣ ទៅ ៥៨,២ ប៊ីលានដុល្លារអាមេរិក ធៀបនឹងដូចគ្នាឆ្នាំមុន ស្មើប្រមាណ ១៩៧,៨% នៃផ.ស.ស។

ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលអភិវឌ្ឍដោយធនាគារជាតិនៃកម្ពុជាចែកជា ២ប្រភេទ គឺប្រព័ន្ធទូទាត់តម្លៃធំ និងប្រព័ន្ធទូទាត់រាយ៖

**ក- ប្រព័ន្ធទូទាត់តម្លៃធំ**

**- ប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS)** ជាប្រព័ន្ធដែលអនុញ្ញាតឱ្យសមាជិក៖ i/- បង់កម្រៃសេវាចូលគណនីចំណូលរបស់ធនាគារជាតិនៃកម្ពុជា ii/-អាចពិនិត្យសមតុល្យគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា និង iii/-ធ្វើការផ្ទេរប្រាក់ដោយខ្លួនឯងរវាងគណនីនៅស្នាក់ការកណ្តាល (មិនត្រូវបានគិតកម្រៃសេវា) លើកលែងតែការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលនិងគណនីនៅសាខារាជធានី-ខេត្ត ដែលត្រូវបានគិតកម្រៃសេវា ០,១% នៃចំនួនប្រាក់ផ្ទេរ ដោយកម្រៃអប្បបរមាត្រឹម ១២ ពាន់រៀល និងអតិបរមាមិនលើសពី ៤ លានរៀល។ ដោយឡែក ការផ្ទេរប្រាក់ដែលជាថវិការដ្ឋមិនត្រូវបានគិតកម្រៃសេវាទេ។ ក្នុងឆមាសទី១ ឆ្នាំ២០២៣ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS សរុបមានចំនួន ១៨០ ទ្រីលានរៀល (៣០.១៧៩ ប្រតិបត្តិការ) កើនឡើង ១,២% ក្នុងនោះការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលជាប្រាក់រៀលមានចំនួន ៥៣,៧ ទ្រីលានរៀល (១៩.០០៩ ប្រតិបត្តិការ)

កើនឡើង ១៥% និងជាប្រាក់ដុល្លារអាមេរិកមានចំនួន ២៩,៩ ប៊ីលានដុល្លារអាមេរិក (១០.៧១៨ ប្រតិបត្តិការ) ថយចុះ -៤,៧% និងការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត ជាប្រាក់រៀលមានចំនួន ២,១ ទ្រីលានរៀល (២៤០ ប្រតិបត្តិការ) កើនឡើង ៩១,៣% និងជាប្រាក់ដុល្លារអាមេរិកចំនួន ៤៩៨,២ លានដុល្លារអាមេរិក (២១២ ប្រតិបត្តិការ) ថយចុះ -២៨,១%។ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS បានកើនឡើងជាបន្តបន្ទាប់ ទាំងទំហំប្រតិបត្តិការ និងទំហំប្រាក់ ដោយសារមានការលើកទឹកចិត្តឱ្យម្ចាស់គណនីប្រើប្រាស់ប្រព័ន្ធ OBS នេះ ជំនួសឱ្យការប្រើប្រាស់មូលប្បទានប័ត្រក្នុងការទូទាត់ ឬផ្ទេរប្រាក់ ដើម្បីសម្រួលដល់ការទូទាត់កាន់តែឆាប់រហ័ស និងស្របតាមការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ជាអេឡិចត្រូនិករបស់ធនាគារជាតិនៃកម្ពុជា។

**-ប្រព័ន្ធទូទាត់តម្លៃធំបាគង (Bakong LVPS)៖** ប្រព័ន្ធនេះកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍ ដើម្បីសម្រួលការទូទាត់ ចំពោះប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំអន្តរធនាគារ ប្រតិបត្តិការទូទាត់សមតុល្យសុទ្ធរបស់ប្រព័ន្ធទូទាត់រាយ និងប្រតិបត្តិការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ។

**ខ- ប្រព័ន្ធទូទាត់រាយ** រួមមាន៖ i/-ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ii/-ប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី (FAST 2.0) iii/-ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) iv/-ប្រព័ន្ធរីថៃលផេ (Retail Pay) និង v/-ប្រព័ន្ធបាគង។

**១. ប្រព័ន្ធផាត់ទាត់ជាតិ (NCS)** មានសមាជិកសរុបចំនួន ៦០ (សមាជិកផ្ទាល់ចំនួន ៤៣ និងសមាជិកមិនផ្ទាល់ចំនួន ១៧) និងមានមណ្ឌលដោះដូរមូលប្បទានប័ត្រចំនួន ៧ ទីតាំង សម្រាប់បម្រើការងារដោះដូរមូលប្បទានប័ត្រជារូបវន្តដែលមានទីតាំងនៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តសៀមរាប បាត់ដំបង កំពង់ចាម ព្រះសីហនុ បន្ទាយមានជ័យ ស្វាយរៀង និងកំពង់ធំ។ ប្រព័ន្ធ NCS បាននិងកំពុងដាក់ឱ្យដំណើរការឧបករណ៍ទូទាត់ ២ ប្រភេទគឺ មូលប្បទានប័ត្រ និងបញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក។

**- សេវាទូទាត់មូលប្បទានប័ត្រ៖** ការទូទាត់មូលប្បទានប័ត្រជាប្រាក់រៀលមាន ១១,៥ ទ្រីលានរៀល (១៧.១០២ សន្លឹក) ដែលបានកើនឡើង ១៨,៦% ហើយការទូទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមាន ២២,៨ ប៊ីលានដុល្លារអាមេរិក (៥២៦.៣០៨ សន្លឹក) ដែលបានថយចុះ -១៦,២% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។

**ក្រាហ្វ ៧០៖ ចំនួនមូលប្បទានប័ត្រជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**

(ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




**ក្រាហ្វ ៧១៖ ចំនួនប្រាក់មូលប្បទានប័ត្រជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**

(ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧២៖ ចំនួនមូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**

(ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




**ក្រាហ្វ ៧៣៖ ទំហំទឹកប្រាក់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**

(ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**- សេវាទូទាត់បញ្ជាផ្ទេរឥណទាន៖** ប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀល មិនមានការប្រែប្រួលដែលមានទឹកប្រាក់សរុប ២,៦ ទ្រីលានរៀល (១៣.០៩៦ ប្រតិបត្តិការ) និងបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិកកើនឡើង ៤,៨% គិតជាទឹកប្រាក់សរុបមាន ៦,៦ ប៊ីលានដុល្លារអាមេរិក (៣៣១.៥៣៧ ប្រតិបត្តិការ)។

**ក្រាហ្វ ៧៤៖ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**

(ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




**ក្រាហ្វ ៧៥៖ ទំហំទឹកប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**

(ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៦៖ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**

(ឆមាសទី១ ឆ្នាំ២០១៧ -ឆមាសទី១ ឆ្នាំ២០២៣)




**ក្រាហ្វ ៧៧៖ ទំហំទឹកប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**

(ឆមាសទី១ ឆ្នាំ២០១៧ - ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**២. ប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី** (FAST 2.0) មានសមាជិកសរុបចំនួន ៥៧ ក្នុងនោះសមាជិកដែលកំពុងដំណើរការមានចំនួន ៣៥។ ប្រព័ន្ធសេវាទូទាត់រហ័សបានដំណើរការទូទាត់ប្រតិបត្តិការផ្ទេរប្រាក់ចំនួន ២២,២ ប៊ីលានរៀល (១២.២០៦ ប្រតិបត្តិការ) ដែលបានថយចុះ -២៤% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។

**៣. ប្រព័ន្ធខេមបូឌានស៊ែស្វីច** (CSS) មានសមាជិកសរុបចំនួន ៥៩ ក្នុងនោះសមាជិកមិនផ្ទាល់ចំនួន ២ និងកំពុងដំណើរការបឋមចំនួន ៤០។ ប្រព័ន្ធ CSS បានដំណើរការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់រៀលថយចុះ -២១,៤% គិតជាទឹកប្រាក់សរុបនៅត្រឹមចំនួន ៣៦,៧ ប៊ីលានរៀល (១៥៨.៩៣០ ប្រតិបត្តិការ) និងជាប្រាក់ដុល្លារអាមេរិកថយចុះ -៣៥,៨% គិតជាទឹកប្រាក់សរុបនៅត្រឹមចំនួន ៤,៣ លានដុល្លារអាមរិក (៣១.៥៥០ ប្រតិបត្តិការ)។

**៤. ប្រព័ន្ធរីថែលផេ** (Retail Pay) មានសមាជិកសរុបចំនួន ២៤ គ្រឹះស្ថាន ក្នុងនោះមានសមាជិកចំនួន ១៦ កំពុងដំណើរការផ្លូវការ។ ប្រព័ន្ធនេះបានដំណើរការទូទាត់ប្រតិបត្តិការផ្ទេរមូលនិធិជាប្រាក់រៀលកើនឡើង ៧,២% គិតជាទឹកប្រាក់សរុបនៅត្រឹមចំនួន ២៨០,២ ប៊ីលានរៀល (៩.៨៨២ ប្រតិបត្តិការ) និងជាប្រាក់ដុល្លារអាមេរិកកើនឡើង ១០% គិតជាទឹកប្រាក់សរុបដល់ចំនួន ១៣០,១ លានដុល្លារអាមេរិក (២៣.៧៤០ ប្រតិបត្តិការ)។

**៥. ប្រព័ន្ធបាគង** (Bakong) មានសមាជិកសរុបចំនួន ៧០ ដោយក្នុងនោះមានសមាជិកចំនួន ៤៩ កំពុងដំណើរការជាផ្លូវការ។ ប្រព័ន្ធបាគង មានប្រតិបត្តិការជាប្រាក់រៀលសរុបចំនួន ១១,៥៩ លានប្រតិបត្តិការ (កើនឡើង ៤,៧ដង) គិតជាទឹកប្រាក់សរុបចំនួន ១២,២៤ ទ្រីលានរៀល (កើនឡើង ១,៨ដង) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកចំនួន ២១,៣២ លានប្រតិបត្តិការ (កើនឡើង ១,៦ដង) គិតជាទឹកប្រាក់សរុបចំនួន ៨,៧០ ប៊ីលានដុល្លារអាមេរិក (កើនឡើង ៨៣,០២%)។

## ២- សេវាគ្រប់គ្រងគណនី

ធនាគារជាតិនៃកម្ពុជា គ្រប់គ្រងគណនីសរុប ២.៨៨២ (ស្នាក់ការកណ្ដាល ២.១៩៧[៤៥] គណនី និងតាមបណ្ដាសាខាខេត្ត ៦៨៥[៤៦] គណនី) បានកើនឡើងចំនួន ១៩៧ គណនី ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ដោយសារការបើកគណនីថ្មីរបស់ស្ថាប័នរដ្ឋ ៣៦ គណនី (សម្រាប់អនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍ និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្នុងការទទួលថវិកាផ្ទាល់ពីអគ្គនាយកដ្ឋានរតនាគារជាតិ) គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៥៣ គណនី និងអង្គភាពផ្សេងៗ ៨ គណនី។

## ៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ

### ក- ប្រតិបត្តិការសាច់ប្រាក់របស់បេឡា

ការទទួល និងការបើកប្រាក់រៀលមានចំនួន ៨,២ ទ្រីលានរៀល (កើន ៥,៨%) និង ៩,២ ទ្រីលានរៀល (កើន ២៩,៩%) រៀងគ្នា។ ចំណែកឯការទទួល និងការបើកប្រាក់ដុល្លារអាមេរិកមានចំនួន ៦,៥ ប៊ីលានដុល្លារអាមេរិក (ថយ -១០,៥%) និង ៣,១ ប៊ីលានដុល្លារអាមេរិក (ថយ -១៣,៨%) រៀងគ្នា។

**ក្រាហ្វ ៧៨៖ ការទទួលនិងការបើកប្រាក់រៀល**

(គិតជាប៊ីលានរៀល, ឆមាសទី១ ឆ្នាំ២០២១-ឆមាសទី១ ឆ្នាំ២០២៣)




**ក្រាហ្វ ៧៩៖ ការទទួលនិងការបើកប្រាក់ដុល្លារអាមេរិក**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០២១-ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ធនាគារជាតិនៃកម្ពុជា

### ខ- ការងារគ្រប់គ្រងសាច់ប្រាក់

ការផ្គត់ផ្គង់ក្រដាសប្រាក់ថ្មីគ្រប់ប្រភេទនិងការប្រមូលក្រដាសប្រាក់ចាស់ ទក់ រហែកត្រូវបានអនុវត្តជាប្រចាំ ដើម្បីបំពេញតម្រូវការសាធារណជន ស្របពេលដែលការពង្រឹងសោភ័ណភាពនិងគុណភាពក្រដាសប្រាក់ត្រូវបានបន្តយកចិត្តទុកដាក់ដើម្បីទប់ស្កាត់ការក្លែងបន្លំក្រដាសប្រាក់ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

ការផ្គត់ផ្គង់ប្រាក់រៀលទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និងការដឹកជញ្ជូនប្រាក់រៀលចាស់និងលើសពីតម្រូវការមកស្នាក់ការកណ្ដាលវិញបានកើនឡើង ២២,៣% និង ៣,៣% រៀងគ្នា។ ចំណែកឯការផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិកទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានថយចុះ -១៧,៩% ខណៈដែលការដឹកជញ្ជូនប្រាក់ដុល្លារអាមេរិកមកស្នាក់ការកណ្ដាលវិញ បានកើនឡើង ៩៦,៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០២២។

---

[៤៥] ស្ថាប័នរដ្ឋ ១.០០៨ គណនី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ១.១៤៩ គណនី និងអង្គភាពផ្សេងៗ ៤០ គណនី។

[៤៦] ស្ថាប័នរដ្ឋ ១១២ គណនី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥៥៧ គណនី និងអង្គភាពផ្សេងៗ ១៦ គណនី។

**ក្រាហ្វ ៨០៖ ប្រាក់រៀលដឹកទៅ-មកសាខាធនាគារជាតិនៃកម្ពុជា**
(គិតជាប៊ីលានរៀល, ឆមាសទី១ ឆ្នាំ២០២១-ឆមាសទី១ ឆ្នាំ២០២៣)




**ក្រាហ្វ ៨១៖ ប្រាក់ដុល្លារអាមេរិកដឹកទៅ-មកសាខាធនាគារជាតិនៃកម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០២១-ឆមាសទី១ ឆ្នាំ២០២៣)




ប្រភព៖ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២វគ្គ ស្តីពី "ការពិនិត្យវិនិច្ឆ័យលើក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ" ដោយបានសហការរៀបចំជាមួយក្រុមហ៊ុនដឹកជញ្ជូនសាច់ប្រាក់ Travelex និងជាមួយធនាគារ Moneycorp ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រីធនាគារជាតិនៃកម្ពុជា និងបុគ្គលិកគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការពិនិត្យក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ និងចៀសវាងបាននូវការខាតបង់ជាយថាហេតុ។

## គ- ការផ្សព្វផ្សាយពីសារៈសំខាន់នៃប្រាក់រៀល

នៅឆមាសទី១នេះ ការយល់ដឹងរបស់សាធារណជន អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលត្រូវបានបន្តលើកកម្ពស់ឱ្យកាន់តែទូលំទូលាយជាមួយកម្មវិធីផ្សព្វផ្សាយស្តីពី ប្រាក់រៀល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធបាគង ដែលត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ និងខេត្តចំនួន ៣ រួមមានខេត្តកំពង់ស្ពឺ ព្រះសីហនុ និងកំពង់ធំ (នៅស្រុកស្ទោង និងស្រុកសន្ទុក) ដោយមានការចូលរួមពីមន្ត្រីរាជការ តំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សិស្សានុសិស្ស និងសាធារណជនទូទៅ។ កម្មវិធីផ្សព្វផ្សាយនេះ បានទាក់ទាញសាធារណជនយ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយចំនួនអ្នកចូលរួមសរុបមានរហូតដល់ប្រមាណជាង ១៣ ពាន់នាក់ និងអ្នកទស្សនាការផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាមានប្រមាណជាង ៩០ ពាន់នាក់។ កម្មវិធីផ្សព្វផ្សាយនេះផ្តោតលើសកម្មភាពសំខាន់ៗ ដូចជា៖ ការយកក្រដាសប្រាក់រៀលចាស់ ទក់ ឬ រហែក ប្តូរយកក្រដាសប្រាក់រៀលថ្មីដោយឥតគិតថ្លៃ ការតាំងពិព័រណ៍ស្តីពីប្រព័ន្ធរូបិយវត្ថុកម្ពុជាតាំងពីសតវត្សរ៍ទី១នៃអាណាចក្រហ្វូណនរហូតដល់បច្ចុប្បន្ន ការតាំងបង្ហាញប្រព័ន្ធទូទាត់បាគង និងការផ្សព្វផ្សាយផលិតផលនិងសេវាហិរញ្ញវត្ថុជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ក្នុងអំឡុងពេលផ្សព្វផ្សាយនោះ សាធារណជនបានយកចាស់ ទក់ រហែកមកប្តូរសរុបទឹកប្រាក់ប្រមាណ ១,២ ប៊ីលានរៀល បើកគណនីបាគង និងគណនីតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា ព្រមទាំងទទួលបានសារអប់រំបណ្តុះគំនិតឱ្យកាន់តែស្រលាញ់និងប្រើប្រាស់ប្រាក់រៀលថែមទៀត។

## VI- ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

សមិទ្ធផលសំខាន់នៅក្នុងឆមាសទី១ ឆ្នាំ២០២៣ របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) គឺចូលរួមចំណែកដ៏សំខាន់ក្នុងការអនុវត្តផែនការសកម្មភាព ដើម្បីដកកម្ពុជាចេញពី "**បញ្ជីប្រផេះ**" របស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force – FATF)។ ដើម្បីសម្រេចបានសមិទ្ធផលនេះ ស.ហ.ក. បានខិតខំអនុវត្ត និងសហការការងារជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ព្រមទាំងបានសម្របសម្រួលការងារជាមួយក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (Asia/Pacific Group on International Cooperation Review Group – Joint Group – (ICRG-JG)) ប្រកបដោយភាពជោគជ័យ រហូតដល់អង្គមហាសន្និបាត FATF សម្រេចដកកម្ពុជាចេញពី**បញ្ជីប្រផេះ** នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ និងទទួលបានការកោតសរសើរពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

ទន្ទឹមនេះ ស.ហ.ក. ក៏បាននិងកំពុងពង្រឹងកាតព្វកិច្ចអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពង្រឹងសហប្រតិបត្តិការជាតិនិងអន្តរជាតិ និងដឹកនាំអនុគណៈកម្មការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.) ផងដែរ។

### ១- ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

តាមរយៈការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ (Risk Based Supervision – RBS) ស.ហ.ក.បានវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍នីមួយៗ ហើយលទ្ធផលនៃការវាយតម្លៃ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង។ ស.ហ.ក. បានត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន ២ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ២ ដោយបានរកឃើញមានចំណុចខ្វះខាតមួយចំនួន និងបានផ្តល់អនុសាសន៍កែតម្រូវ។

ចំពោះការងារត្រួតពិនិត្យលើឯកសារ ស.ហ.ក. ក៏បានយកចិត្តទុកដាក់លើការវាយតម្លៃគុណវុឌ្ឍិរបស់មន្ត្រីប្រតិបត្តិការតាមដានលទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុងនិងសវនកម្មផ្ទៃក្នុង លទ្ធផលនៃការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងវឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍ត្រួតពិនិត្យដល់ទីកន្លែង ជាដើម។ ស.ហ.ក. បានទទួលស្គាល់មន្ត្រីប្រតិបត្តិចំនួន ៦៣រូប មកពីធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនអចលនទ្រព្យ កាស៊ីណូ ជាដើម។

លើសពីនេះ ក្នុងការពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិរបស់បុគ្គលរាយការណ៍ ស.ហ.ក. បានចេញលិខិតព្រមានចំពោះគ្រឹះស្ថានចំនួន ៥៤ ដែលពុំបានអនុវត្តឱ្យបានពេញលេញស្របតាមការតម្រូវនៃច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ២- ការខារវិភាគនិងបញ្ជូនរបាយការណ៍

ស.ហ.ក. បានបន្តតាមដានជាប្រចាំនូវការអនុវត្តកាតព្វកិច្ចរាយការណ៍ប្រតិបត្តិការសាច់ប្រាក់និងប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍។ ការរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ថយចុះ ១៩,៥% ហើយការរាយការណ៍ប្រតិបត្តិការសង្ស័យបានកើនឡើង ១៥,៧% ធៀបនឹងឆមាសទី១ ឆ្នាំ២០២២។ ទន្ទឹមនេះ ស.ហ.ក. បានភ្ជាប់ប្រព័ន្ធរាយការណ៍ប្រតិបត្តិការដល់គ្រឹះស្ថានចំនួន ៩៥ ដោយតម្រូវឱ្យគ្រឹះស្ថានទាំងនោះរាយការណ៍ប្រតិបត្តិការឱ្យបានទាន់ពេលវេលា និងមានគុណភាពខ្ពស់។

## ៣- កិច្ចសហប្រតិបត្តិការ

### ក- កិច្ចសហប្រតិបត្តិការក្នុងស្រុក

កម្ពុជាបានរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារពិភពលោក។ ស.ហ.ក. ដឹកនាំកិច្ចប្រជុំអនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.) ចំនួន ៣លើក ដោយមានសមាសភាពចូលរួមមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ២២ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារនិងបញ្ហាប្រឈមរបស់ក្រុមការងារក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ជាលទ្ធផល ក្រុមការងាររបស់ក្រសួង-ស្ថាប័ននីមួយៗ បានចាប់ផ្តើមដំណើរការការងាររបស់ខ្លួនក្នុងការប្រមូលទិន្នន័យ ដើម្បីវិភាគ និងវាយតម្លៃកម្រិតហានិភ័យ ភាពងាយរងគ្រោះ និងការគំរាមកំហែងតាមវិស័យនីមួយៗមុននឹងបញ្ចូលលទ្ធផលសម្រេចទៅក្នុងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ។

### ខ- កិច្ចសហប្រតិបត្តិការអន្តរជាតិ

**ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (Asia/Pacific Group on Money Laundering-APG)៖** កម្ពុជាបានបន្តកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តតាមអនុសាសន៍របស់ APG ដែលមាននៅក្នុងរបាយការណ៍វាយតម្លៃអញ្ញមញ្ញ (Mutual Evaluation Report – MER) កាលពីឆ្នាំ២០១៧។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៣ នេះ កម្ពុជាបានរៀបចំរបាយការណ៍វឌ្ឍនភាព (Follow-Up Reports – FUR) នៃការវិវត្តផ្ទៃកគតិយុត្ត ចំនួន ៦លើក ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តកម្រិតខ្ពស់របស់កម្ពុជាក្នុងការកែលម្អក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិស្របតាមអនុសាសន៍របស់ APG។ របាយការណ៍វឌ្ឍនភាពលើកទី ៦ (6th FUR) កម្ពុជាកំពុងស្ថិតនៅក្នុងដំណើរការវាយតម្លៃនៅឡើយ។ ទន្ទឹមនេះ កម្ពុជាបានរួមចំណែកផ្តល់ធាតុចូលតាមការចាំបាច់មួយចំនួនជាមួយ APG លើគម្រោងនានាពាក់ព័ន្ធនឹងការកែលម្អស្តង់ដារផងដែរ។

មិនតែប៉ុណ្ណោះ ដើម្បីទទួលបានបទពិសោធន៍និងឧត្តមានុវត្តល្អៗ កម្ពុជាក៏បានចូលរួមជាប្រចាំជាមួយក្រុមការងារនានារបស់ APG ដូចជា៖ ១/- គណៈកម្មការអភិបាលកិច្ច ២/- គណៈកម្មការវាយតម្លៃអញ្ញមញ្ញ ៣/- ការកាត់បន្ថយផលប៉ះពាល់ពីការអនុវត្តអនុសាសន៍របស់ FATF ៤/- ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ របស់ APG ៥/- លទ្ធផលការងារប្រចាំត្រីមាសរបស់ FATF និង ៦/- កិច្ចប្រជុំក្រុមការងារផ្សេងៗ និងមហាសន្និបាតរបស់ FATF ជាដើម។

**ក្រុមអ៊ិកម៉ុង (The EGMONT Group)៖** ក្នុងនាមជាសមាជិករបស់ក្រុមអ៊ិកម៉ុង ស.ហ.ក. បានចូលរួមកិច្ចប្រជុំក្រុមការងាររបស់ក្រុមអ៊ិកម៉ុង ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣០ ខែមករា ដល់ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣ នៅទីក្រុងដាកា ប្រទេសសេណេហ្គាល់។ កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិភាក្សាពីវឌ្ឍនភាពគម្រោងសិក្សារបស់ក្រុមការងារនីមួយៗ រួមមាន៖ ១/- ក្រុមការងារផ្លាស់ប្ដូរព័ត៌មាន ២/- ក្រុមការងារជំនួយបច្ចេកទេសនិងបណ្ដុះបណ្ដាល ៣/- ក្រុមការងារសមាជិកភាព ការគាំទ្រ និងអនុលោមភាព និង ៤/- ក្រុមការងារគោលនយោបាយនិងនីតិវិធី។

ទន្ទឹមនេះ ស.ហ.ក. បានចូលរួមកិច្ចប្រជុំក្រុមការងារតំបន់អាស៊ីប៉ាស៊ីហ្វិក (Asia Pacific Regional Group) និងកិច្ចប្រជុំក្រុមការងារសមាជិកភាព ការគាំទ្រ និងអនុលោមភាព តាមប្រព័ន្ធអនឡាញជាបន្តបន្ទាប់ ដែលកិច្ចប្រជុំក្រុមការងារនេះត្រូវបានរៀបចំឡើងដោយផ្អែកលើតម្រូវការចាំបាច់របស់ក្រុមការងារនីមួយៗ។

ស.ហ.ក. ក៏បានសិក្សា និងចូលរួមផ្ដល់ធាតុចូលក្នុងគម្រោងសិក្សាផ្សេងៗ របស់ក្រុមអ៊ិកម៉ុង ដូចជា៖ ១/- តួនាទីរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុលើការប្រឆាំងការគេចវេះការដាក់ទណ្ឌកម្ម ២/- កម្រងសំណួររបស់ក្រុមការងារផ្លាស់ប្ដូរព័ត៌មានសម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំសេចក្ដីព្រាងផែនការអាជីវកម្ម ឆ្នាំ២០២៣-២០២៤ ផងដែរ។

**ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (Financial Intelligence Consultative Group – FICG)៖** ក្នុងនាមជាសមាជិករបស់ក្រុម FICG ស.ហ.ក. បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី១៤-១៦ ខែកុម្ភៈ ឆ្នាំ២០២៣ នៅប្រទេសសិង្ហបុរី។ កិច្ចប្រជុំនេះ មានគោលបំណងចែករំលែកវឌ្ឍនភាពការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្មរបស់ប្រទេសជាសមាជិក រួមមាន អាស៊ាន បូកអូស្ត្រាលី និងនូវែលសេឡង់ ព្រមទាំងពិភាក្សា និងអនុម័តលើបច្ចុប្បន្នភាពការងាររបស់គម្រោងសិក្សានានា ដែលរៀបចំដោយ FICG និងតំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុរបស់ប្រទេសជាសមាជិក។

## ៤- ការបណ្ដុះបណ្ដាល

ស.ហ.ក. បានចាត់មន្ត្រីចូលរួមវគ្គបណ្ដុះបណ្ដាលក្នុងប្រទេសចំនួន ២១លើក និងក្រៅប្រទេសចំនួន ៧លើក ដែលរៀបចំដោយស្ថាប័នជាតិ និងអន្តរជាតិ តាមរយៈប្រព័ន្ធអនឡាញ និង ការចូលរួមផ្ទាល់ ដែលមានប្រធានបទសំខាន់ៗ ដូចជា ការអនុវត្តច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ បទល្មើសបច្ចេកវិទ្យា ការស៊ើបអង្កេតហិរញ្ញវត្ថុ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ការរឹបអូសដោយមិនមានការផ្ដន្ទាទោស ការប្រឆាំងបទល្មើសហិរញ្ញវត្ថុ ការវាយតម្លៃអញ្ញមញ្ញ និងការស៊ើបអង្កេតការសម្អាតប្រាក់ក្នុងវិស័យកាស៊ីណូ ជាដើម ។ល។

ស.ហ.ក. បានចាត់មន្ត្រីជំនាញចូលរួមជាវាគ្មិន ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងសិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលចំនួន ៥លើក មានដូចជា ការអនុវត្តច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ការស៊ើបអង្កេតការសម្អាតប្រាក់ក្នុងវិស័យកាស៊ីណូ និងការស៊ើបអង្កេតបទល្មើសពន្ធដារ។

VII- **កិច្ចសហប្រតិបត្តិការអន្តរជាតិ**

**១- កិច្ចសហប្រតិបត្តិការពហុភាគី**

ដើម្បីចូលរួមជំរុញសមាហរណកម្មទាំងក្នុងតំបន់ និងពិភពលោក ពង្រីកចំណេះដឹងនិងបទពិសោធន៍ការងារ និងកសាងសមត្ថភាពមន្ត្រី-បុគ្គលិក កិច្ចសហប្រតិបត្តិការជាមួយបណ្ដាស្ថាប័នអន្តរជាតិនានាកំពុងត្រូវបានពង្រឹងនិងពង្រីកជាបន្តបន្ទាប់។

**- កិច្ចសហប្រតិបត្តិការអាស៊ាន៖** ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងការពង្រឹងសមាហរណកម្មអាស៊ាន ជាពិសេសក្នុងវិស័យហិរញ្ញវត្ថុនិងធនាគារ ដែលក្នុងនោះវឌ្ឍនភាពការងារសំខាន់ៗរួមមាន៖ i/-ការកំណត់យកមូលបទ អាស៊ានជាស្នូលនៃកំណើន ii/-ការដាក់ចេញនូវយុទ្ធសាស្ត្រជំរុញចំនួន ៣ សម្រាប់សសរស្តម្ភសេដ្ឋកិច្ចអាស៊ាន ដូចជា ការងើបឡើងនិងការកសាងឡើងវិញ (Recovery-Rebuilding) សេដ្ឋកិច្ចឌីជីថល (Digital Economy) និងចីរភាព (Sustainability) iii/-ការកំណត់នូវការងារអាទិភាពចំនួន ៤ សម្រាប់ធនាគារកណ្ដាល ដូចជា ការពង្រឹងការស្តារឡើងវិញនៃសេដ្ឋកិច្ចតាមរយៈការអនុវត្តនយោបាយចម្រុះ (Policy Mix) ការលើកកម្ពស់ការធ្វើប្រតិបត្តិការជារូបិយវត្ថុដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថិរភាពហិរញ្ញវត្ថុនិងម៉ាក្រូសេដ្ឋកិច្ចក្នុងតំបន់ ការពន្លឿនការតភ្ជាប់ប្រព័ន្ធទូទាត់ និងការដាក់ចេញនូវវិធានការរួមគ្នាដើម្បីដោះស្រាយចំពោះសេដ្ឋកិច្ចឌីជីថល iv/-ការជំរុញសេរីភាវូបនីយកម្មនិងសមាហរណកម្មហិរញ្ញវត្ថុប្រកបដោយភាពធន់មាំ តាមរយៈការរៀបចំក្របខ័ណ្ឌសមាហរណកម្មធនាគារអាស៊ាន និងការពង្រឹងថ្នាលចែករំលែកបច្ចេកវិទ្យាព័ត៌មាន v/-ការជំរុញពាណិជ្ជកម្មនិងការវិនិយោគ តាមរយៈការធ្វើសេរីភាវូបនីយកម្មគណនីមូលធននិងការជំរុញការប្រើប្រាស់រូបិយវត្ថុក្នុងតំបន់ vi/-ការពង្រឹងការតភ្ជាប់ហិរញ្ញប្បទាន ការទូទាត់ និងសេវា តាមរយៈការអង្កេតលើការតភ្ជាប់ប្រព័ន្ធទូទាត់ពហុភាគី និងការធ្វើទំនើបកម្មការតភ្ជាប់ជាលក្ខណៈទ្វេភាគី vii/-ការលើកកម្ពស់ហិរញ្ញប្បទានប្រកបដោយចីរភាព ដើម្បីចូលរួមកាត់បន្ថយការបំពុលបរិស្ថាន viii/-ការជំរុញបរិយាបន្នហិរញ្ញវត្ថុតាមរយៈការសម្រួលដល់អាជីវកម្មខ្នាតតូចឱ្យមានលទ្ធភាពទទួលបានប្រភពមូលធន ការចែករំលែកព័ត៌មាន ឧត្តមានុវត្តន៍ និងបទពិសោធន៍ចំពោះការពង្រឹងចំណេះដឹងនិងសេវាហិរញ្ញវត្ថុឌីជីថល ix/-ការពង្រីកការផ្ដល់ហិរញ្ញប្បទានសម្រាប់គ្រោះមហន្តរាយធម្មជាតិ ដើម្បីភាពធន់មាំនៃសេដ្ឋកិច្ចទប់ទល់និងការប្រែប្រួលអាកាសធាតុ x/- ការពង្រឹងការងារសវនកម្មផ្ទៃក្នុងជាមួយធនាគារកណ្ដាលនិងអាជ្ញាធររូបិយវត្ថុនៃសមាជិកអាស៊ាន និង xi/-ការពង្រឹងទំនាក់ទំនងជាមួយក្រុមប្រឹក្សាធុរកិច្ចអាស៊ាន, នាយកប្រតិបត្តិគ្រឹះស្ថានហិរញ្ញវត្ថុអាស៊ាន, ក្រុមប្រឹក្សាធុរកិច្ចអឺរ៉ុប-អាស៊ាន និងក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន ជាដើម។

**- កិច្ចសហប្រតិបត្តិការអាស៊ាន+៣៖** ធនាគារជាតិនៃកម្ពុជាបានចូលរួមពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ាន+៣ ក្រោមការដឹកនាំរបស់សហប្រធានប្តូរវេនឆ្នាំ២០២៣ ប្រទេសឥណ្ឌូណេស៊ី និងជប៉ុន។ កិច្ចសហប្រតិបត្តិការសំខាន់ៗរបស់អាស៊ាន+៣ រួមមាន៖ i/-ការពិភាក្សាលើទិសដៅអនាគតសម្រាប់ការត្រៀមរៀបចំហិរញ្ញប្បទានក្នុងតំបន់ ដូចជា ការបង្កើតឧបករណ៍ផ្ដល់ហិរញ្ញប្បទានឆាប់រហ័ស

និងឧបករណ៍ផ្តល់ហិរញ្ញប្បទានថ្មីៗបន្ថែមទៀត ii/-ការពង្រឹងកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ដូចជា ការជំរុញការផ្តល់ហិរញ្ញប្បទានជារូបិយវត្ថុក្នុងតំបន់ (LCY) និងការសម្រេចការសាកល្បងនូវដំណើរការសាកល្បងលើកទី១៣ នៃយន្តការ CMIM iii/-ការអភិវឌ្ឍអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ដូចជា ការអនុម័តទិសដៅយុទ្ធសាស្ត្រឆ្នាំ២០៣០ របស់អង្គភាព AMRO ការគាំទ្រអង្គភាព AMRO ឱ្យក្លាយទៅជាមជ្ឈមណ្ឌលចំណេះដឹងក្នុងតំបន់ (RKH) ការបង្កើតបណ្តាញអ្នកវិភាគហិរញ្ញវត្ថុអាស៊ាន+៣ (AFTN) និងការពង្រឹងអភិបាលកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់របស់អង្គភាព AMRO iv/-ការពង្រឹងគំនិតផ្តួចផ្តើមទីផ្សារសញ្ញាបណ្ណអាស៊ី តាមរយៈការអនុម័តលើផែនទីបង្ហាញផ្លូវរយៈពេលមធ្យមរបស់ ABMI ថ្មី ឆ្នាំ២០២៣-២០២៦ សំដៅអភិវឌ្ឍទីផ្សារមូលបត្របំណុលជារូបិយវត្ថុក្នុងស្រុក v/-ការសិក្សាលើគំនិតផ្តួចផ្តើមអនាគតអាស៊ាន+៣ ដូចជា ការផ្តល់ហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ ការបង្កើតឧបករណ៍ហិរញ្ញវត្ថុម៉ាក្រូសេដ្ឋកិច្ចរយៈពេលវែង ការពង្រឹងភាពរឹងមាំហិរញ្ញវត្ថុពីគ្រោះមហន្តរាយធម្មជាតិ និងការពង្រឹងកិច្ចសហការគោលនយោបាយសម្រាប់វឌ្ឍនភាពនៃបច្ចេកវិទ្យា។

- **មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)៖** ធនាគារជាតិនៃកម្ពុជាទទួលបានជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលពី IMF លើការព្យាករដោយប្រើប្រាស់ទិន្នន័យថ្មីៗ (Nowcasting) ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជា និងគោលការណ៍ស្ទួលបាសែល ដើម្បីពង្រឹងការតាមដាននិងវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច នយោបាយរូបិយវត្ថុ សន្ទនីយភាព ស្ថិតិ និងការត្រួតពិនិត្យក្នុងវិស័យធនាគារនៅកម្ពុជា។ ធនាគារជាតិនៃកម្ពុជាបានចូលរួមគាំទ្របេក្ខភាពសម្រាប់តំណែងនាយកប្រតិបត្តិនៃក្រុមការងារមណ្ឌលបោះឆ្នោតប្រចាំតំបន់អាស៊ីអាគ្នេយ៍នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (SEAVG)។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមពិភាក្សាអំពីទស្សនវិស័យសេដ្ឋកិច្ចតំបន់និងពិភពលោក បញ្ហាប្រឈម និងគោលនយោបាយដោះស្រាយចម្បង សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ក្នុងកម្មវិធីកិច្ចប្រជុំប្រចាំនិទាឃរដូវឆ្នាំ២០២៣ របស់មូលនិធិរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោក នៅរដ្ឋធានីវ៉ាស៊ីនតោនឌីស៊ីសហរដ្ឋអាមេរិក។ ធនាគារជាតិនៃកម្ពុជាក៏បានត្រៀមខ្លួនដើម្បីសហការជាមួយលោក Jochen Schmittmann អ្នកតំណាងការិយាល័យ IMF ថ្មីប្រចាំកម្ពុជា, វៀតណាម និងឡាវ បន្ទាប់ពីលោក Yasuhisa Ojima ផងដែរ។ នៅឆមាសទី២ខាងមុខ ធនាគារជាតិនៃកម្ពុជា កំពុងត្រៀមរៀបចំសហការជាមួយក្រុមបេសកកម្មមាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF Article IV) ដើម្បីបន្តតាមដាន និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុនិងធនាគារ នៅកម្ពុជាបន្ថែមទៀត។

- **ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)៖** ក្រោមជំនួយផ្នែកហិរញ្ញវត្ថុរបស់ ADB គម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដំណាក់កាលទី២ ត្រូវបានបញ្ចប់ជាស្ថាពរកាលពីដើមឆ្នាំ២០២៣។ ជាមួយគ្នានេះ ពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នកម្មលើឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០២១-២០៣០" សេចក្តីព្រាងរបាយការណ៍ចុងក្រោយនៃឯកសារនេះ

ត្រូវបានពិនិត្យដោយក្រុមការងារបច្ចេកទេសអន្តរក្រសួង និងត្រៀមដាក់ជូនគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុដើម្បីពិនិត្យនិងសម្រេច។ លើសពីនេះ ADB ក៏បានជួបប្រជុំជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពិភាក្សា និងប្រមូលធាតុចូលសម្រាប់ជំនួយបច្ចេកទេសលើគម្រោង "កៀរគរប្រាក់ចំណូល ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ និងការពង្រឹងចំណូលថ្នាក់ក្រោមជាតិ" ដែលមូលនិធិសម្រាប់គម្រោងនេះត្រូវបានអនុម័តរួចរាល់ដោយក្រុមប្រឹក្សាភិបាលរបស់ ADB។

**- មជ្ឈមណ្ឌលស៊ាសិន (SEACEN)៖** ស៊ាសិនបានបន្តរួមចំណែកអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជាជាបន្តបន្ទាប់ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលនានា។ ជាមួយគ្នានេះ ក្នុងនាមជាប្រធានប្តូរវេនរបស់ស៊ាសិនសម្រាប់ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានដឹកនាំកិច្ចសម្ភាសន៍បេក្ខជន និងការជ្រើសរើស សម្រាប់មុខតំណែងនាយកប្រតិបត្តិ និងប្រធានទទួលបន្ទុកទៅលើស្ថិរភាពហិរញ្ញវត្ថុ ការត្រួតពិនិត្យ និងប្រព័ន្ធទូទាត់ ដោយមានការចូលរួមពីទេសាភិបាលរង ឧបការីទេសាភិបាល និងតំណាងមកពីធនាគារកណ្តាលជាសមាជិកស៊ាសិន។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានត្រៀមខ្លួនក្នុងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិស៊ាសិន (EXCO) ដែលនឹងត្រូវធ្វើឡើងនៅប្រទេសកម្ពុជា នាត្រីមាសទី៣ ខាងមុខនេះ។

**- ធនាគារពិភពលោក (WB)៖** គណៈប្រតិភូរបស់ WB ដែលទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការជំនួយប្រឹក្សាផ្នែកគ្រប់គ្រងការវិនិយោគ (RAMP Program) បានចូលជួបជាមួយថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាដើម្បីពិភាក្សាពីការបន្តកិច្ចសហការរបស់ WB ក្នុងការជួយជ្រោមជ្រែងធនាគារជាតិនៃកម្ពុជាបន្ថែមទៀត ដើម្បីឱ្យការគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជាកាន់តែមានការរីកចម្រើន និងជឿនលឿន។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងវេទិកាពិភាក្សាតុមូលជាន់ខ្ពស់ស្តីពី "ការធ្វើបច្ចុប្បន្នកម្មលើការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់កម្ពុជា" ដែលរៀបចំឡើងដោយ WB។ វេទិកានេះ មានគោលបំណងពិភាក្សាអំពីការកំណត់គោលនយោបាយអាទិភាព សម្រាប់ជំរុញការអភិវឌ្ឍប្រកបដោយបរិយាបន្ន ព្រមទាំងបញ្ហាប្រឈមនិងដំណោះស្រាយដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងរៀបចំជាឯកសារវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ ជំនាន់ទី២ (SCD-2) ដែលក្នុងនោះមានជាប់ពាក់ព័ន្ធនឹងការពង្រឹងបទប្បញ្ញត្តិ និងការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ ផងដែរ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិផ្សេងទៀតដូចជា JICA, UNDP, UNESCAP, UNEP, IFC ដើម្បីរួមចំណែកក្នុងការសិក្សាស្រាវជ្រាវ ពង្រឹងមូលដ្ឋានទិន្នន័យ គាំទ្រដល់ការថែរក្សាបរិស្ថាន ជំរុញសហគ្រិនភាពរបស់ស្ត្រី បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងហិរញ្ញវត្ថុ និងការជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ ជាដើម។

## ប្រអប់ ២ ៖ កិច្ចសហប្រតិបត្តិការពហុភាគីជាមួយស្ថាប័នផ្សេងៗ

- **ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)៖** JICA បាននឹងកំពុងបន្តសហការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយធនាគារជាតិនៃកម្ពុជា ស្តីពី "ការលើកកម្ពស់សមត្ថភាពក្នុងការស្រាវជ្រាវ វិភាគសេដ្ឋកិច្ច និងប្រតិបត្តិការរូបិយវត្ថុ"។ កិច្ចសហប្រតិបត្តិការបច្ចេកទេសនេះមានរយៈពេល ៣ឆ្នាំ (២០២៣-២០២៥) ដែលនឹងជួយលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈការធ្វើឱ្យប្រសើរឡើងនៃប្រតិបត្តិការទីផ្សាររូបិយវត្ថុអន្តរធនាគារ និងការពង្រឹងទំនាក់ទំនងជាមួយសាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងពីការអនុវត្តនយោបាយរូបិយវត្ថុ។ ក្នុងការអនុវត្តគម្រោងនេះ ក្រុមជំនាញការរបស់ JICA ក៏បានបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជា ដើម្បីពិភាក្សាការងារជាមួយមន្ត្រីពាក់ព័ន្ធ ហើយ JICA ក៏បានផ្តល់ជំនាញការរយៈពេលវែងដែលកំពុងបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជា ចាប់តាំងពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ មក។ ទន្ទឹមនេះ កិច្ចសហប្រតិបត្តិការបច្ចេកទេសក៏នឹងជួយបង្កើនសមត្ថភាពធនធានមនុស្សរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុនៅកម្ពុជា ស្របពេលដែលគម្រោងបច្ចេកទេសនេះ នឹងរួមចំណែកអភិវឌ្ឍយន្តការនិងក្របខ័ណ្ឌនយោបាយរូបិយវត្ថុ សំដៅគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនូវការសម្រេចចិត្តគោលនយោបាយ។ ជាមួយគ្នានេះ សម្រាប់កិច្ចសហការស្រាវជ្រាវ ស្តីពី ដុល្លារូបនីយកម្មនៅកម្ពុជា និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលត្រូវបានបញ្ចប់ ហើយគ្រោងនឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈ នាពេលខាងមុខ។

- **កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP)៖** UNDP បាននិងកំពុងសហការរៀបចំកិច្ចប្រជុំពិភាក្សាលើគម្រោង "Blended Finance" សម្រាប់វិស័យសុខាភិបាល ដែលជាការប្រើប្រាស់ហិរញ្ញប្បទានរបស់គម្រោងអភិវឌ្ឍន៍ជួយដល់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចក្នុងគោលដៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលហិរញ្ញប្បទាននេះអាចមានការចូលរួមពីវិស័យឯកជន និងសាធារណៈ។ ធនាគារជាតិនៃកម្ពុជាសហការជាមួយ UNDP ធ្វើការអង្កេតលើការប្រើប្រាស់រូបិយវត្ថុរបស់រោងចក្រ សហគ្រាស និងបុគ្គល ក្នុងគោលបំណងសិក្សាពីកម្រិតដុល្លារូបនីយកម្មនៅកម្ពុជាផងដែរ។

- **គណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ (UNESCAP)៖** UNESCAP បានបន្តកិច្ចសហការលើគម្រោង ស្តីពី "ការជំរុញសហគ្រិនភាពរបស់ស្ត្រី (Catalyzing Women's Entrepreneurship)" សម្រាប់ឆ្នាំ២០២៣ ហើយការព្យាករថានឹងត្រូវបានអនុវត្តនៅត្រីមាសទី៣។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក៏បានសហការជាមួយអង្គការ UNESCAP ក្នុងការរៀបចំរបាយការណ៍សិក្សា ស្តីពី ការវិភាគទីផ្សារហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា "the Green and Sustainable Financial Market Analysis for the Financing Cambodia's Future" ដែល

របាយការណ៍នេះ ត្រូវបានបញ្ចប់រួចរាល់ ជាស្ថាពរ។ ធនាគារជាតិនៃកម្ពុជាកំពុងបន្តសហការក្នុងជំហានទី២ ជាមួយអង្គការ UNESCAP ក្នុងការរៀបចំផែនទីចង្អុលទិសហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា "Cambodia's Sustainable Finance Roadmap" ក្នុងគោលបំណងតម្រង់ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាស្របទៅនឹងគោលដៅរួមនៃការអភិវឌ្ឍ ដោយផ្តោតលើបញ្ហាបម្រែបម្រួលអាកាសធាតុ បរិស្ថាន និងសង្គមប្រកបដោយចីរភាព និងដើម្បីសម្រេចបាននូវភាពធន់ និងស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ សម្រាប់ការគាំទ្រសេដ្ឋកិច្ច និងបរិស្ថានប្រកបដោយចីរភាព។ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមចែករំលែកទស្សនៈលើប្រធានបទ "កាតាលីករអាកាសធាតុលើហិរញ្ញវត្ថុ និងការវិនិយោគ" នៅក្នុងវេទិកាពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាននៃបណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

- **កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP)៖** UNEP បានជួបពិភាក្សាអំពីគម្រោង "EmPower II៖ ស្ត្រីសម្រាប់សង្គមដែលមានភាពរឹងមាំទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ" ដើម្បីគាំទ្រការដាក់ចេញនូវអនុសាសន៍គោលនយោបាយបម្រែបម្រួលអាកាសធាតុ និងលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងនៃការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងសមភាពយេនឌ័រក្នុងការងារពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ថាមពលកកើតឡើងវិញ និងសកម្មភាពកាត់បន្ថយហានិភ័យគ្រោះធម្មជាតិ។
- **សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)៖** ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា និង IFC បានសហការរៀបចំសិក្ខាសាលាសម្រាប់និយ័តករ ស្តីពី "ការអភិវឌ្ឍទីផ្សារឧបករណ៍និស្សន្ទនៅកម្ពុជា៖ ឧបករណ៍សម្រាប់គ្រប់គ្រងហានិភ័យ" ដើម្បីជំរុញការអភិវឌ្ឍទីផ្សារឧបករណ៍និស្សន្ទចារឹកជាប្រាក់រៀលដែលមានបទប្បញ្ញត្តិគ្រប់គ្រងត្រឹមត្រូវ ហើយប្រើប្រាស់ជាឧបករណ៍គ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពសម្រាប់ជំរុញការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុចារឹកជាប្រាក់រៀល ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងសម្រេចបានគោលដៅចម្បងគឺការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

## ២- កិច្ចសហប្រតិបត្តិការទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគារកណ្តាល និងអាជ្ញាធររូបិយវត្ថុផ្សេងទៀតនៅក្នុងតំបន់និងពិភពលោក។ ចំពោះកិច្ចសហការទ្វេភាគីក្នុងតំបន់អាស៊ានចំពោះធនាគារកណ្តាលថៃ ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ២០២៣ ដោយមានការចូលរួមពី ឯកឧត្តម ទេសាភិបាលនៃធនាគារកណ្តាលថៃ ដោយក្នុងឱកាសនោះក៏មានការរៀបចំកម្មវិធីសម្ពោធជាផ្លូវការនូវការធ្វើសន្ទានកម្មសម្រាប់ថៃស្កេនឃ្យូអរកូតនៅកម្ពុជាក្នុងដំណាក់កាលទី២ ដែលអនុញ្ញាតឱ្យប្រជាជនថៃ អាចធ្វើការស្កេនឃ្យូអរកូតរបស់ពាណិជ្ជករកម្ពុជាទូទាំងប្រទេសផងដែរ។ ជាមួយធនាគារកណ្តាលឡាវ ធនាគារជាតិនៃកម្ពុជាបានចូលរួមអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេសទ្វេភាគី តាមរយៈការធ្វើទស្សនកិច្ចសិក្សាទៅលើប្រធានបទដូចជា៖ i/-ការគ្រប់គ្រង ការត្រួតពិនិត្យ និងគោលនយោបាយបទប្បញ្ញត្តិលើប្រព័ន្ធទូទាត់

តម្លៃធំ ii/-ការគ្រប់គ្រង និងចងក្រងស្ថិតិ និង iii/-ការគ្រប់គ្រងគណនី និងប្រតិបត្តិការសន្ធនីយភាព។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយធនាគាររដ្ឋវៀតណាម ធនាគារជាតិនៃកម្ពុជា បានបន្តអនុវត្តនិងសហការ ក្នុងការជំរុញការទូទាត់ឆ្លងដែនតាមប្រព័ន្ធធនាគារ ស្របតាមអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់។ ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី ដើម្បីសម្គោធជាផ្លូវការលើគម្រោងការផ្តល់សេវាចែករំលែកព័ត៌មានឥណទានឆ្លងតំបន់រវាងប្រទេសកម្ពុជា និងសិង្ហបុរី។

ចំណែកឯកិច្ចសហប្រតិបត្តិការទ្វេភាគីក្រៅពីតំបន់អាស៊ាន ធនាគារជាតិនៃកម្ពុជា បានចុះអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ជាមួយ ធនាគារកណ្តាលនៃកោះសូឡូម៉ូន ធនាគារកណ្តាលហ្វីជី និងធនាគារកណ្តាលវ៉ាន់ដា។ ធនាគារជាតិនៃកម្ពុជា ក៏បន្តសហការរៀបចំកម្មវិធីស្រាវជ្រាវរួមគ្នាជាមួយធនាគារកណ្តាលកូរ៉េ ក្រោមកម្មវិធី "ភាពជាដៃគូផ្តល់ចំណេះដឹងរបស់ធនាគារកណ្តាលកូរ៉េ (BOK-KPP)" សម្រាប់ឆ្នាំ២០២៣ លើប្រធានបទ "ការទំនាក់ទំនង និងផ្សព្វផ្សាយសាធារណៈរបស់ធនាគារកណ្តាល"។ ជាមួយធនាគារកណ្តាលចិន ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការលើការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកសម្រាប់ការទូទាត់ពាណិជ្ជកម្មឆ្លងដែនទ្វេភាគីចិន-កម្ពុជា និងការបង្កើនការតភ្ជាប់ប្រព័ន្ធទូទាត់សម្រាប់ប្រតិបត្តិការឆ្លងដែនរវាងប្រទេសទាំងពីរ។ ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសក្នុងតំបន់អឺរ៉ុប ធនាគារជាតិនៃកម្ពុជា បានរៀបចំទទួលដំណើរទស្សនកិច្ចរបស់ឯកឧត្តម Burkhard BALZ ទេសាភិបាលរងធនាគារកណ្តាលអាល្លឺម៉ង់ និងក្រុមការងារមកកាន់កម្ពុជា ក៏ដូចជាបានជួបពិភាក្សាជាមួយគណៈប្រតិភូធនាគារកណ្តាលបារាំងដែលដឹកនាំដោយលោកស្រី Emmanuelle Assouan អគ្គនាយកស្ថិរភាពហិរញ្ញវត្ថុនិងប្រតិបត្តិការ ព្រមទាំងបានចែករំលែកបទពិសោធន៍ពីការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា ជាពិសេស ប្រព័ន្ធទូទាត់បាគង។ ជាមួយនឹងកិច្ចសហប្រតិបត្តិការល្អជាមួយធនាគារកណ្តាល និងស្ថានទូតនានាប្រចាំកម្ពុជា មន្ត្រីធនាគារជាតិនៃកម្ពុជា ទទួលបានអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេសដូចជា៖ អង់គ្លេស នូវែលសេឡង់ ជប៉ុន ថៃ វៀតណាម កូរ៉េ និងអូស្ត្រាលី ជាដើម ដែលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា។

## VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - ឯកឧត្តម ស៊ុំ សន្និសិទ្ធ | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ឹរ ចុង | តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម រស់ សីលវ៉ា | តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - ឯកឧត្តម ឡាយ ម៉េងស៊ុន | តំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក និង |
| - លោក មុំ ដារ៉េត | តំណាងឱ្យបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក។ |

នៅឆមាសទី១នេះ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៣ លើក ៖

- លើកទី១៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៦ កាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២២។

- លើកទី២៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៧ កាលពីថ្ងៃពុធ ៣រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០២២ និងផែនការឆ្នាំ២០២៣។

-លើកទី៣៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៨ កាលពីថ្ងៃចន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៣។

### ២- ការអភិវឌ្ឍធនធានមនុស្ស

ធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា មានការអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដោយបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួនមន្ត្រីបុគ្គលិកប្រកបដោយគុណវុឌ្ឍិ វចនាសម្ព័ន្ធការងាររឹងមាំ និងការងារប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ន ការគ្រប់គ្រងធនធានមនុស្ស ត្រូវបានអភិវឌ្ឍស្របនឹងតម្រូវការនៃសមាហរណកម្មនៅក្នុងតំបន់និងពិភពលោក ព្រមទាំងគោលការណ៍នៃស្ថិរភាព និងប្រសិទ្ធភាពការងារ។

ជាមួយគ្នានេះ ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា បច្ចុប្បន្នធនាគារជាតិនៃកម្ពុជា កំពុងជំរុញបន្ថែមទៀតលើវគ្គសិក្សា FSI-Connect និងវគ្គសិក្សា FPP និងបានផ្សព្វផ្សាយកម្មវិធីទាំងពីរនេះដល់សាខារាជធានី-ខេត្ត ដើម្បីពង្រឹងសមត្ថភាពចំណេះដឹងចំណេះធ្វើ ដល់មន្ត្រីបុគ្គលិកសាខារបស់ខ្លួន។ ធនាគារជាតិនៃកម្ពុជាក៏បានបង្កើតក្រុមការងារនៅតាមបណ្តាសាខារាជធានី-ខេត្ត ដើម្បីតាមដានស្ថានភាពសេដ្ឋកិច្ច និងអតិផរណាផងដែរ។

### ក- ស្ថិតិមន្ត្រីបុគ្គលិក

ក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសក្នុងឆមាសទី១នេះ មានចំនួនសរុប ១.៩១៥ រូប (ប្រុស ៩៧១ រូប ស្រី ៩៤៤ រូប) ក្នុងនោះទីស្នាក់ការកណ្តាលមានចំនួន ១.៤០៩ រូប (ប្រុស ៧៣៦ រូប ស្រី ៦៧៣ រូប) និងសាខារាជធានី-ខេត្ត មានចំនួន៥០៦ រូប (ប្រុស ២៣៥ រូប ស្រី ២៧១ រូប)។ ក្នុងរយៈពេល ៦ខែដើមឆ្នាំនេះ ក្របខ័ណ្ឌមន្ត្រីបុគ្គលិកនៅទីស្នាក់ការកណ្តាលបានកើនឡើងចំនួន ៣១ រូប (ចូលថ្មី ៤៦រូប ផ្ទេរចូល ៤ រូប ផ្ទេរចេញ ១ រូប ចូលនិវត្តន៍ ៩ រូប លាឈប់ ៧ រូប និងមរណភាព ២ រូប) ស្របពេលនៅសាខា បានថយចុះចំនួន ៥រូប (ផ្ទេរចូល ១ រូប ផ្ទេរចេញ ៤ រូប ចូលនិវត្តន៍ ១ រូប លាឈប់ ១ រូប )។

**តារាង១៖ ស្ថិតិមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០២៣**

| | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | ឆ្នាំ២០២៣ | ប្រែប្រួល ២០២២ |
|---|---|---|---|---|---|---|---|
| | | ឆមាសទី១ | ឆមាសទី២ | ឆមាសទី១ | ឆមាសទី២ | ឆមាសទី១ | |
| **ទីស្នាក់ការកណ្តាល** | ប្រុស | ៦៨៧ | ៦៨៦ | ៧១០ | ៧២០ | ៧៣៦ | ១៦ |
| | ស្រី | ៦០៨ | ៦០៩ | ៦២៤ | ៦៥៨ | ៦៧៣ | ១៥ |
| | សរុប | ១២៩៥ | ១២៩៥ | ១៣៣៤ | **១៣៧៨** | **១៤០៩** | ៣១ |
| **សាខា** | ប្រុស | ២៣៣ | ២៣១ | ២២៦ | ២៣៩ | ២៣៥ | -៤ |
| | ស្រី | ២៥៥ | ២៤៩ | ២៤១ | ២៧២ | ២៧១ | -១ |
| | សរុប | ៤៨៨ | ៤៨០ | ៤៦៧ | **៥១១** | **៥០៦** | -៥ |
| **សរុបទូទាំងប្រទេស** | ប្រុស | ៩២០ | ៩១៧ | ៩៣៦ | ៩៥៩ | ៩៧១ | ១២ |
| | ស្រី | ៨៦៣ | ៨៥៨ | ៨៦៥ | ៩៣០ | ៩៤៤ | ១៤ |
| | សរុប | **១៧៨៣** | **១៧៧៥** | **១៨០១** | **១៨៨៩** | **១៩១៥** | **២៦** |

### ខ- ការបណ្តុះបណ្តាល

#### - ការងារបណ្តុះបណ្តាលក្នុងប្រទេស

នៅក្នុងឆមាសទី១ ឆ្នាំ២០២៣នេះ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍសមត្ថភាពមន្ត្រីបុគ្គលិកតាមរយៈការបើកវគ្គបណ្តុះបណ្តាល និងការចាត់បញ្ជូនមន្ត្រីបុគ្គលិកឱ្យទៅចូលរួមកម្មវិធីបណ្តុះបណ្តាលផ្សេងៗតាមការអញ្ជើញរបស់ក្រសួង-ស្ថាប័ននានា ដែលរួមមានសិក្ខាសាលាចំនួន២០លើក (សិក្ខាកាមចូលរួម ១១០រូប) វគ្គសិក្សាចំនួន ៥លើក (២៥០រូប) កិច្ចប្រជុំចំនួន ៤០លើក (មន្ត្រីបុគ្គលិកចូលរួម ៤០០រូប) និងបានរៀបចំកម្មវិធីចុះកម្មសិក្សានៅធនាគារជាតិនៃកម្ពុជាជូនសិស្ស-និស្សិតមកពីបណ្តាគ្រឹះស្ថានឧត្តមសិក្សាចំនួន៥លើក សម្រាប់សិស្ស-និស្សិតចូលរួមចំនួន ២០០រូប។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តបណ្តុះបណ្តាលមន្ត្រីបុគ្គលិកផ្ទៃក្នុងតាមប្រព័ន្ធអនឡាញចំនួន២ គឺ៖ ១/- កម្មវិធីបណ្តុះបណ្តាល NBC FSI Connect ជំនាញត្រួតពិនិត្យធនាគារ ក្រោមកម្មវិធីរបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) មាន៧ជំនាន់ និងមានសិក្ខាកាមចូលរួមសិក្សាសរុបចំនួន ៤០៦រូប។ វគ្គសិក្សានេះត្រូវបានរៀបចំការប្រឡងតាមប្រព័ន្ធអនឡាញជាផ្លូវការដើម្បីវាយតម្លៃគុណភាពសិក្សាចំនួន ៤៩លើកជាបន្តបន្ទាប់ ក្នុងនោះមានមន្ត្រីបុគ្គលិកប្រឡងបញ្ចប់កម្រិតបឋមចំនួន ២៨៧រូប កម្រិតមធ្យមចំនួន ១៦៦រូប និងកម្រិតខ្ពស់ចំនួន៩៩រូប។

២/- កម្មវិធីបណ្តុះបណ្តាល NBC-IMF ស្តីពីកម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ (FPP) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) មាន៤ជំនាន់ ដែលមានសិក្ខាកាមសរុបចំនួន៣០៤រូប។ នៅឆមាសនេះ មន្ត្រីបុគ្គលិកជំនាន់ទី៤ ចំនួន ៤៩រូប បានប្រឡងបញ្ចប់កម្មវិធីសិក្សាកម្រិត១ តាមប្រព័ន្ធអនឡាញជាផ្លូវការកាលពីដើមខែមេសាដោយជោគជ័យ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជា គ្រោងនឹងដាក់ឱ្យដំណើរការវគ្គសិក្សាតាមប្រព័ន្ធអនឡាញ ស្តីពី Macroeconomic Diagnostics នៅឆមាសថ្មីសម្រាប់សិក្ខាកាមចំនួន ៦០រូប បន្តទៀត។

ចំពោះការបណ្តុះបណ្តាលនិស្សិតថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ មណ្ឌលសិក្សាបច្ចេកទេសធនាគារ (CBS) បាននិងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារជំនាញធនាគារនិងហិរញ្ញវត្ថុ មាននិស្សិតចំនួនបីជំនាន់ ក្នុងនោះមាននិស្សិតកំពុងសិក្សាចំនួនពីរជំនាន់ ដែលមាននិស្សិតសរុបចំនួន ២៨៨រូប (ស្រី២១៤រូប ប្រុស៧៤រូប) រីឯមួយជំនាន់ទៀតបាននិងកំពុងចុះកម្មសិក្សានៅធនាគារជាតិនៃកម្ពុជា និងត្រៀមសរសេររបាយការណ៍យល់ដឹង ក៏ដូចជាធ្វើបទបង្ហាញជូនគណៈកម្មការវាយតម្លៃគុណភាពសិក្សា។ ក្នុងគោលដៅពង្រឹងគុណភាពសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារ CBS បានបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមមាន៖ វិទ្យាស្ថានអាស៊ីសម្រាប់ធនាគារិក (Asian Institute of Chartered Banker - AICB) វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ (IBF) សមាគមធនាគារនៅកម្ពុជា (ABC) និងវិទ្យាស្ថានបណ្តុះបណ្តាលនៃធនាគារកណ្តាលម៉ាឡេស៊ី ហ្វីលីពីន និងថៃ។ គួររំលេចថា អគារថ្មីនៃមណ្ឌលសិក្សាបច្ចេកទេសធនាគារ ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ ដើម្បីរួមចំណែកពង្រឹងគុណភាពនិងប្រសិទ្ធភាពសិក្សាបន្ថែមទៀត។

## តារាង២៖ ស្ថិតិសាស្ត្រាចារ្យនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារឆ្នាំ២០២៣

| បរិយាយ | ជំនាន់ទី៣១ | | | ជំនាន់ទី៣២ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| បរិញ្ញាបត្រ | ១ | ២ | ៣ | ១ | ២ | ៣ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ២៥ | ៥ | ៣០ | ២៤ | ៧ | ៣១ |
| បណ្ឌិត | ១ | ០ | ១ | ១ | ០ | ១ |
| សរុប | ២៧ | ៧ | ៣៤ | ២៦ | ៩ | ៣៥ |
| **សរុបជំនាន់ទី៣១ និង៣២** | ៦៩ រូប (ប្រុស ៥៣រូប, ស្រី ១៦រូប) | | | | | |

## តារាង៣៖ ស្ថិតិនិស្សិតនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារឆ្នាំ២០២៣

| បរិយាយ | ជំនាន់ទី៣១ | | | ជំនាន់ទី៣២ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| វគ្គសិក្សាទី៥៧ | ៣១ | ១០៧ | ១៣៨ | ៤៣ | ១០៧ | ១៥០ |
| **និស្សិតជំនាន់ទី៣១ និងទី៣២** | សរុប ២៨៨ រូប (ស្រី ២១៤ រូប, ប្រុស ៧៤ រូប) | | | | | |

- ការងារបណ្តុះបណ្តាលក្រៅប្រទេស

ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍសមត្ថភាពធនធានមនុស្សជាមួយដៃគូអន្តរជាតិ តាមរយៈការចាត់បញ្ជូនមន្ត្រី-បុគ្គលិកឱ្យចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ចំនួន១២៩លើក (មន្ត្រីបុគ្គលិកចូលរួម ៣១២រូប មន្ត្រីបុគ្គលិកចូលរួមវគ្គសិក្សារយៈពេលខ្លី តាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ចំនួន ៦៩លើក (២០២រូប) និងវគ្គសិក្សារយៈពេលវែងថ្នាក់អនុបណ្ឌិតចំនួន ៧លើក (៧រូប)។ ជារួម ដោយសារវិបត្តិជំងឺកូវីដ-១៩ បានថមថយជាបណ្តើរៗ សកម្មភាពបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេសបានកើនឡើងបន្តបន្ទាប់ ទាំងជាលក្ខណៈ Hybrid ផង និងដោយផ្ទាល់ផង។

## ៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យផ្ទៃក្នុង ធនាគារជាតិនៃកម្ពុជាបន្តអនុវត្តការងារសវនកម្មនិងអធិការកិច្ចទៅតាមផែនការ សំដៅលើកកម្ពស់ការប្រតិបត្តិតាមបទប្បញ្ញត្តិ សេចក្តីណែនាំ និងនីតិវិធីការងារ ជាពិសេសរួមចំណែកពង្រឹងអភិបាលកិច្ចល្អនៅធនាគារជាតិនៃកម្ពុជា។

នៅក្នុងឆមាសទី១ ឆ្នាំ២០២៣ ការធ្វើសវនកម្មបានអនុវត្តចំពោះនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ចំនួន ៤ (ខេត្តកំពង់ស្ពឺ ព្រះសីហនុ ព្រៃវែង និងរតនគិរី) ព្រមទាំងបានតាមដានការអនុវត្តតាមអនុសាសន៍នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តបន្ទាយមានជ័យ ស្វាយរៀង និងកំពត។ ដោយឡែក ការចុះធ្វើអធិការកិច្ចបានអនុវត្តចំពោះសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ចំនួន ៧ (រតនគិរី ពោធិ៍សាត់ ព្រៃវែង ក្រចេះ សៀមរាប ស្ទឹងត្រែង និងកំពង់ចាម)។ ទន្ទឹមនេះ ការងារអធិការកិច្ចក៏បានពិនិត្យការបំផ្លាញចោលក្រដាសប្រាក់ចាស់ ទក់ រហែក ដែលប្រមូលបានពីចរាចរណ៍នៅលើទីផ្សារ។

ចំពោះការងារគ្រប់គ្រងហានិភ័យ គណៈកម្មការគ្រប់គ្រងហានិភ័យប្រព័ន្ធធនាគារស្នូលរបស់ធនាគារជាតិនៃកម្ពុជាបានប្រជុំចំនួន២លើក ដើម្បីពិភាក្សាអំពីដំណើការបិទបញ្ជីឆ្នាំ២០២២ និងការងារពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធធនាគារស្នូល។

ក្នុងក្របខ័ណ្ឌអាស៊ាន ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំ ធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំប្រធានសវនកម្មផ្ទៃក្នុងធនាគារកណ្តាលអាស៊ានប្រចាំឆ្នាំលើកទី៨ ដែលនឹងប្រព្រឹត្តទៅនៅខែតុលាឆ្នាំ២០២៣ខាងមុខនេះ។

## ៤- សាខាធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងពង្រឹងនិងពង្រីកសមត្ថភាពប្រតិបត្តិការនៅតាមសាខារាជធានី-ខេត្ត សំដៅគ្រប់គ្រងការធ្វើចរាចរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារឱ្យបានកាន់តែទូលំទូលាយតាមរយៈការផ្តល់សេវា (គ្រប់គ្រងគណនីប្រាក់បញ្ញើ ទទួលនិងបើកសាច់ប្រាក់ និងសេវាផ្ទេរប្រាក់) ជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្រសួង-មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាលឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់ថែមទៀត ដែលសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តជាអ្នកផ្តល់សេវាប្តូរក្រដាសប្រាក់រៀលចាស់ សឹករេចរិល ទក់ រហែក ជូនដល់សាធារណជន ក្នុងគោលបំណងដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានបន្តសហការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ ក្រៅពីនេះ សាខាធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមតាមដានស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ដូចជាការប្រែប្រួលថ្លៃ អត្រាប្តូរប្រាក់ និងសូចនាករម៉ាក្រូសេដ្ឋកិច្ចដទៃទៀតដែលរួមចំណែកក្នុងការតាមដានស្ថានភាពសេដ្ឋកិច្ចជារួម និងការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។ ម្យ៉ាងទៀត មន្ត្រីជំនាញនៅតាមសាខាក៏បានផ្តល់ព័ត៌មានអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុដល់សាធារណជនតាមប្រព័ន្ធ Hotline ផងដែរ។

## សេចក្តីសន្និដ្ឋាន

នៅឆមាសទី១នេះ សេដ្ឋកិច្ចកម្ពុជាបានបន្តកើនឡើង ដែលជំរុញដោយកំណើនខ្ពស់នៃវិស័យទេសចរណ៍ និងវឌ្ឍនភាពល្អនៃវិស័យកសិកម្ម ស្របពេលវិស័យសំណង់ហាក់បានបង្ហាញពីសញ្ញាងើបឡើងវិញ ដោយអាចផាត់ទាត់ការធ្លាក់ចុះនៃការនាំចេញក្នុងវិស័យកាត់ដេរ ស្បែកជើង និងផលិតផលធ្វើដំណើរ។ អតិផរណាមាននិន្នាការថយចុះជាលំដាប់ ដោយសារការធ្លាក់ថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ ហើយអត្រាប្តូរប្រាក់បន្តរក្សាបានស្ថិរភាពល្អប្រសើរ ដែលបានជួយរួមចំណែកការពារអំណាចទិញនៃប្រាក់រៀល។ ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ដោយប្រុងប្រយ័ត្ន ដើម្បីគាំទ្រការងើបឡើងនៃសេដ្ឋកិច្ច ព្រមទាំងបានគរពូនទុនបម្រុងអន្តរជាតិក្នុងកម្រិតខ្ពស់គ្រប់គ្រាន់ ដែលកត្តាទាំងនេះបានជួយបង្កើនជំនឿទុកចិត្តរបស់វិនិយោគិននិងសាធារណជនមកលើសេដ្ឋកិច្ចជាតិ។

ប្រព័ន្ធធនាគាររក្សាបានស្ថិរភាព ជាមួយនឹងភាពរឹងមាំនៃស្ថានភាពដើមទុននិងសន្ទនីយភាព ព្រមទាំងបានរួមចំណែកគាំទ្រកំណើន តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុចាំបាច់សម្រាប់គាំទ្រការវិនិយោគ និងការប្រើប្រាស់ក្នុងសេដ្ឋកិច្ច។ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឥណទានទៅកាន់វិស័យចម្បងៗ និងប្រាក់បញ្ញើអតិថិជន បានបន្តកើនឡើង ក្នុងពេលដែលយុទ្ធសាស្ត្រចាកចេញពីវិបត្តិត្រូវបានអនុវត្តជាជំហានៗ ដើម្បីពង្រឹងភាពធន់នៃប្រព័ន្ធធនាគារ។ម្យ៉ាងទៀត ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ជាពិសេសតាមរយៈការទូទាត់អេឡិចត្រូនិក បានបង្កើនប្រសិទ្ធភាពនិងសុវត្ថិភាពក្នុងប្រតិបត្តិការទូទាត់ ព្រមទាំងបានលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងបានសម្រួលដល់ការទូទាត់ឆ្លងដែនជាមួយប្រទេសក្នុងតំបន់។ ធនាគារជាតិនៃកម្ពុជាក៏បានបន្តលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជន តាមរយៈការអនុវត្តនូវសកម្មភាពនិងយុទ្ធនាការនានា ព្រមទាំងបានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូពាក់ព័ន្ធ។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តពង្រឹងការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងបានរួមចំណែកដ៏សំខាន់ក្នុងការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ដោយទទួលបានជោគជ័យក្នុងការដកកម្ពុជាចេញពីបញ្ជីប្រផេះ។

កិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី ត្រូវបានបន្តពង្រឹងជាប្រចាំ ដែលបានរួមចំណែកជំរុញសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក ព្រមទាំងបានលើកកម្ពស់ការចែករំលែកចំណេះដឹងនិងបទពិសោធន៍ការងារ ការទទួលបានជំនួយបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជាផងដែរ។

# ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារ ឆមាសទី២ ឆ្នាំ២០២៣

## ទស្សនវិស័យ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៣

សេដ្ឋកិច្ចពិភពលោក បាននិងកំពុងប្រឈមនឹងភាពមិនច្បាស់លាស់នៅឆ្នាំ២០២៣នេះ ដោយសារៈ i/-ភាពតានតឹងភូមិសាស្ត្រនយោបាយ រួមមាន ការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលអាចបន្តប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់សកលនិងបន្តដាក់សម្ពាធលើអតិផរណា ii/-ការបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត ដែលអាចបង្កឱ្យមានភាពមិនច្បាស់លាស់នៃលំហូរមូលធនចេញពីប្រទេសកំពុងលូតលាស់ និងកំពុងអភិវឌ្ឍន៍ iii/-ការបំប្លែងមេរោគកូវីដ-១៩ ប្រភេទថ្មី ដែលអាចបង្កឱ្យប៉ះពាល់ដល់ខ្សែច្រវាក់នៃការផ្គត់ផ្គង់ ប្រសិនបើមានការអនុវត្តវិធានការណ៍បិទខ្ទប់ឡើងវិញ iv/-ការកើនឡើងបំណុលសាធារណៈនិងឯកជន ដែលជាផលវិបាកចម្បងពីវិបត្តិកូវីដ-១៩ និង v/-គ្រោះមហន្តរាយធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ មូលនិធិរូបិយវត្ថុអន្តរជាតិ បានបន្ទាបការព្យាករកំណើនសេដ្ឋកិច្ចពិភពលោកឆ្នាំ២០២៣ បន្តិចមកត្រឹម ៣% (ការព្យាករក្នុងខែកក្កដា ឆ្នាំ២០២៣) ដែលក្នុងនោះ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍មានកំណើន ១,៥% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ៤% និងអាស៊ាន-៥[៤៧] ៤,៦%[៤៨]។

ដោយឡែកនៅកម្ពុជា កំណើនសេដ្ឋកិច្ចរំពឹងថាអាចសម្រេចបានក្នុងរង្វង់ ៥,៥% នៅឆ្នាំ២០២៣។ កំណើននេះ រួមចំណែកទ្រទ្រង់ដោយវិស័យចម្បងៗ រួមមាន៖ i/-វិស័យទេសចរណ៍ត្រូវបានរំពឹងថាមានកំណើនខ្ពស់ជាងឆ្នាំមុនដល់ ១៩,៩% ដោយសារភាពប្រសើរឡើងនៃស្ថានភាពទេសចរណ៍ក្នុងតំបន់ និងការគ្រប់គ្រងបាននៃការរីករាលដាលជំងឺកូវីដ-១៩ ii/-វិស័យកសិកម្មត្រូវបានព្យាករថានឹងបន្តមានកំណើនទាប ១,១% ដែលរួមចំណែកដោយភាពអំណោយផលនៃកត្តាអាកាសធាតុ ការចូលជាធរមានកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី iii/-វិស័យសំណង់ត្រូវបានរំពឹងថារួមចំណែកដល់កំណើនក្នុងកម្រិតទាបប្រមាណ ១,១% ដែលគាំទ្រដោយកំណើនលំហូរទុនវិនិយោគបរទេស និងគម្រោងសំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ iv/-វិស័យកាត់ដេរដែលមានចំណែកធំជាងគេក្នុងវិស័យឧស្សាហកម្មកម្ពុជា ត្រូវបានរំពឹងថាមានកំណើនទាប ៥,៩% ដោយសារការថមថយតម្រូវការខាងក្រៅ ជាពិសេស ប្រទេសដៃគូសំខាន់ៗដូចជា សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប និងអង់គ្លេស និង v/-វិស័យឧស្សាហកម្មក្រៅពីកាត់ដេរ ត្រូវបានរំពឹងថានឹងបន្តមានកំណើន ១០,១%។

ជាមួយគ្នានេះ វិស័យធនាគារនឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមគាំទ្រកំណើនសេដ្ឋកិច្ច តាមរយៈការផ្តល់ហិរញ្ញប្បទាននិងសេវាហិរញ្ញវត្ថុនានា ដោយឥណទានត្រូវបានរំពឹងថានឹងមានកំណើនក្នុងអត្រា ១៥% គួបផ្សំនឹងការបន្តអនុវត្តវិធានការគាំទ្រដទៃទៀត។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់អេឡិចត្រូនិកនឹងបន្តរួមចំណែកសម្រួលដល់សកម្មភាពពាណិជ្ជកម្មនិងការវិនិយោគក្នុងស្រុកនិងតំបន់ សំដៅគាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជានៅក្រោយវិបត្តិ ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការកសាងសេដ្ឋកិច្ចឌីជីថលដ៏រឹងមាំមួយ។

---

[៤៧] អាស៊ាន-៥ រួមមាន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និង វៀតណាម។

[៤៨] ការព្យាករក្នុងខែមេសា៖ សេដ្ឋកិច្ចពិភពលោកមានកំណើន ២,៨% ប្រទេសអភិវឌ្ឍន៍ ១,៣% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ៣,៩% និងអាស៊ាន ៤,៥% ។

## តារាង ៣ ៖ កំណើនសេដ្ឋកិច្ចកម្ពុជាតាមវិស័យ

| | ឆ្នាំ២០២១ | ឆ្នាំ២០២២ប | ឆ្នាំ២០២៣ព |
|---|---|---|---|
| កសិកម្ម | ១,៥១% | ០,២៧% | ១,១៤% |
| ឧស្សាហកម្ម | ៥,៦៤% | ៨,៨៥% | ៦,៧០% |
| សេវាកម្ម | ០,៣១% | ៣,៣៤% | ៦,១៩% |
| **កំណើនផ.ស.ស** | **២,៤២%** | **៥,២១%** | **៥,៥១%** |

*សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

## តារាង ៤ ៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជារបស់ស្ថាប័នអន្តរជាតិ

| | ឆ្នាំ២០២២ប | ឆ្នាំ២០២៣ព |
|---|---|---|
| រាជរដ្ឋាភិបាល | ៥,២% | ៥,៦% |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៥,០% | ៥,៨% |
| ធនាគារពិភពលោក (WB) | ៥,២% | ៥,៥% |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ៥,២% | ៥,៥% |

*សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

